សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et Des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សន្តតិកម្មតាមច្បាប់

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបរៀងដោយ៖
និស្សិតឈ្មោះ **រឿម ផានិត**
**ធុល វិយ៉ាដា**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតឈ្មោះ **អៀម ផានិត** និងឈ្មោះ **ធុល ទិយ៉ាដា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ថ្នាក់ L4C7 ជំនាន់ទី២២ ឆ្នាំសិក្សា២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាស្ត្រសេដ្ឋកិច្ច។

**សូមសម្តែងនូវការគោរពដឹងគុណកតញ្ញូកតវេទិតាធម៌ និងគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ**

លោកឪពុកឈ្មោះ **អៀម ឆន់** អ្នកម្តាយឈ្មោះ **រង់ ចាន់ថន** និង លោកឪពុកឈ្មោះ **ម៉ៅ ធុល** អ្នកម្តាយឈ្មោះ **រស់ ល្វាន់** ដែលលោកបានចិញ្ចឹមបីបាច់ថ្នាក់ថ្នមថៃរក្សាយើងខ្ញុំទាំងពីរនាក់ ប្រកបដោយព្រហ្មវិហារធម៌ បង្រៀន អប់រំទូន្មាន ប្រៀនប្រដៅឱ្យមានចរិយាមាយាទជាកូនល្អ លោកបានខិតខំធ្វើការទាំងយប់ទាំងថ្ងៃ មិនថាក្រោមផ្ទៃមេឃដ៏ក្តៅហួតហែង ក្រោមដំណក់ទឹកភ្លៀងធ្លាក់ជោគសព្វសារពាង្គកាយ ហូរញើស ស្រក់ឈាមគ្មាននឹកស្តាយ លះបង់សព្វគ្រប់បែបយ៉ាងទាំងកម្លាំងកាយចិត្ត ដើម្បីរកប្រាក់ជួយទំនុកបម្រុងឱ្យយើងខ្ញុំទាំងពីរនាក់បានសិក្សារៀនសូត្រ ស្វែងរកចំណេះវិជ្ជា តាំងពីនៅជាកុមារភាព រហូតដល់ធំដឹងក្តីនេះ។

ឯកឧត្តម **លុយ ចន្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិក**ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសដល់យើងខ្ញុំទាំងពីរបានសិក្សារៀនសូត្រនៅសាកលវិទ្យាល័យនេះ ដែលជាសាកលវិទ្យាល័យដ៏សំខាន់មួយដែលបានចូលរួមចំណែកក្នុងការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សទាំងក្នុងក្របខណ្ឌវិស័យច្បាប់។

លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលលោក បានមមាញឹកក្នុងការបង្រៀន ផ្ទេរចំណេះដឹង ក៏ដូចជាជួយធ្វើការពន្យល់ ណែនាំតម្រង់ទិស ផ្តល់ជាគំនិតល្អៗ កែតម្រូវកំហុសឆ្គងរបស់ពួកយើងខ្ញុំទាំងពីរតាំងពីចំណុចចាប់ផ្តើម រហូតដល់ទីបញ្ចប់ ដែលធ្វើឱ្យការសរសេរសារណារបស់យើងខ្ញុំទាំងពីរនាក់ សម្រេចបានជោគជ័យ និងសម្រេចបានជាស្ថាពរ ដែលជាសមិទ្ធផលនៃកិច្ចខំខិតប្រឹងប្រែងរបស់យើងខ្ញុំទាំងពីរនាក់គួរជាទីមោទនភាព។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមគោរពដឹងគុណកត្តញ្ញូតាធម៌ និងគោរពជូនពរ ចំពោះលោកឪពុកអ្នកម្តាយ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សូមប្រកបតែសុខភាពល្អ សេចក្តីសុខ សុភមង្គល និងសូមឧទ្ទិសបុណ្យកុសលជូនចំពោះវិញ្ញាណក្ខន្ធ អ្នកម្តាយឈ្មោះ **រស់ ល្វាន់** ព្រមទាំងបុព្វការីជន សូមទៅកាន់សុគតិភពដ៏បរមសុខរៀងអើយ។

# អារម្ភកថា

នៅក្នុងសង្គមខ្មែរយើងពីសម័យបុរាណ ឬយើងអាចរាប់ចាប់គិតពីឆ្នាំ ១៩៧៥ ថយក្រោយ ពាក្យដែលគេឧស្សាហ៍និយាយជាប់ពីមាត់មួយទៅមាត់មួយ នៅពេលដែលគ្រួសារមួយមានបុគ្គលម្នាក់ដែលជាមេគ្រួសារបានស្លាប់ ហើយបុគ្គលនោះបានបន្សល់ទុកនូវទ្រព្យសម្បត្តិដែលខ្លួនខំរកបាននៅពេលដែលខ្លួននៅរស់ ដែលត្រូវប្រគល់បន្តទៅឱ្យកូនចៅជំនាន់ក្រោយ មិនថាជា ផ្ទះ លុយកាក់ ដីធ្លី គ្រឿងអលង្ការ ជាអាទិ៍ ប្រជាជនខ្មែរយើងតែងតែនិយមហៅទ្រព្យសម្បត្តិទាំងនោះថាជា កេរ្តិ៍មត៌ក ឬជា របស់ប្រចាំត្រកូល។ ទ្រព្យសម្បត្តិដែលបន្សល់ទុកនេះហើយ គឺជាកម្មវត្ថុក្នុងការចាត់ចែង និងផ្ទេរទៅឱ្យអ្នកជំនាន់ក្រោយ ដើម្បីគ្រប់គ្រងបន្តនូវមត៌កនោះ។ម្យ៉ាងទៀត តាមរយៈការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរ យើងខ្ញុំទាំងពីរសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជាយើង នៅពុំទាន់បានយល់ច្បាស់អំពីសិទ្ធិដែលត្រូវទទួលបាន ដែលជាផលប្រយោជន៍សម្រាប់អ្នកទទួលបន្តនូវមត៌កពីបុគ្គលដែលបានស្លាប់ទៅ និងករណីកិច្ចមួយចំនួន នៅពេលដែលសន្តតិកម្មកើតឡើងនោះទេ។ ដោយផ្តើមចេញពីចំណុចនេះ រួមផ្សំជាមួយការសិក្សាអំពីមេរៀន និងបទប្បញ្ញត្តិស្តីពីសន្តតិកម្មដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាផងនោះ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរនាក់ បានសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី "**សន្តតិកម្មតាមច្បាប់**" ក្រោមការជួយណែនាំរបស់សាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដើម្បីធ្វើការពន្យល់បកស្រាយដោយយោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ និងច្បាប់ពាក់ព័ន្ធផ្សេងទៀតដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

មុននឹងឈានដល់ការបង្កើតស្នាដៃនេះឡើងមក យើងខ្ញុំទាំងពីរនាក់បានខិតខំអស់ពីកម្លាំងកាយចិត្តទាំងយប់ទាំងថ្ងៃក្នុងការសិក្សាស្រាវជ្រាវ ស្វែងរកឯកសារ ក៏ដូចជាសូមការណែនាំពីលោកសាស្ត្រាចារ្យ រៀមច្បងព្រមទាំងអ្នកប្រកបវិជ្ជាជីវៈច្បាប់ មានជាអាទិ៍ បងៗជាអ្នកប្រកបអាជីពជាមេធាវី ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាតដែលយើងខ្ញុំទាំងពីរបានជួបប្រទះក្នុងការសរសេរសារណានេះ ហើយយើងខ្ញុំទាំងពីរ សង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងក្លាយជាឯកសារមួយដ៏សំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងអស់ ដែលចង់ស្វែងយល់បន្ថែមទាក់ទងនឹងសន្តតិកម្មដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

ទោះជាយ៉ាងនេះក្តី យើងខ្ញុំទាំងពីរនៅតែមានការជឿជាក់ថា ការបង្កើតសារណាមួយនេះឡើង នៅតែមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ពោលគឺនៅតែមានចំណុចខ្វះខាត កំហុសឆ្គងទាំងពាក្យពេចន៍ អត្ថន័យ កើតឡើងដោយអចេតនាត្រង់ចំណុចណាមួយជាក់ជាពុំខានឡើយ។ យើងខ្ញុំទាំងពីរនាក់ សូមស្វាគមន៍យ៉ាងកក់ក្តៅនិងរីករាយទទួលយកនូវរាល់មតិរិះគន់កែលម្អ ក្នុងន័យស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ អ្នកអាន អ្នកសិក្សាពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើអោយសារណាមួយនេះមានអត្ថន័យ ខ្លឹមសារ ត្រឹមត្រូវគ្រប់គ្រាន់ សម្រាប់ឱ្យអ្នកសិក្សាគ្រប់រូប ក៏ដូចជាប្អូនៗជំនាន់ក្រោយយកទៅសិក្សាស្វែងយល់បន្ថែម។

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........ ១

ជំពូកទី១

សញ្ញាណទូទៅនៃសន្តតិកម្ម

ផ្នែកទី១ ៖ ការចាប់ផ្តើមសន្តតិកម្ម ........ ៥

១.១ មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម ........ ៥

១.២ ពេលវេលា និងទីកន្លែងចាប់ផ្តើមសន្តតិកម្ម ........ ៧

ផ្នែកទី២ ៖ បុគ្គលដែលអាចក្លាយជាសន្តតិជន ........ ៨

២.១ រូបវន្តបុគ្គល ........ ៨

២.១.១ ទារកក្នុងគភ៌ ........ ៩

២.១.២ អនីតិជន ........ ៩

២.១.៣ អនីតិជនដែលទទួលបានអត្តាធីនភាព ........ ១០

២.១.៤ នីតិជន ........ ១១

២.១.៥ ជននៅក្រោមហិតូបត្ថម្ភ ........ ១១

២.១.៦ ជននៅក្រោមអាណាព្យាបាលទូទៅ ........ ១២

២.១.៧ ជនបរទេស ........ ១៣

២.២ នីតិបុគ្គល ........ ១៥

ផ្នែកទី៣ ៖ បុគ្គលដែលគ្មានលក្ខណសម្បត្តិជាសន្តតិជន ........ ១៦

៣.១ អភ័ព្វបុគ្គល ........ ១៦

៣.២ បុគ្គលដែលត្រូវបានផ្តាច់ពីមត៌ក ........ ១៧

ជំពូកទី២

លំដាប់សន្តតិជន និងការសម្រួលចំណែកមត៌ក

ផ្នែកទី១ ៖ លំដាប់សន្តតិជន ........ ១៩

១.១ លំដាប់នៃសន្តតិជន ........ ១៩

១.១.១ សន្តតិជនលំដាប់ទី១ ........ ២០

១.១.២ សន្តតិជនលំដាប់ទី២ ........ ២២

១.១.៣ សន្តតិជនលំដាប់ទី៣ ........ ២២

១.១.៤ សន្តតិជនជំនួស ........ ២៣

១.១.៥ សន្តតិជនជានិច្ច ........ ២៤

១.២ ចំណែកមត៌កតាមច្បាប់ ........ ២៥

១.២.១ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី១ ........ ២៦

១.២.២ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី២ ........ ២៦

១.២.៣ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី៣ ........ ២៧

១.២.៤ ចំណែកមត៌កនៃសន្តតិជនជំនួស ........ ២៨

១.២.៥ ចំណែកមត៌កនៃសន្តតិជនជានិច្ច ........ ២៨

**ផ្នែកទី២ ៖ ការសម្រួលចំណែកមត៌ក** ........ ៣០

២.១ ករណីមានការទទួលផលប្រយោជន៍ពិសេស ........ ៣១

២.២ ករណីមានការធ្វើភាគនៃវិភាគទាន ........ ៣១

២.៣ វិធីសម្រួលចំណែកមត៌ក ........ ៣២

## ជំពូកទី៣

## ការប្រតិបត្តិសន្តតិកម្ម

**ផ្នែកទី១ ៖ ការយល់ព្រមទទួលសន្តតិកម្ម** ........ ៣៧

១.១ ការយល់ព្រមទាំងស្រុង ........ ៣៩

១.២. ការយល់ព្រមដោយកម្រិត ........ ៤០

**ផ្នែកទី២ ៖ ការបោះបង់សន្តតិកម្ម** ........ ៤១

**ផ្នែកទី៣ ៖ ការគ្រប់គ្រងមត៌ក** ........ ៤២

៣.១ ការគ្រប់គ្រងមត៌កដោយសន្តតិជន ........ ៤២

៣.២ ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍ ........ ៤២

៣.៣ ការគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ........ ៤៣

**ផ្នែកទី៤ ៖ ការបែងចែកមត៌ក** ........ ៤៣
៤.១ ការបែងចែកមត៌កដោយសហសន្តតិជន ........ ៤៣
៤.១.១ មូលដ្ឋាននៃការបែងចែក ........ ៤៧
៤.១.២ សិទ្ធិអាទិភាពរបស់សហព័ទ្ធ ........ ៤៧
៤.១.៣ សំណងនៃកាតព្វកិច្ចរបស់មតកជន ........ ៤៨
**៤.២ ការបែងចែកដោយតុលាការ** ........ ៤៩
៤.២.១ ការប្ដូរជាប្រាក់ដោយការលក់ ........ ៤៩
៤.២.២ អានុភាពនៃការបែងចែក ........ ៥០
៤.៣ ការសម្រួលរវាងម្ចាស់បំណុល ........ ៥០
៤.៤ ការជម្រះបញ្ជីក្នុងករណីមានការយល់ព្រមដោយកម្រិត ........ ៥១
**ផ្នែកទី៥ ៖ នត្ថិភាពនៃសន្តតិជន** ........ ៥៤
៥.១ នីតិបុគ្គលមត៌ក ........ ៥៥
៥.១.១ ការជ្រើសតាំងអ្នកគ្រប់គ្រង ........ ៥៥
៥.១.២ ការជូនដំណឹងជាសាធារណៈ ........ ៥៦
៥.២ ចំណែកនៃជនដែលមានឧបនិស្ស័យពិសេស ........ ៥៧
៥.៣ មត៌កដែលក្លាយជារបស់រដ្ឋ ........ ៥៧
**ផ្នែកទី៦ ៖ ការទាមទារបដិទានសន្តតិកម្ម** ........ ៥៨
៦.១ បុគ្គលដែលមានសិទ្ធិទាមទារ ........ ៥៨
៦.២ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ ........ ៥៩
**សេចក្ដីសន្និដ្ឋាន** ........ ៦០
**អនុសាសន៍** ........ ៦២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយនៅអាស៊ីអាគ្នេយ៍ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ វៀតណាម និង ឡាវ ដែលមានផ្ទៃក្រឡា ១៨១,០៣៥ គីឡូម៉ែត្រការ៉េ។ មិនតែប៉ុណ្ណោះ កម្ពុជា ក៏ជាប្រទេសមួយដែលបានឆ្លងកាត់ជាច្រើនសម័យកាល ទាំងសម័យកាលរុងរឿង និងសម័យកាលដ៏ខ្មៅងងឹត ពិសេសគឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបណ្តាលឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធសង្គម បាត់បង់ធនធានមនុស្សដែលជាសសរទ្រូងនៃប្រទេសជាតិ ព្រមទាំងវិស័យសំខាន់ៗជាច្រើនផងដែរ។

ក្រោយពីទទួលបានសន្តិភាព និងស្ថេរភាពខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងវប្បធម៌ឡើងវិញ កម្ពុជាបានខិតខំស្តារមុខមាត់ប្រទេសជាតិ ដោយយកចិត្តទុកដាក់ស្ទើរគ្រប់វិស័យ រួមទាំងវិស័យយុត្តិធម៌ផងដែរ ដែលជាវិស័យដ៏សំខាន់មួយសម្រាប់បម្រើការរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយសិទ្ធិស្មើគ្នាៗនិងដើម្បីដោះស្រាយបញ្ហានានាពេលមានវិវាទកើតឡើង។

មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជា ទាំងស្ថាប័ននីតិបញ្ញត្តិ និង ស្ថាប័ននីតិប្រតិបត្តិ តែងតែខិតខំនិងស្រាវជ្រាវច្បាប់ ឱ្យសមស្របទៅតាមតថភាពសង្គមជាក់ស្តែងនាពេលបច្ចុប្បន្ន និងមានគោលបំណងឱ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិលើកម្មសិទ្ធិគ្រប់ៗគ្នា មិនថាសិទ្ធិប្រើប្រាស់ អាស្រ័យផល និងសិទ្ធិចាត់ចែងលើទ្រព្យសម្បត្តិរបស់ខ្លួនបានដោយសេរី ទាំងពេលមានជីវិត និង រហូតក្រោយពេលទទួលមរណភាព ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់កំណត់។ ការចាត់ចែងទ្រព្យសម្បត្តិដោយការផ្ទេរទ្រព្យសម្បត្តិពីបុគ្គលដែលទទួលមរណភាពទៅឱ្យបុគ្គលដែលនៅរស់ ក្នុងន័យបច្ចេកទេសច្បាប់គេហៅថា សន្តតិកម្ម។ សន្តតិកម្ម ត្រូវបានយកមកអនុវត្តតាំងពីសម័យបុរាណមកម្ល៉េះ ដោយបុព្វបុរសខ្មែរមានបំណងចង់ឱ្យបច្ឆាញាតិដែលជាកូនចៅ បានទទួល និងគ្រប់គ្រងបន្តនូវកេរ្តិ៍មត៌ករបស់ខ្លួនពីពូជពង្សមួយទៅពូជពង្សមួយទៀត។

បច្ចុប្បន្ននេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គន្ថីទី៨ ក៏បានកំណត់ផងដែរអំពីសន្តតិកម្ម។ ទ្រព្យសម្បត្តិដែលមតកជនបានបន្សល់ទុក គឺជាកម្មវត្ថុក្នុងការចាត់ចែង និងផ្ទេរទៅឱ្យអ្នកជំនាន់ក្រោយ ដើម្បីគ្រប់គ្រងបន្តនូវមត៌កនោះ។ វាមានលក្ខណៈស្មុគស្មាញ ដើម្បីកំណត់ថា តើមានទ្រព្យណាខ្លះ ដែលត្រូវបានផ្ទេរទៅឱ្យអ្នកបន្តវេន ហើយអ្នកដែលទទួលបន្តនូវទ្រព្យទាំងនោះ អាចទទួលបានក្នុងទំហំប៉ុណ្ណា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រសិនបើមានករណីមតកជនបានទទួលមរណភាព មុនពេលធ្វើការបែងចែកមត៌កទៅឱ្យអ្នកស្នង ឬមិនបានធ្វើបណ្តាំមត៌កជាមុននោះ តើសន្តតិកម្មនឹងប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើនរណាខ្លះមានសិទ្ធិទទួលបាននូវសន្តតិកម្ម ហើយទទួលបានចំណែកមត៌កដូចម្តេចខ្លះ?

ក្រោមការជួយណែនាំពីសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** រួមជាមួយនឹងការសិក្សាអំពីក្រមរដ្ឋប្បវេណី យើងខ្ញុំទាំងពីររូប បានធ្វើការជ្រើសរើសស្រាវជ្រាវទៅលើប្រធានបទអំពី "**សន្តតិកម្មតាមច្បាប់**" ដើម្បីធ្វើការបកស្រាយនិងបំភ្លឺដូចអត្ថបទនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនូវប្រធានបទខាងលើនេះ យើងខ្ញុំមានគោលបំណងចង់ធ្វើការពន្យល់បកស្រាយឱ្យកាន់តែស៊ីជម្រៅ នូវសន្តតិកម្មតាមច្បាប់ ដែលកំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះរួមមាន៖

- សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់
- ការចាប់ផ្តើមសន្តតិកម្ម
- បុគ្គលដែលអាចក្លាយជាសន្តតិជន
- ការបែងចែកមត៌ក
- ការសម្រួលចំណែកមត៌ក
- ការយល់ព្រមទទួលសន្តតិកម្ម
- ការបោះបង់សន្តតិកម្ម
- នត្ថិភាពនៃសន្តតិជន
- ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ជាអាទិ៍។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទខាងលើនេះ យើងខ្ញុំបានខិតខំស្រាវជ្រាវអស់ពីកម្លាំងកាយចិត្តស្វែងរកតាមគ្រប់មធ្យោបាយ និងតាមលទ្ធភាពដោយប្រធានបទស្តីពី សន្តតិកម្មតាមច្បាប់នេះ ត្រូវបានស្រាវជ្រាវ និងសរសេរចងក្រងឡើង ដោយយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ ច្បាប់ពាក់ព័ន្ធនានា រួមជាមួយនឹងចំណេះដឹងដែលទទួលបានពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យច្បាប់ មេធាវី សិស្សច្បង ដើម្បីធ្វើការចងក្រងបង្កើតជាស្នាដៃនេះឡើង។

មិនតែប៉ុណ្ណោះ ក្នុងការស្រាវជ្រាវនេះផងដែរ យើងខ្ញុំនឹងធ្វើការពន្យល់បកស្រាយលើចំណុចសំខាន់ៗទាក់ទងនឹងរបបសន្តតិកម្មតាមច្បាប់ដែលកើតមានឡើងជាបញ្ហាចំពោះប្រជាពលរដ្ឋក្នុងសង្គមបច្ចុប្បន្ន។

មួយវិញទៀត ការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំចង់បង្ហាញនូវទស្សនទានអំពីសន្តតិកម្មតាមច្បាប់ ដែលត្រូវបានយកមកអនុវត្ត និងមានវិសាលភាពក្នុងប្រព័ន្ធច្បាប់នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

អាស្រ័យដូចនេះហើយ ក្នុងនាមជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ហើយមានបំណងបកស្រាយឱ្យកាន់តែច្បាស់ ទាក់ទងទៅនឹងរបបសន្តតិកម្មតាមច្បាប់នេះ យើងបានបកស្រាយដោយផ្អែកលើឯកសារផ្លូវការមួយចំនួនដែលអាចឱ្យអ្នកអានកាន់តែមានភាពងាយស្រួលក្នុងការស្វែងរកកម្មវត្ថុ និងគោលបំណងដែលកើតមានឡើងនៅក្នុងរបបសន្តតិកម្មតាមច្បាប់ ដោយហេតុថា ការសិក្សាស្រាវជ្រាវអំពីរបបសន្តតិកម្ម នៅមិនទាន់មានការសិក្សាយល់ដឹងឱ្យបានស៊ីជម្រៅនៅឡើយ។ ម្យ៉ាងទៀត ការអនុវត្តជាក់ស្តែង ក៏នៅតែមិនទាន់ត្រឹមត្រូវ និងមានប្រសិទ្ធភាពស្របតាមច្បាប់នោះដែរ ពីព្រោះថាការយល់ដឹងអំពីច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ។ ដូចនេះ ដើម្បីឆ្លើយតប និងចូលរួមដោះស្រាយពីបញ្ហាខាងលើនេះ ក្នុងនាមជានិស្សិតច្បាប់ ក៏ដូចជាមន្ត្រីអនុវត្តច្បាប់ ត្រូវព្យាយាមផ្សព្វផ្សាយពន្យល់ដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីសន្តតិកម្ម ពីព្រោះថាវាបានជាប់ទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃដែលជាផលប្រយោជន៍របស់ប្រជាពលរដ្ឋ ក៏ដូចជាសម្រាប់អ្នកដែលទទួលបន្តនូវមត៌ក ពិសេសគឺសម្រាប់អ្នកច្បាប់ដែលត្រូវសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ ដើម្បីចូលរួមដោះស្រាយបញ្ហាទាំងនេះនាពេលអនាគត នៅពេលដែលខ្លួនបានក្លាយជាអ្នកប្រកបវិជ្ជាជីវៈច្បាប់។ ប្រការដ៏សំខាន់នៃសៀវភៅសារណានេះ ក៏បានបង្ហាញអំពីសាមគ្គីភាពនៃយើងខ្ញុំទាំងពីរនាក់ ដែលបានចូលរួមសហការគ្នាយ៉ាងសស្រាក់សស្រាំ និងប្រកបដោយស្មារតីទទួលខុសត្រូវចំពោះការបំពេញកាតព្វកិច្ចនេះផងដែរ។

## ៦. វិធីសាស្ត្រនៃស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី សន្តតិកម្មតាមច្បាប់ គឺយើងខ្ញុំទាំងពីរនាក់ បានធ្វើការស្រាវជ្រាវស្វែងរកឯកសារដែលពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមរយៈប្រព័ន្ធអ៊ីនធើណែត ឯកសារមេរៀនដែលយើងខ្ញុំទាំងពីរនាក់ទទួលបានពីការសិក្សានីតិសាស្ត្ររយៈពេល៤ឆ្នាំ ជាពិសេសច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានចែងជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការជួយពន្យល់ណែនាំពីលោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីពន្យល់អំពីប្រធានបទ "**សន្តតិកម្មតាមច្បាប់**" ឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការបែងចែកខ្លឹមសារជាបីជំពូកធំៗគឺ៖

ជំពូកទី១ ៖ សញ្ញាណទូទៅនៃសន្តតិកម្ម

ជំពូកទី២ ៖ លំដាប់សន្តតិជន និងការសម្រួលចំណែកមត៌ក

ជំពូកទី៣ ៖ ការប្រតិបត្តិសន្តតិកម្ម

# ជំពូកទី១
# សញ្ញាណទូទៅនៃសន្តតិកម្ម

# ជំពូកទី១
# សញ្ញាណទូទៅនៃសន្តតិកម្ម

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់[1]។ បើក្រឡេកទៅមើលអត្ថន័យនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ វិញ គឺមិនមានលក្ខណៈខុសគ្នាប៉ុន្មាននោះទេ ដោយសន្តតិកម្ម ត្រូវបានកំណត់និយមន័យថា គឺជាការបញ្ជូនតាមច្បាប់នូវទ្រព្យរបស់អ្នកស្លាប់ ឱ្យទៅអ្នករស់[2]។ចំពោះបុគ្គលដែលបានទទួលមរណភាពទៅហើយ ហើយបន្សល់ទុកនូវទ្រព្យសម្បត្តិដែលនឹងក្លាយជាមត៌កនោះ ហៅថា "មតកជន" ចំណែកឯ ជនដែលទទួលបន្តនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចរបស់មតកជន តាមរយៈសន្តតិកម្ម ឬអាចនិយាយម្យ៉ាងទៀតថា ជាបុគ្គលដែលមានសិទ្ធិក្នុងការទទួលយកមត៌កពីមតកជននោះ ហៅថា "សន្តតិជន" ។

របបសន្តតិកម្មនៅក្នុងពិភពលោកនេះ ត្រូវបានចែកចេញជា ២ប្រភេទ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចទាំងអស់របស់មតកជន។ ដូច្នេះ សន្តតិជនបានទទួលបន្តនូវឋានៈរបស់មតកជនតែម្តង។ ក៏ប៉ុន្តែក្នុងករណីដែលមតកជននោះ បានបន្សល់នូវកាតព្វកិច្ចច្រើនពេក ប្រសិនបើសន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះ នឹងធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ ដោយសារសន្តតិកម្ម ដូច្នេះហើយ បានជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិត ដើម្បីចៀសវាងនូវស្ថានភាពនេះ។ ចំណែកឯ គោលការណ៍ជម្រះបញ្ជី គឺត្រូវជម្រះបញ្ជីទាំងអស់នូវសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់មតកជន ពេលដែលសន្តតិកម្មកើតមានឡើង ហើយសន្តតិជននឹងស្នងទ្រព្យនោះ តែក្នុងករណីដែលមានទ្រព្យសកម្មប៉ុណ្ណោះ ហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុពេកត្រូវប្រកាសធនក្ស័យនៃមត៌កនោះ ដើម្បីកុំឱ្យសន្តតិជនទទួលនូវបន្ទុកកាតព្វកិច្ចនោះ។ នេះជាគោលការណ៍មួយ ដែលស្របទៅតាមសមភាពរវាងម្ចាស់បំណុលរបស់មតកជន និងសន្តតិជន ក៏ប៉ុន្តែ មានការលំបាកដូចជា នីតិវិធីស្មុគស្មាញ អស់សោហ៊ុយ និងត្រូវចំណាយពេលវេលាច្រើន[3]។

បើយើងពិនិត្យទៅលើក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាវិញឃើញថា ប្រទេសកម្ពុជាយើង បានជ្រើសរើសគោលការណ៍ របបសន្តតិកម្មទទួលយកដោយស្វ័យប្រវត្តិ ដើម្បីស្របទៅតាមស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនាពេលបច្ចុប្បន្ន។

[1] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

[2] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧

[3] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-គន្ថីទី៩ ទំព័រទី១

## ផ្នែកទី១ ៖ ការចាប់ផ្ដើមសន្តតិកម្ម

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានបញ្ញត្តិផងដែរ អំពីមូលហេតុដែលនាំឱ្យសន្តតិកម្មត្រូវចាប់ផ្ដើមឡើងហើយព្រមគ្នាទៅនឹងពេលវេលានិងទីកន្លែងនៃការចាប់ផ្ដើមសន្តតិកម្មផងដែរ ពីព្រោះថានៅពេលដែលមានការចាប់ផ្ដើមសន្តតិកម្ម អានុភាពរបស់វាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសិទ្ធិ និងករណីកិច្ចរបស់សន្តតិជន និងជនដែលពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិដែលត្រូវក្លាយជាមត៌កនាពេលចាប់ផ្ដើមសន្តតិកម្មនោះ។

### ១.១ មូលហេតុនៃការចាប់ផ្ដើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន[4]។ មានន័យថា នៅពេលដែលមតកជននៅរស់ គឺមិនអាចចាប់ផ្ដើមសន្តតិកម្មបានទេ ហើយក៏មិនត្រូវបានទទួលស្គាល់ចំពោះការធ្វើសន្តតិកម្មនោះដែរ។ មរណភាព គឺជាពេលដែលសួត បេះដូង ខួរក្បាល ឈប់មានដំណើរការ ហើយមានគេបញ្ជាក់មរណភាព ដោយពិនិត្យមើលការអស់ដង្ហើម បេះដូងឈប់លោត និងការរីកនៃប្រស្រីភ្នែក ព្រមទាំងភាពគ្មានប្រតិកម្មនៃពន្លឺ[5]។ ប៉ុន្តែ ក្នុងករណីដែលបុគ្គលណាម្នាក់ស្ថិតក្នុងស្ថានភាពមួយដែលមិនច្បាស់លាស់ថាស្លាប់ ឬនៅរស់ ដែលគេហៅថា ការបាត់ខ្លួន ហើយមានសាលក្រមជាស្ថាពរប្រកាសដោយតុលាការថាបុគ្គលនោះបានបាត់ខ្លួន ក៏ជាមូលហេតុដែលនាំឱ្យមានការចាប់ផ្ដើមសន្តតិកម្មដែរ។ ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់ សហព័ទ្ធ អ្នកដែលត្រូវបានសន្មតជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្ដាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន។ម្យ៉ាងទៀត តុលាការអាចប្រកាសថាបុគ្គលនោះបានបាត់ខ្លួន ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថាអ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ[6]។ ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើងដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការដាស់តឿនជាសាធារណៈ[7]។ ការដាស់តឿនជាសាធារណៈនេះ ត្រូវធ្វើឡើងតាមវិធីផ្សាយជាសាធារណៈ។ ការផ្សាយជាសាធារណៈ ត្រូវធ្វើដោយបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ

[4] មាត្រា ១១៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[5] សៀវភៅសេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ ១-៣ ទំព័រទី១៣

[6] មាត្រា ៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[7] មាត្រា ៤២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

និងចុះផ្សាយនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចធ្វើការផ្សាយជាសាធារណៈ តាមការចុះផ្សាយនៅក្នុងសារពត៌មានប្រចាំថ្ងៃ ឬតាមវិធីផ្សេងទៀតដែលយល់ឃើញថាសមរម្យបាន។ ការផ្សាយជាសាធារណៈនេះ ត្រូវបញ្ជាក់អំពីចំណុចដូចខាងក្រោមៈ

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ។
- ឈ្មោះ និងអាសយដ្ឋានចុងក្រោយដែលត្រូវបានដឹង និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកអវត្តមាន។
- កំណត់ថា អ្នកអវត្តមានត្រូវផ្តល់ពត៌មានអំពីការរស់នៅរបស់ខ្លួន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ហើយបើមិនបានផ្តល់ពត៌មានមុនអំឡុងពេលនេះទេ អ្នកអវត្តមាននោះ នឹងទទួលការប្រកាសអំពីការបាត់ខ្លួន។
- កំណត់ថា ជនដែលដឹងអំពីការនៅរស់ ឬមរណភាពរបស់អ្នកអវត្តមាន ត្រូវផ្តល់ពត៌មាន នៅមុនពេលចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ។
- ថ្ងៃចប់អំឡុងពេលនៃការដាស់តឿនជាសាធារណៈ។
- អំឡុងពេលនៃការដាស់តឿនជាសាធារណៈ ត្រូវមានមិនតិចជាង ៦ខែ ក្នុងករណីប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ឆ្នាំ ហើយមិនតិចជាង ២ខែ ក្នុងករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ១ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ[8]។

ដូចនេះ ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាស បន្ទាប់ពីពេលដែលអំឡុងពេល ៥ឆ្នាំ បានកន្លងផុត និងក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសក្នុងអំឡុងពេល ១ឆ្នាំ បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព ចំពោះទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬទីសំណាក់[9]។ មានន័យថា សន្តតិកម្មអាចចាប់ផ្តើមបាន ហើយសហព័ទ្ធម្ខាងទៀតអាចរៀបអាពាហ៍ពិពាហ៍ថ្មីបាន។ ប៉ុន្តែត្រូវចាត់ទុកថាបានទទួលមរណភាពចំពោះតែទំនាក់ទំនងគតិយុត្តនៅជុំវិញលំនៅឋានប៉ុណ្ណោះ មិនមែនដកហូតសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលនោះទេ។ ដូច្នេះហើយ បើបុគ្គលនោះនៅរស់ ហើយរស់នៅកន្លែងផ្សេង បុគ្គលនោះអាចធ្វើលទ្ធកម្មនូវសិទ្ធិ និងកាតព្វកិច្ចបាន[10]។

---

[8] មាត្រា ៥៤ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[9] មាត្រា៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] សៀវភៅនីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធផលរបស់ក្រុមការងារសសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## ១.២ ពេលវេលា និងទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព[11]។ លំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ[12]។ លំនៅឋានរបស់មនុស្សម្នាក់ៗ គឺជាកន្លែងដែលអ្នកនោះបានកំណត់ស្នាក់នៅរបស់ខ្លួនជាទម្លាប់របស់គេ ហើយជាទីតាំងដ៏សំខាន់នៃកិច្ចការ និងជីវភាពរស់នៅរបស់គេប្រចាំថ្ងៃ។ លំនៅឋាន ត្រូវកំណត់យកតែមួយគត់ ព្រោះជាកន្លែងដែលភ្ជាប់បុគ្គលិកលក្ខណៈគតិយុត្តនៃរូបវន្តបុគ្គល ទៅនឹងលំនៅឋាននោះ។ នៅពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ហើយការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព[13]។ ម្យ៉ាងទៀត បើមានពលរដ្ឋខ្មែររស់នៅក្នុងឃុំ ឬសង្កាត់ណាមួយ បានទៅស្លាប់នៅឃុំ ឬសង្កាត់ផ្សេង មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬសង្កាត់របស់អ្នកស្លាប់រស់នៅ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់ ឱ្យទៅយកសពធ្វើបុណ្យ និងចុះសៀវភៅមរណភាពនៅឃុំ ឬសង្កាត់នៃអ្នកស្លាប់នោះស្នាក់នៅជាប់លាប់[14]។ ប៉ុន្តែក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន[15]។

ម្យ៉ាងទៀត ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន[16]។

ការកំណត់លំនៅឋានច្បាស់លាស់របស់បុគ្គលម្នាក់គឺបានផ្តល់ភាពងាយស្រួលក្នុងរឿងក្តីរដ្ឋប្បវេណីដូចជាក្នុងករណីដែលមានបណ្តឹងចំពោះចុងចម្លើយ ត្រូវដាក់ពាក្យបណ្តឹងទៅសាលាដំបូងដែលមានសមត្ថកិច្ចជម្រះក្តីនៅលំនៅឋានរបស់ចុងចម្លើយ ឬទីសំណាក់ បើពុំមានលំនៅឋាន ឬមានលំនៅឋានមិនពិតប្រាកដនៅក្នុងព្រះរាជាណាចក្រកម្ពុជា[17]។

---

11 មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

12 មាត្រា ៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

13 មាត្រា ៣៥ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

14 មាត្រា ៣៧ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០

15 មាត្រា ៣៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

16 មាត្រា ៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

17 មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

## ផ្នែកទី២ ៖ បុគ្គលដែលអាចក្លាយជាសន្តតិជន

បុគ្គលដែលមានលក្ខណៈគ្រប់គ្រាន់ជាសន្តតិជន គឺជាបុគ្គលដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ហើយមិនមែនជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្តាច់មត៌ក ទើបអាចទទួលសន្តតិកម្មបាន[18]។ មានន័យថា សន្តតិកម្មអាចធ្វើឡើងបានតែចំពោះបុគ្គលដែលមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ។ ដូច្នេះក្នុងករណីដែលមតកជន និងជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាពព្រមជាមួយគ្នា នោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនបំពេញល័ក្ខខ័ណ្ឌមានជីវិតរស់នៅ នៅពេលចាប់ផ្តើមសន្តតិកម្មទេ[19]។

### ២.១ រូបវន្តបុគ្គល

រូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល[20]។ ជាគោលការណ៍ រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន[21]។ មានន័យថា គ្រប់រូបវន្តបុគ្គលទាំងអស់ មិនថាជនជាតិខ្មែរ ឬជនជាតិបរទេស អាចទទួលបាននូវសិទ្ធិបុគ្គលដូចគ្នា។ ប៉ុន្តែចំពោះជនបរទេសដែលរស់នៅលើទឹកដីខ្មែរ ត្រូវបានក្រមរដ្ឋប្បវេណី ត្រង់មាត្រា ៧ កម្រិតនូវសិទ្ធិមួយចំនួន ដោយមាត្រានេះបានចែងថា ជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ នៅក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ[22]។ ការកម្រិតសិទ្ធិនេះ ក៏មានចែងនៅក្នុងបញ្ញត្តិនៃមាត្រា៤៤ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ បញ្ញត្តិនេះបានចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ បើយើងក្រឡេកទៅមើលច្បាប់ភូមិបាលវិញ ក៏មានចែងអំពីការកម្រិតនូវសិទ្ធិរបស់ជនបរទេសផងដែរ ដោយមាត្រា ៨ ចែងថា មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីនៃព្រះរាជាណាចក្រកម្ពុជា[23]។សញ្ជាតិខ្មែរ សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា[24]។ ដូចនេះហើយ នៅពេលដែលសន្តតិកម្មបានកើតឡើង រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ មិនថារូបវន្តបុគ្គលនោះជា នីតិជនក្តី ឬជនដែលត្រូវបានកម្រិតសមត្ថភាពក្តី ដែលអាចជាអនីតិជន

[18] មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[19] សេចក្តីកំណត់មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[20] សន្ទានុក្រមផ្នែករដ្ឋប្បវេណី
[21] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[22] មាត្រា ៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[23] មាត្រា ៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១
[24] មាត្រា ៤ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ អាចក្លាយជាសន្តតិជនទទួលបន្តនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចពីមតកជន ហើយប្រសិនបើមតកជនបន្សល់ទុកនូវទ្រព្យសកម្ម សន្តតិជនដែលមានសញ្ជាតិខ្មែរ អាចទទួលបានទ្រព្យដែលជាមត៌កទាំងចលនវត្ថុ និងអចលនវត្ថុ។ ចំណែកឯសន្តតិជនដែលគ្មានសញ្ជាតិជាខ្មែរ មិនអាចទទួលបានមត៌កអចលនវត្ថុជាដីធ្លីបានឡើយ។ លើសពីនេះទៅទៀត ចំពោះទារកក្នុងគភ៌ដែលមិនទាន់ចាប់កំណើត ក៏មានសិទ្ធិក្លាយជាសន្តតិជនបានដែរ។ ទោះជាយ៉ាងនេះក្តី ក្នុងករណីដែលរូបវន្តបុគ្គល បានក្លាយជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្តាច់មត៌កពីសន្តតិកម្ម បុគ្គលនោះមិនអាចក្លាយជាសន្តតិជន ហើយគ្មានសិទ្ធិទទួលបានចំណែកមត៌កពីសន្តតិកម្មឡើយ។

### ២.១.១ ទារកក្នុងគភ៌

ចំពោះទារកនៅក្នុងគភ៌ ក៏អាចក្លាយជាសន្តតិជន ដែលត្រូវទទួលចំណែកមត៌កពីមតកជនបានដែរ ប្រសិនបើនាពេលដែលចាប់ផ្តើមសន្តតិកម្ម ទារកនោះមានកំណើតនៅពេលក្រោយ ហើយអាចរស់រានមានជីវិត ទារកនោះ អាចទទួលមត៌កដោយសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍នោះបាន[25]។ ដោយហេតុថា នៅពេលដែលទារកចាប់កំណើត ហើយរស់រានមានជីវិត ទារកនោះក្លាយជារូបវន្តបុគ្គល ដែលមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។

ផ្ទុយទៅវិញ បើទារកនៅក្នុងគភ៌នោះកើតមកហើយ ប៉ុន្តែបែរជាបាត់បង់ជីវិតទៅវិញ មានន័យថា ទារកនោះ មិនអាចក្លាយជាសន្តតិជនដែលត្រូវទទួលបានចំណែកមត៌កពីមតកជនបានទេ ព្រោះថាទារកនោះបានបាត់បង់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាពអស់ទៅហើយ[26]។

ដូចនេះហើយ ទារកនោះអាចត្រូវទទួលបានចំណែកមត៌កដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម គឺមិនគិតនាថ្ងៃដែលទារកនោះចាប់កំណើតនោះទេ។

### ២.១.២ អនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ[27]។ ទោះបីជាអនីតិជន គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏មិនមែនមានន័យថា អនីតិជនមិនអាចទទួលបន្តនូវសិទ្ធិចំពោះសន្តតិកម្មពីមតកជននោះទេ។ ជាគោលការណ៍ សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន។ ប៉ុន្តែចំពោះសកម្មភាពដែលទទួលបន្តនូវសិទ្ធិលើសន្តតិកម្មពីមតកជន ឬសកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច ក្នុងករណីដែលសន្តតិកម្មភ្ជាប់បន្ទុកធ្ងន់ធ្ងរហួសហេតុដែលធ្វើឱ្យខូចផលប្រយោជន៍របស់អនីតិជន ឬ សកម្មភាពដែល

[25] មាត្រា ៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[26] មាត្រា ៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[27] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ នោះសកម្មភាពដែលអនីតិជនបានធ្វើ មិនចាំបាច់មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ[28]។ ផ្ទុយទៅវិញ រាល់សកម្មភាពដែលទាក់ទងទៅនឹងកាតព្វកិច្ចរបស់អនីតិជន ចាំបាច់ត្រូវតែមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះជាមុនសិន។ម្យ៉ាងទៀត រាល់សកម្មភាពរបស់អនីតិជនដែលបានធ្វើទាក់ទងទៅនឹងទ្រព្យសម្បត្តិ អ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើក្នុងនាមជាតំណាងឱ្យអនីតិជនចំពោះការធ្វើសកម្មភាពទាក់ទងនឹងទ្រព្យសម្បត្តិ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ[29]។ ក្នុងករណីនេះ ប្រសិនបើអនីតិជនដែលជាកូនបានទទួលសន្តតិកម្មពីមតកជន ដែលជាសកម្មភាពឯកតោភាគី នោះសហព័ទ្ធរបស់មតកជនដែលនៅរស់ ដែលជាអ្នកមានអំណាចមេបាលើកូន ឬប្រសិនបើគ្មានសហព័ទ្ធរបស់មតកជននៅរស់ទេ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវធ្វើការយល់ព្រម ឬបោះបង់ចោលសន្តតិកម្មនោះក្នុងនាមជាតំណាងឱ្យអនីតិជន ដើម្បីការពារផលប្រយោជន៍របស់អនីតិជន[30]។

### ២.១.៣ អនីតិជនដែលទទួលបានអត្តាធីនភាព

អត្តាធីនភាព គឺជាស្ថានភាពមួយដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា ហើយមានសមត្ថភាពដូចនីតិជនដែរ[31]។ ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ឆ្នាំ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់បុគ្គលនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបាជាមុនសិន។ មួយវិញទៀត អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ ក៏ត្រូវទទួលបានអត្តាធីនភាពផងដែរ ដោយមិនចាំបាច់មានការប្រកាសពីតុលាការនោះទេ ហើយទោះបីជាភាគីនោះលែងលះគ្នាទៅវិញ ក៏អត្តាធីនភាពមិនរលត់នោះទេ[32]។ នៅពេលដែលអនីតិជនទទួលបានអត្តាធីនភាព អនីតិជននោះត្រូវបានចាត់ទុកថា បានដល់នីតិភាព[33]។ ក្នុងករណីនេះ មានន័យថា ជនដែលទទួលបានអត្តាធីនភាព ច្បាប់បានបញ្ញត្តិចាត់ទុកជននោះថា ជានីតិជន ដែលមានសមត្ថភាពទទួលនូវសិទ្ធិ និងកាតព្វកិច្ច ព្រមទាំងសមត្ថភាពធ្វើរាល់សកម្មភាពទាំងឡាយណាដែលច្បាប់បានអនុញ្ញាត។ លើសពីនេះទៅទៀត ជនដែលទទួលបានអត្តាធីនភាព ក៏អាចក្លាយជាសន្តតិជនទទួលបានចំណែក

[28] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[29] មាត្រា ១០៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[30] មាត្រា ១០៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[31] សន្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧
[32] មាត្រា ២១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
[33] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មត៌កពីមតកជន ឬមានសិទ្ធិក្នុងការបោះបង់ចោលនូវសន្តតិកម្មនោះ ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលឡើយ។

### ២.១.៤ នីតិជន

តាមន័យទូទៅ នីតិជន គឺជាបុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។ ចំណែកតាមក្រមរដ្ឋប្បវេណី នីតិជន មានន័យថា ជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ[34]។ ជាគោលការណ៍ នីតិជន មានសមត្ថភាពទទួលសិទ្ធិ ក្នុងឋានៈជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច ដែលអាចទទួលបាននូវលទ្ធកម្មមួយចំនួនដូចជា សិទ្ធិនៃកម្មសិទ្ធិ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ សិទ្ធិទទួលបាននូវសន្តតិកម្ម ជាអាទិ៍។ នីតិជន គឺជាបុគ្គលដែលមានសមត្ថភាពខាងឆន្ទៈដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ហើយមានសមត្ថភាពយល់ដឹងពេញលេញ និងអាចវិនិច្ឆ័យអំពីលទ្ធផលនៃសកម្មភាពរបស់ខ្លួន។ ម្យ៉ាងទៀត នីតិជន គឺជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពយ៉ាងពេញលេញ ពោលគឺជាបុគ្គលដែលមិនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភជាដើម។ នៅពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើម នីតិជន អាចមានសិទ្ធិក្លាយជាសន្តតិជនក្នុងការទទួលបាននូវសន្តតិកម្មពីមតកជន លើកលែងតែជននោះ គឺជាអភ័ព្វបុគ្គល ឬជនដែលត្រូវបានផ្តាច់មត៌ក ដែលមិនអាចមានសិទ្ធិទទួលបាននូវសន្តតិកម្មនោះទេ។

### ២.១.៥ ជននៅក្រោមហិតូបត្ថម្ភ

ជាទូទៅ ជននៅក្រោមហិតូបត្ថម្ភ គឺជាជនទាំងឡាយណាដែលមានសមត្ថភាពយល់ដឹងតិចតួច និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកស្មារតី [35]។ បើទោះបីជាជននៅក្រោមហិតូបត្ថម្ភ ត្រូវស្ថិតក្រោមការថែរក្សាដោយហិតូបត្ថម្ភៈក្តី ក៏មានករណីលើកលែងផងដែរ គឺសកម្មភាពទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ឬសកម្មភាពដែលច្បាប់បានអនុញ្ញាត ជននោះអាចធ្វើឡើងដោយខ្លួនឯង ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភៈនោះទេ។

ផ្ទុយទៅវិញ សកម្មភាពមួយចំនួនដែលបានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ សកម្មភាពទាំងនោះអាចលុបចោលបានដែលមានជាអាទិ៍:

- ការទទួល ឬការប្រើប្រាស់ទុន។
- ការខ្ចីទ្រព្យ ឬការធានា។
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត។

[34] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[35] មាត្រា ២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ការធ្វើសកម្មភាពបណ្តឹង។
- ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម។
- ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមត៌ក។
- ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក។
- ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ។
- ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ឆ្នាំ ចំពោះដីធ្លី លើសពី ២ឆ្នាំ ចំពោះអាគារ លើសពី ៦ខែ ចំពោះចលនវត្ថុ។
- សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ ឬហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ[36]។

ដូចដែលបានរៀបរាប់ខាងលើ ជននៅក្រោមហិតូបត្ថម្ភ មិនអាចធ្វើការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភៈបានឡើយ ទោះបីជាមានការយល់ព្រមពីជននៅក្រោមហិតូបត្ថម្ភក្តី ក៏ហិតូបត្ថម្ភកៈ នៅតែមានសិទ្ធិលុបចោលនូវសកម្មភាពនោះបាន។ ក្នុងន័យនេះ បើទោះបីជាជននៅក្រោមហិតូបត្ថម្ភ មានវិបត្តិផ្នែកស្មារតីធ្ងន់ធ្ងរក៏ដោយ ក៏នៅតែមានសិទ្ធិទទួលបានសន្តតិកម្មដូចទៅនឹងជនទូទៅផងដែរ។

### ២.១.៦ ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ សំដៅដល់ជនដែលស្ថិតនៅក្រោមស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី[37]។ ជនដែលបានទទួលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[38]។ អ្នកអាណាព្យាបាលទូទៅ ជាអ្នកមើលថែរាល់សកម្មភាពរបស់ជនក្រោមអាណាព្យាបាលទូទៅ ទាក់ទងនឹងទ្រព្យសម្បត្តិ ព្រមទាំងដើម្បីការពារផលប្រយោជន៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ។ ម្យ៉ាងទៀត ច្បាប់បានកំណត់ថា ដើម្បីចេញដីកា

[36] មាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[37] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មាត្រា ២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សម្រេចចាប់ផ្តើមអាណាព្យាបាលទូទៅ តុលាការត្រូវស្តាប់មតិយោបល់ជំនាញរបស់វេជ្ជបណ្ឌិត ឬជនផ្សេងទៀត ដែលអាចទទួលស្គាល់ថាសមរម្យអំពីស្ថានភាពស្មារតីរបស់សាមីខ្លួន [39] ។ ជននៅក្រោមអាណាព្យាបាលទូទៅ មិនខុសពីជននៅក្រោមហិតូបត្ថម្ភទេ គឺមានសិទ្ធិទទួលបានសន្តតិកម្ម និងអាចមានសិទ្ធិក្លាយជាសន្តតិជនផង ដែរ តែរាល់សកម្មភាពទាំងនោះត្រូវធ្វើដោយអ្នកអាណាព្យាបាលទូទៅ។ ក្នុងករណីសកម្មភាពនោះ ធ្វើឡើង ដោយជននៅក្រោមអាណាព្យាបាលទូទៅ នោះសកម្មភាពនោះអាចលុបចោលបាន លើកលែងតែសកម្មភាព ដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ[40]។

### ២.១.៧ ជនបរទេស

ជនបរទេស សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះ មានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង[41]។ រូបវន្តបុគ្គលជាជនបរទេស ក៏អាចក្លាយជាសន្តតិជន ឬទទួលបានមត៌កពីមតកជនផងដែរ ប៉ុន្តែមិនអាចទទួល បាននូវមត៌កជាអចលនវត្ថុបានទេ។ អចលនវត្ថុ សំដៅទៅលើ ដីធ្លី និងវត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបាន ដូចជា អាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍[42]។ មានន័យថា រាល់អចលនវត្ថុដូចជាដីធ្លីជាដើម សន្តតិជនជាជនបរទេសមិនអាចទទួលបានតាមរយៈសន្តតិកម្ម ឬអច្ច័យទានពីមតកជនបានទេ ដូចបានបក ស្រាយនៅក្នុងចំណុច ២.១ (រូបវន្តបុគ្គល)។ ប៉ុន្តែក៏មានបញ្ញត្តិពិសេសដែលបានផ្តល់សិទ្ធិខ្លះចំពោះជនបរទេស ទៅលើចំណែកសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិផងដែរ។ អគារសហកម្មសិទ្ធិ សំដៅដល់ អគារ ឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិ មានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់ មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា **ចំណែកឯកជន** និងមានចំណែកខ្លះជាលំហរួម សម្រាប់ការប្រើប្រាស់ រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា **ចំណែករួម**។ ជនបរទេស ក៏អាចមានសិទ្ធិទទួលបានចំណែកសិទ្ធិកម្ម សិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតាមរយៈសន្តតិកម្មផងដែរ ប៉ុន្តែជនបរទេសអាចមានសិទ្ធិកម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិចាប់ពីជាន់ទី ០១ ឡើងទៅ ចំណែកឯជាន់ផ្ទាល់ដី និងជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិនោះឡើយ[43]។មិនតែប៉ុណ្ណោះ សន្តតិជនឬសហសន្តតិជន ជាជនបរទេសត្រូវតែមានសញ្ជាតិខ្មែរទើបអាចទទួលបាន ឬអាចធ្វើលទ្ធកម្ម ចាត់ចែងអចលនវត្ថុនោះបាន។ ម្យ៉ាងទៀត ក្នុងករណីជនបរទេសមិនថាជាបុរស ឬស្ត្រីនោះទេ ប្រសិនបើយកប្តី ឬប្រពន្ធជាពលរដ្ឋខ្មែរដោយ

---

[39] មាត្រា ៥០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងឆ្នាំ២០១០

[40] មាត្រា ២៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[41] មាត្រា ៤ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០

[42] មាត្រា ១២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[43] មាត្រា ៦ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០

បានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះត្រាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេល ៣ឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោច រយៈពេល ១២ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា[44]។

បន្ថែមទៅលើលក្ខខណ្ឌទាំងនេះ ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចជាៈ

- មានគំនិត មារយាទ និងសីលធម៌ល្អ។
- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍។
- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ។
- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ[45]។

ជនបរទេសដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ អាចទាមទារសញ្ជាតិខ្មែរបាន ដោយត្រូវដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ[46]។

ជនបរទេសដែលទាមទារសញ្ជាតិខ្មែរ ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំ និងត្រូវបំពេញបែបបទដូចខាងក្រោមៈ

- ពាក្យទាមទារសញ្ជាតិខ្មែរចំនួន ២ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២ច្បាប់ ដោយមានបិទរូបថតទំហំ ៤cm x ៦cm
- រូបថត ត្រូវថតថ្មីចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ ៤cm x ៦cm ចំនួន ១០សន្លឹក
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន ២ច្បាប់
- លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២ច្បាប់
- ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេល ១២ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ២ច្បាប់
- ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ២ច្បាប់
- លិខិតបញ្ជាក់គំនិតមាយាទ និងសីលធម៌ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២ច្បាប់

[44] មាត្រា១១ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[45] មាត្រា១២ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[46] មាត្រា៤ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនចំនួន ១ច្បាប់
- លិខិតថ្កោលទោស មានសុពលភាព គិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ច្បាប់
- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជាចំនួន ២ ច្បាប់[47] ។

ជាគោលការណ៍ ច្បាប់ទទួលស្គាល់ថា ជនណាមានសញ្ជាតិខ្មែរ ជាប្រជាពលរដ្ឋខ្មែរ[48]។ ដូចនេះនៅពេលដែលជនបរទេសទទួលបានសញ្ជាតិខ្មែរ តាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរជនបរទេសនោះមានសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចក្នុងការទទួលបាននូវមត៌កតាមរយៈសន្តតិកម្មដូចគ្នាទៅនឹងពលរដ្ឋខ្មែរផងដែរ ទាំងចលនវត្ថុ និងអចលនវត្ថុជាដីធ្លីជាដើម។

ផ្ទុយទៅវិញ បើសន្តតិជនណាម្នាក់ឬច្រើននាក់ពុំមានសញ្ជាតិខ្មែរទេ មត៌កត្រូវបែងចែកដោយពិចារណាយ៉ាងហ្មត់ចត់។ មួយវិញទៀត ចំពោះសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និងការចាត់ចែងដីធ្លីនោះត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ដែលយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងចំណុច ៥.១ (នីតិបុគ្គលមត៌ក)។

ម្យ៉ាងទៀត បើសន្តតិជនដែលមានលំដាប់មុនគេទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬបានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីនោះត្រូវក្លាយជាមត៌ក។មានន័យថា សន្តតិជនជាជនបរទេសអាចធ្វើការប្តូរអចលនវត្ថុទៅជាសាច់ប្រាក់។ ប្រសិនបើក្នុងអំឡុងពេលនោះមិនបានធ្វើការចាត់ចែងដីធ្លីនោះទេ សន្តតិជនដែលមានលំដាប់ខ្ពស់នោះត្រូវបាត់បង់សិទ្ធិ ហើយកម្មសិទ្ធិលើដីធ្លីនោះ ត្រូវធ្លាក់ទៅលើសន្តតិជនលំដាប់បន្ទាប់ដែលមានសញ្ជាតិខ្មែរជំនួសវិញ[49]។

### ២.២ នីតិបុគ្គល

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ក៏បានអនុញ្ញាតឱ្យនីតិបុគ្គលក្លាយជាសន្តតិជនបានផងដែរ ពោលគឺសំដៅដល់នីតិបុគ្គលមូលនិធិ។ នីតិបុគ្គលមូលនិធិ ជាបណ្តុំនៃទ្រព្យសម្បត្តិវិភាគទានដែល

[47] មាត្រា៥ នៃអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[48] មាត្រា ៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨

[49] មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ត្រូវបានផ្តល់ជាឋានៈជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ចដោយឯករាជ្យ [50] ។ នៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិ ដើម្បីបង្កើតនីតិបុគ្គលមូលនិធិដោយចាត់ចែងនៅមុនពេលទទួលមរណភាព ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះនឹងក្លាយទៅជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលបានចុះបញ្ជី ឬនៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិ ដើម្បីបង្កើតនីតិបុគ្គលមូលនិធិដោយមតកសាសន៍ ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះ ត្រូវចាត់ទុកថា ក្លាយជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលមតកសាសន៍នោះបង្កើតអានុភាព[51]។ ម្យ៉ាងទៀត នីតិបុគ្គលអាចក្លាយជាសន្តតិជនក្នុងករណីដែលនីតិបុគ្គលនោះជាសន្តតិជនជំនួសឱ្យសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ដែលមានសញ្ជាតិបរទេស មានន័យថានីតិបុគ្គលអាចជាសន្តតិជនបាននៅពេលដែលសហសន្តតិជនទាំងអស់ ឬសន្តតិជនដែលមានលំដាប់មុនទាំងអស់ពុំមានសញ្ជាតិខ្មែរទេ ហើយដីធ្លីនៅក្នុងចំណោមមត៌កត្រូវក្លាយជានីតិបុគ្គល ចំណែកឯការគ្រប់គ្រង និងការចាត់ចែងដីធ្លី ត្រូវធ្វើឡើងដោយសហសន្តតិជន ឬ សន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ។

## ផ្នែកទី៣ ៖ បុគ្គលដែលគ្មានលក្ខណសម្បត្តិជាសន្តតិជន

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិទាក់ទងទៅនឹងបុគ្គលដែលមិនអាចក្លាយជាសន្តតិជន ក្នុងការទទួលចំណែកមត៌កពីមតកជនក្នុងពេលចាប់ផ្តើមសន្តតិកម្មបានឡើយដូចជា៖

### ៣.១ អភ័ព្វបុគ្គល

ជាទូទៅ អភ័ព្វបុគ្គល ជាបុគ្គលដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចក្លាយជាសន្តតិជន ឬ អច្ច័យលាភីក្នុងការទទួលយកមត៌កពីមតកជនបានឡើយ ដោយហេតុថាជននោះ៖

- ជាបុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬ គម្រាមកំហែង។
- ជាបុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ដោយផ្ទាល់ ឬ ដោយប្រយោល។
- ជាបុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនរាយការណ៍ ឬ មិនបានប្តឹង។
- ជាបុគ្គលដែលបានឱ្យមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។
- បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន[52]។

---

[50] មាត្រា៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[51] មាត្រា ១១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[52] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ក្នុងករណីនេះ បើទោះបីជាបុគ្គលនោះបានសន្មតថាជាសន្តតិជនតាមច្បាប់កំណត់ក្តី ឬ អច្ច័យលាភី ដោយកំណត់នៅក្នុងមតកសាសន៍ក្តី ជននោះក៏ត្រូវបាត់បង់សិទ្ធិរបស់ខ្លួនដោយស្វ័យប្រវត្តិ ទោះបីជាមាន ឬ គ្មានឆន្ទៈរបស់មតកជនក្តី[53]។ ម្យ៉ាងទៀត ប្រសិនបើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលបាននូវទ្រព្យសម្បត្តិតាមមតកសាសន៍ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម[54]។ ដូចនេះ បើអភ័ព្វបុគ្គលបានកាន់កាប់មត៌ក ហើយធ្វើឱ្យបាត់បង់ ឬខូចខាតនៃវត្ថុដែលបានកាន់កាប់ បុគ្គលនោះត្រូវមានករណីកិច្ចសងនូវសំណងនៃការខូចខាតទាំងស្រុង ចំពោះការបាត់បង់ ឬខូចខាតនៃវត្ថុកាន់កាប់នោះ ដែលកើតមានឡើងចាប់ពីពេលមតកជនបានទទួលមរណភាព[55]។

### ៣.២ បុគ្គលដែលត្រូវបានផ្តាច់ពីមត៌ក

ម្ចាស់បណ្តាំ អាចបង្ហាញឆន្ទៈ អំពីការផ្តាច់មត៌កពីសន្តតិជនមិនឱ្យទទួលបានសន្តតិកម្មតាមរយៈមតកសាសន៍ ឬដោយដាក់ពាក្យសុំទៅតុលាការ បើជនដែលត្រូវបានសន្មតថាជាសន្តតិជនបានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ដូចខាងក្រោម៖

- បើបានធ្វើបាបចំពោះមតកជន។
- បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។
- បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ។
- បើត្រូវបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។
- បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់[56]។

ជាក់ស្តែងនៅក្នុងករណីនេះ ប្រសិនបើសន្តតិជនជាកូនបង្កើតរបស់ខ្លួន មតកជនមិនអាចផ្តាច់មត៌កពីកូននោះតាមរយៈការកាត់កាល់បានទេ ព្រោះច្បាប់មិនទទួលស្គាល់ការកាត់កាល់កូនបង្កើតឡើយ ប៉ុន្តែមតកជនអាចផ្តាច់មត៌កពីកូននោះ តាមរយៈមតកសាសន៍ ឬដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីកូននោះបាន ដែលនឹងធ្វើការបកស្រាយនៅក្នុងចំណុច ១.១.១ (សន្តតិជនលំដាប់ទី១)។

ជាការពិតណាស់ ម្ចាស់បណ្តាំ មួយចំនួនមានការខ្វះខាតនូវសមត្ថភាពយល់ដឹង និង វិនិច្ឆ័យនូវសកម្មភាពរបស់ខ្លួនតាមផ្លូវច្បាប់ ដែលការសម្រេចចិត្តអាចប៉ះពាល់ទៅដល់សន្តតិជន និង ជនដែលមានផលប្រយោជន៍ផ្សេងទៀត ដូចនេះត្រូវមានការចូលរួមពីស្ថាប័នតុលាការ ក្នុងការសម្រេចសេចក្តីពីមូលហេតុនៃការសុំ

[53] សេចក្តីកំណត់ចំពោះមាត្រា១១៥០ នៃក្រមរដ្ឋប្បវេណី ភាគ៦

[54] មាត្រា ១១៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[55] សេចក្តីកំណត់ចំពោះមាត្រា១១៥៣ នៃក្រមរដ្ឋប្បវេណី ភាគ៦

[56] មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ផ្ដាច់មត៌កពីសន្តតិជននោះ។ គួរបញ្ជាក់ផងដែរថា សន្តតិជនដែរត្រូវបានផ្ដាច់មត៌ក អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការផ្ដាច់មត៌កនេះ នៅក្នុងនីតិវិធីនៃការសម្រេចសេចក្ដីដោយតុលាការបានផងដែរ [57] ។ ផ្ទុយមកវិញ មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការឱ្យលុបចោលនូវការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន[58]។

ដូចនេះ ទោះបីជាមតកជន កាលនៅរស់បានដាក់ពាក្យសុំឱ្យផ្ដាច់មត៌ក ពីជនដែលត្រូវបានសន្មតថាជាសន្តតិជន ហើយតុលាការបានទទួលស្គាល់នូវការផ្ដាច់មត៌កនោះហើយក៏ដោយ ក៏អាចសុំឱ្យលុបចោលវិញនូវការផ្ដាច់មត៌កនោះបានដែរ ដោយតុលាការគ្រាន់តែធ្វើការវិនិច្ឆ័យ អំពីការសុំលុបចោលនូវការផ្ដាច់មត៌កនោះ ពិតជាកើតចេញពីឆន្ទៈពិតប្រាកដរបស់អ្នកដាក់ពាក្យសុំ ជាការគ្រប់គ្រាន់ហើយ[59]។

[57] សេចក្តីកំណត់ចំពោះមាត្រា១១៥១ នៃក្រមរដ្ឋប្បវេណី ភាគ៦

[58] មាត្រា ១១៥៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[59] សេចក្តីកំណត់ចំពោះមាត្រា១១៥៤ នៃក្រមរដ្ឋប្បវេណី ភាគ៦

# ជំពូកទី២
# លំដាប់សន្តតិជន និង
# ការសម្រួលចំណែកមត៌ក

# ជំពូកទី២
# លំដាប់សន្តតិជន និងការសម្រួលចំណែកមត៌ក

## ផ្នែកទី១ ៖ លំដាប់សន្តតិជន

ដូចយើងខ្ញុំបានបកស្រាយនៅក្នុងផ្នែកទី២ នៃជំពូកទី១(បុគ្គលដែលអាចក្លាយជាសន្តតិជន) សន្តតិជន គឺជាជនដែលទទួលបន្តនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម ព្រមទាំងជាបុគ្គលដែលច្បាប់មិនបានចាត់ទុកថា ជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្តាច់មត៌ក។

សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជន នៅលំនៅឋានរបស់មតកជននាពេលទទួលមរណភាព ហើយសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចទាំងអស់របស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម។សន្តតិកម្ម ផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់[60]។មានន័យថា សន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរទ្រព្យសម្បត្តិទាំងឡាយរបស់បុគ្គលដែលបានទទួលមរណភាព ទៅឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ដោយមិនបានបន្សល់ទុកលិខិតបណ្តាំ ហើយរាល់ការបែងចែកមត៌ក គឺត្រូវអនុវត្តទៅតាមច្បាប់កំណត់ដោយមិនពិចារណាទៅលើឆន្ទៈរបស់មតកជនកាលពីរស់នៅនោះទេ។

ជាទូទៅសន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចរបស់មតកជនដែលទទួលមរណភាព ឬបាត់ខ្លួន ទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ ហើយលំដាប់នៃសន្តតិជនដែលជាឋានានុក្រម គឺបង្ហាញអំពីសិទ្ធិក្នុងការទទួលបាននូវមត៌ករបស់មតកជន។

នៅពេលដែលមតកជន មិនបានបន្សល់ទុកនូវលិខិតបណ្តាំ ដែលកំណត់អំពីខ្លឹមសារនៃការបែងចែកទ្រព្យសម្បត្តិទៅឱ្យបុគ្គលណាម្នាក់បែបនេះ ច្បាប់បានកំណត់អំពីបុគ្គលដែលមានសិទ្ធិទទួលបន្តនូវទ្រព្យសម្បត្តិទាំងនោះពីមតកជន ដែលយើងខ្ញុំនឹងធ្វើការបកស្រាយដូចខាងក្រោម។

### ១.១ លំដាប់នៃសន្តតិជន

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាយើង គេបានបែងចែកសន្តតិជនជា ៣ លំដាប់ ដែលសុទ្ធតែជាសាខាញាតិរបស់មតកជន ដែលនឹងបកស្រាយនៅក្នុងចំណុច ១.១.១ (សន្តតិជនលំដាប់ទី១) ចំណុច ១.១.២ (សន្តតិជនលំដាប់ទី២) និងចំណុច ១.១.៣ (សន្តតិជនលំដាប់ទី៣)។ មិនតែប៉ុណ្ណោះ យើងនឹងសិក្សាទៅលើករណីពិសេសមួយចំនួនដែលនឹងបកស្រាយនៅក្នុងចំណុច ១.១.៤ (សន្តតិជនជំនួស) និងចំណុច ១.១.៥ (សន្តតិជនជានិច្ច)។

[60] មាត្រា ១១៤៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.១.១ សន្តតិជនលំដាប់ទី១

ជាទូទៅ សន្តតិជនលំដាប់ទី១ គឺសំដៅដល់កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ដែលត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា[61]។ កូនដែលត្រូវបានកំណត់ថាជាកូនបង្កើត លុះត្រាតែកូននោះកើតមកពីឪពុកម្តាយ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និង លុះត្រាតែម្តាយនៃកូននោះមានគត៌ក្នុងរយៈពេលដែលឪពុកម្តាយនៅជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា ដែលរយៈពេលនេះ ត្រូវបានកំណត់នៅក្នុងមាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារឹកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថារួមសមគ្គសង្វាសជាមួយគ្នាតាមប្បញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន[62]។ ពាក់ព័ន្ធនឹងកូនបង្កើតរបស់ម្តាយ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ញត្តិដូចគ្នាទៅនឹងក្រឹត្យក្រមនៃច្បាប់ធម្មជាតិ ដែលបានបញ្ញត្តិថា ជនដែលចាត់ទុកជាម្តាយរបស់កូន លុះត្រាតែជាស្ត្រីដែលបានសម្រាលកូននោះ[63]។មានន័យថា កូនដែលកើតចេញពីផ្ទៃម្តាយ គឺជាកូនបង្កើតរបស់ម្តាយ។ ចំពោះកូនដែលត្រូវបានសន្មតថាជាកូនរបស់ជនដែលជាឪពុក លុះត្រាតែកូននោះ ជាទារកនៅក្នុងគភ៌ប្រពន្ធដែលមាននៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ឬនៅក្នុងករណីដែលកូននោះបានកើតនៅក្នុងអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីពេលដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ ថ្ងៃ គិតចាប់ពីពេលដែលបានរំលាយ ឬ លុបចោលអាពាហ៍ពិពាហ៍ ត្រូវបានសន្មតថាមានគភ៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ[64]។ម្យ៉ាងទៀត ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបានដែរ ដោយទទួលការយល់ព្រមពីម្តាយ ព្រមទាំងត្រូវចុះហត្ថលេខាលើលិខិតទទួលស្គាល់នោះ[65]។ជាទូទៅ សំបុត្រកំណើតជាភស្តុតាងមួយយ៉ាងសំខាន់ក្នុងការបញ្ជាក់ពីទំនាក់ទំនងគតិយុត្តរវាងកូន និងឪពុកម្តាយ។

ទម្រង់នៃការទទួលស្គាល់ នឹងត្រូវធ្វើឡើងដោយការជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាន។ឪពុក ឬម្តាយរបស់កូនត្រូវសុំចុះកំណើតរបស់កូន នៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុក ឬម្តាយ ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលកូននោះកើត[66]។ ដូចនេះ បើបុគ្គលណាបានសុំចុះកំណើតរបស់កូន បានចុះឈ្មោះខ្លួនជាឪពុក ហើយបានចុះហត្ថលេខា ឬផ្តិតមេដៃ នៅក្នុងសៀវភៅកំណើត បុគ្គលនោះត្រូវបានចាត់ទុកថា បានទទួលស្គាល់កូននោះ នៅពេលដែលបានសុំចុះកំណើត[67]។

---

[61] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[62] មាត្រា៣ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦

[63] មាត្រា ៩៨៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[64] មាត្រា ៩៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[65] មាត្រា ៩៩៥ កថាខណ្ឌទី២ និងមាត្រា ៩៩៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[66] មាត្រា ៩៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[67] មាត្រា ៩៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដោយឡែក ចំពោះកូនសុំ ឬ ដែលត្រូវបានហៅតាមភាសាច្បាប់ថា ស្មុំកូន វិញ ត្បិតតែពុំមានទំនាក់ទំនងញាតិលោហិតជាមួយនឹងឪពុកម្ដាយចិញ្ចឹមក៏ដោយ ក៏កូនសុំ មានករណីកិច្ច និងមានសិទ្ធិអាចក្លាយជាសន្តតិជនក្នុងការទទួលបានសន្តតិកម្មដូចកូនបង្កើតផងដែរ។ នៅក្នុងរបបស្មុំកូននេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់របបស្មុំកូនជា ២ទម្រង់ គឺ ស្មុំកូនពេញលេញ និងស្មុំកូនធម្មតា ដែលយើងខ្ញុំនឹងធ្វើការបកស្រាយដូចខាងក្រោម។

ចំពោះកូនសុំ តាមរយៈស្មុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នាទៅនឹងញាតិភាពតាមផ្លូវច្បាប់នឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹម [68] ។ ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ដោយស្មុំកូនពេញលេញ[69]។ ដូចនេះ កូនសុំនោះ មិនអាចទទួលបានចំណែកមត៌កពីឪពុកម្ដាយបង្កើតបាននោះទេ គឺបានត្រឹមតែទទួលសន្តតិកម្មពីឪពុកម្ដាយចិញ្ចឹមប៉ុណ្ណោះ។ ផ្ទុយទៅវិញ ក្នុងករណីមានការកាត់កាល់ស្មុំកូនពេញលេញ នោះញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស្មុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់[70]។ដូចនេះ នៅពេលដែលសន្តតិកម្មកើតឡើង កូនសុំនោះ នៅតែមានសិទ្ធិទទួលបន្តសន្តតិកម្មឡើងវិញពីឪពុកម្ដាយបង្កើតបាន គិតចាប់ពីថ្ងៃកាត់កាល់ស្មុំកូនពេញលេញ។ ចំណែកឯ ស្មុំកូនធម្មតាវិញ បើទោះបីជាការបង្កើតស្មុំកូនធម្មតាក៏ដោយញាតិភាពរវាងកូនសុំនិងឪពុកម្ដាយបង្កើតត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក[71]។ មិនតែប៉ុណ្ណោះ ការបង្កើតស្មុំកូនធម្មតា កូនសុំក៏ត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និងត្រូវទទួលបាននូវសិទ្ធិកាតព្វកិច្ច និងករណីកិច្ចដូចគ្នាទៅនឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹមផងដែរ [72] ។ ពោលគឺកូនសុំធម្មតា អាចទទួលសន្តតិកម្មពីឪពុកម្ដាយបង្កើតផង និងឪពុកម្ដាយចិញ្ចឹមផង។

ផ្ទុយទៅវិញ បើទោះបីជាកូនដែលជាសន្តតិជនលំដាប់ទី១ មានអាទិភាពខ្ពស់ក្នុងការទទួលបាននូវចំណែកមត៌កតាមរយៈសន្តតិកម្មក៏ដោយ ប្រសិនបើមតកជនបានធ្វើការកាត់ផ្ដាច់នូវផលប្រយោជន៍របស់កូនតាមរយៈលិខិតបណ្ដាំមត៌កដោយមានបញ្ជាក់ពីមូលហេតុដូចបានបកស្រាយនៅក្នុងចំណុច ៣.១ (អភ័ព្វបុគ្គល) និងតាមរយៈការកាត់ផ្ដាច់នូវមត៌កដោយការដាក់ពាក្យសុំទៅតុលាការ ដូចបានបកស្រាយនៅក្នុងចំណុច ៣.២ (បុគ្គលដែលត្រូវបានផ្ដាច់ពីមត៌ក) កូននោះ ពុំអាចក្លាយជាសន្តតិជនក្នុងការទទួលបានចំណែកមត៌កតាមរយៈសន្តតិកម្មនោះបានឡើយ។ ម៉្យាងវិញទៀត ប្រសិនបើកូនរបស់មតកជនបានទទួលមរណភាពនៅមុន ឬព្រមគ្នា

[68] មាត្រា ១០១៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[69] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[70] មាត្រា ១០១៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[71] មាត្រា ១០២៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[72] មាត្រា ១០២៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បាត់បង់សិទ្ធិសន្តតិកម្ម ដោយមូលហេតុដូចបានបកស្រាយនៅក្នុងចំណុច ៣.១ (អភ័ព្វបុគ្គល) និងចំណុច ៣.២ (បុគ្គលដែលត្រូវបានផ្តាច់ពីមត៌ក) របស្តីពីសន្តតិកម្មជំនួសនឹងត្រូវបានយកមកអនុវត្ត។

### ១.១.២ សន្តតិជនលំដាប់ទី២

ជាទូទៅ នៅពេលដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ ដែលនឹងត្រូវក្លាយជាសន្តតិជនលំដាប់ទី១ ទេ បុព្វញាតិផ្ទាល់របស់មតកជននឹងក្លាយជាសន្តតិជនលំដាប់ទី២[73]។ បុព្វញាតិ សំដៅទៅលើជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន[74]។ យោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានកំណត់ថា អ្នកដែលជាបុព្វញាតិដែលមានលំដាប់ថ្នាក់ជិតជាងគេទៅនឹងមតកជន ជាអ្នកដែលមានអាទិភាពទទួលបានចំណែកមត៌ក ដែលឪពុកម្តាយរបស់មតកជននឹងក្លាយទៅជាសន្តតិជនលំដាប់ទី២។ គេបានកំណត់យកបុព្វញាតិផ្ទាល់ដែលជាឪពុកម្តាយ ឬជីដូនជីតារបស់មតកជនជាសន្តតិជនលំដាប់ទី២ ដោយគេគិតថា អ្នកទាំងនោះ គឺជាអ្នកដែលទទួលបានការគោរពពីមតកជន និងជាអ្នកបានមើលថែទាំមតកជន ជាកូន ឬចៅ។ ឪពុកម្តាយរបស់មតកជនដែលក្លាយជាសន្តតិជននោះត្រូវទទួលទ្រព្យសម្បត្តិស្មើៗគ្នា តែប្រសិនបើមតកជនមានតែឪពុក ឬ ម្តាយតែម្ខាងដែលនៅរស់ នោះគាត់នឹងទទួលបានមត៌កតែម្នាក់ឯង។ ក្នុងករណីឪពុកម្តាយរបស់មតកជនទទួលមរណភាពមុនមតកជននោះ ជីដូនជីតារបស់មតកជន នឹងត្រូវក្លាយជាសន្តតិជន ហើយទទួលសន្តតិកម្មបន្តពីមតកជន។ ប្រសិនបើបុព្វញាតិមានចំនួនច្រើននាក់ សន្តតិជននីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ទាំងទ្រព្យសកម្ម និងទ្រព្យអកម្មដែលមាន[75]។

### ១.១.៣ សន្តតិជនលំដាប់ទី៣

នៅពេលដែលមតកជនមិនមានទាំងបច្ឆាញាតិ មិនមានទាំងបុព្វញាតិ ដែលនឹងត្រូវក្លាយជាសន្តតិជនស្នងមត៌កនោះទេ នោះបងប្អូនបង្កើតរបស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី៣[76]។ បើទោះបីជាមតកជនមានបងប្អូនបង្កើតប៉ុន្មាននាក់ក៏ដោយ ក៏ចំណែកនៃមត៌កត្រូវទទួលបានស្មើៗគ្នាជានិច្ច។ តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ទៅនឹងមតកជន អាចទទួលបានតែ ១ ភាគ ២ នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុកនិងម្តាយទាំងសងខាងដូចគ្នា[77]។

[73] មាត្រា ១១៥៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[74] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[75] មាត្រា ១១៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[76] មាត្រា ១១៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[77] មាត្រា១១៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.១.៤ សន្តតិជនជំនួស

ក្នុងករណីកូនរបស់មតកជនបានស្លាប់មុន ឬ ស្របពេលគ្នានឹងការចាប់ផ្ដើមសន្តតិកម្ម នោះកូនរបស់សន្តតិជនដែលត្រូវជាចៅរបស់មតកជននោះនឹងក្លាយជាសន្តតិជនជំនួស[78]។ ករណីនេះក៏ត្រូវបានយកមកអនុវត្តផងដែរ ប្រសិនបើកូនរបស់មតកជនបានបាត់បង់សិទ្ធិជាសន្តតិជន ដោយមូលហេតុជាអភ័ព្វបុគ្គល ឬត្រូវបានផ្ដាច់មត៌ក[79]។ប៉ុន្តែប្រសិនបើកូនរបស់មតកជនបានទទួលមរណភាពក្រោយពេលចាប់ផ្ដើមសន្តតិកម្ម មានន័យថាជននោះបានទទួលសន្តតិកម្មពីមតកជនរួចហើយ នោះកូនរបស់ជននោះមានសិទ្ធិក្លាយជាសន្តតិជនបន្តទៀតដោយមរណភាពរបស់ជននោះតែម្ដង[80]។

ម្យ៉ាងវិញទៀត ក្នុងករណីកូនរបស់មតកជនជាកូនសុំតាមរបបសុំកូនធម្មតា បានធ្វើឡើងមុនពេលកូនសុំមានកូន នៅពេលកូនសុំស្លាប់មុនមតកជន កូនរបស់កូនសុំ(ចៅរបស់មតកជន) អាចទទួលបន្តមត៌កត្រឹមរូបភាពជាសន្តតិកម្មជំនួស ប៉ុន្តែបើកូនសុំនោះមានកូនមុនពេលភ្ជាប់ទំនាក់ទំនងជាកូនសុំរបស់មតកជន នោះកូនរបស់កូនសុំនៃមតកជន មិនអាចអនុវត្តសិទ្ធិសន្តតិកម្មជំនួសបានទេ ព្រោះកូននោះមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន[81]។

លើសពីនេះ ប្រសិនបើជនដែលក្លាយជាសន្តតិជនជំនួស បានជួបមូលហេតុដូចគ្នាទៅនឹងសន្តតិជនដែលនាំឱ្យកូនរបស់សន្តតិជនជំនួសនឹងក្លាយជាសន្តតិជនជំនួសបន្តទៀត ដែលត្រូវទទួលមត៌កពីមតកជនជាបន្តបន្ទាប់គ្នា។

ការអនុវត្តសន្តតិកម្មជំនួស គឺអាចធ្វើទៅបន្តបន្ទាប់បាន សម្រាប់តែបច្ឆាញាតិផ្ទាល់របស់មតកជនប្រសិនបើមានហេតុផលដូចមានកំណត់ខាងលើ ដូចជាករណី ប្រសិនបើចៅរបស់មតកជនបានស្លាប់ ចៅទួតនឹងទទួលសន្តតិកម្មជំនួសវិញ[82]។

ចំណែកមត៌កនៃសន្តតិកម្មជំនួស ត្រូវទទួលបានដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន និងប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួននោះត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយនោះ[83]។ សន្តតិកម្មជំនួស មិនអនុវត្តចំពោះសន្តតិជនលំដាប់ទី២(បុព្វញាតិផ្ទាល់របស់មតកជន)នោះទេ ដោយហេតុថាៈ

[78] មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[79] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[80] មាត្រា ១១៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[81] មាត្រា ១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[82] មាត្រា ១១៥៧ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[83] មាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ទី១ បុព្វញាតិផ្ទាល់មានសិទ្ធិទទួលសន្តតិកម្ម នៅពេលមតកជនគ្មានកូន
- ទី២ បើគ្មានបុព្វញាតិផ្ទាល់ គឺត្រូវបន្តទៅសន្តតិជនលំដាប់ទី៣ (បងប្អូនបង្កើត)។

សន្តតិកម្មជំនួស អាចអនុវត្តចំពោះសន្តតិជនលំដាប់ទី៣ ប៉ុន្តែទទួលស្គាល់តែមួយតំណប៉ុណ្ណោះ មិនអាចអនុវត្តជាបន្តបន្ទាប់បានទេ ពោលគឺក្មួយរបស់មតកជនអាចក្លាយជាសន្តតិជនជំនួសបាន។

បើក្រឡេកទៅមើលក្នុងករណីសន្តតិជនលំដាប់ទី២វិញដែលបុព្វញាតិផ្ទាល់ត្រូវបានទទួលនូវមត៌កនោះច្បាប់មិនបានទទួលស្គាល់នូវសន្តតិកម្មជំនួសឡើយ ដោយហេតុថា កូនរបស់សន្តតិជនគឺត្រូវជាបងប្អូនរបស់មតកជនរួចទៅហើយ ដែលជាសន្តតិជនលំដាប់ទី៣ តាមច្បាប់។

ជាទូទៅ ចំណែកមត៌ករបស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនជំនួស ត្រូវទទួលបានស្មើៗគ្នាទៅនឹងចំណែកដែលបុព្វញាតិផ្ទាល់ទទួលបាន ប៉ុន្តែប្រសិនបើបច្ឆាញាតិផ្ទាល់ដែលក្លាយជាសន្តតិជនជំនួសមានចំនួនច្រើននាក់ ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិនីមួយៗ ធៀបទៅនឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់នៃបច្ឆាញាតិនីមួយៗនោះទទួលបាន។

បន្ទាប់ពីធ្វើការពន្យល់បកស្រាយចំពោះសន្តតិជនតាមញាតិលោហិតទាំង ៣លំដាប់ រួមទាំងបុគ្គលដែលត្រូវក្លាយជាសន្តតិជនជំនួសរួចមក នៅមានសន្តតិជនពិសេសមួយប្រភេទទៀតដែរគឺ សន្តតិជនជានិច្ច ឬអាចហៅម្យ៉ាងទៀតបានថា សហព័ទ្ធរបស់មតកជន ដែលយើងខ្ញុំនឹងលើកមកធ្វើការពន្យល់បកស្រាយនៅក្នុងចំណុច ១.១.៥ (សន្តតិជនជានិច្ច) ដូចខាងក្រោម។

### ១.១.៥ សន្តតិជនជានិច្ច

សហព័ទ្ធ សំដៅទៅលើប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ទ្ធនេះ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់[84]។ នៅពេលដែលសន្តតិកម្មចាប់ផ្តើមកើតឡើង សហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជនជានិច្ច។នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច បើមានបុគ្គលផ្សេងទៀត ក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ[85]។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានផ្តល់សិទ្ធិពិសេសដល់សហព័ទ្ធ គឺសិទ្ធិជាសន្តតិជនជាអចិន្ត្រៃយ៍ មានន័យថា នៅក្នុងចំណោមសន្តតិជនទាំង ៣ លំដាប់ ទោះបីជាមានសន្តតិជនលំដាប់ណាមួយ ក៏មានចំណែកមត៌ករបស់សហព័ទ្ធនៅក្នុងនោះដែរ[86]។ពាក្យថា ជានិច្ច នៅក្នុងន័យនេះ មានន័យថាគ្មានពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេង ព្រមទាំងលំដាប់សន្តតិកម្មទេ។

---

[84] សន្ទានុក្រមផ្នែករដ្ឋប្បវេណី

[85] មាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[86] កម្មវិធីយល់ដឹងអំពីច្បាប់ និងជំនួញ ប្រធានបទ ច្បាប់ប្រគល់មត៌ក របស់វិទ្យុបារាំង RFI បកស្រាយដោយលោក សេង ឌីណា

ម្យ៉ាងទៀត ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ[87]។ ក៏ប៉ុន្តែ ទោះបីជាសហព័ទ្ធរបស់មតកជនក៏ដោយ ក្នុងករណីដែលសហព័ទ្ធនោះ ជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ដូចបានបកស្រាយនៅក្នុងចំណុច ៣.១ (អភ័ព្វបុគ្គល) ឬជាបុគ្គលដែលត្រូវបានផ្ដាច់ពីសន្តតិកម្ម ដូចបានបកស្រាយនៅក្នុងចំណុច ៣.២ (បុគ្គលដែលត្រូវបានផ្ដាច់ពីមត៌ក) ជននោះមិនអាចទទួលសន្តតិកម្មបានឡើយ[88]។

### ១.២ ចំណែកមត៌កតាមច្បាប់

ក្រោយពីមតកជនបានទទួលមរណភាព ឬ ការប្រកាសអំពីការបាត់ខ្លួនក្នុងអំឡុងពេលណាមួយដែលច្បាប់បានកំណត់ ដូចបានបកស្រាយនៅក្នុងចំណុច ១.១ (មូលហេតុនៃការចាប់ផ្ដើមសន្តតិកម្ម) ដោយមិនមានបន្សល់ទុកនូវមតកសាសន៍ ឬលិខិតបណ្ដាំ មត៌កដែលបន្សល់ទុកនោះ ត្រូវធ្វើការបែងចែកតាមការកំណត់ដោយច្បាប់។

យើងអាចយល់ជាទូទៅបានថា ចំណែកមត៌កតាមច្បាប់ គឺជាផ្នែកមួយនៃមត៌កដែលជនត្រូវបានសន្មតថាជាសន្តតិជន ត្រូវទទួលបានតាមបញ្ញត្តិរបស់ច្បាប់ ចំពោះមត៌កដែលមតកជនមាន។ សន្តតិជនអាចមានចំនួនច្រើន ហៅថា សហសន្តតិជន ហើយចំណែកមត៌ករបស់សហសន្តតិជនទាំងនោះ ពុំមានលក្ខណៈស្មើៗគ្នាឡើយ អាស្រ័យលើទំនាក់ទំនងញាតិដែលមតកជនមាន។ ចំណែកមត៌កតាមច្បាប់ ជាវិធីមួយដែលត្រូវបានយកមកអនុវត្ត នៅពេលដែលសហសន្តតិជនធ្វើការពិភាក្សាបែងចែកមត៌កក្រៅប្រព័ន្ធតុលាការ ដូចបានកំណត់នៅក្នុងមាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ហើយក៏ត្រូវយកមកអនុវត្តផងដែរនៅតុលាការ តាមរយៈបណ្ដឹងរបស់សន្តតិជនណាម្នាក់ ដែលមិនយល់ព្រមលើការបែងចែកមត៌កតាមរយៈការពិភាក្សាបែងចែកមត៌កនោះ ដូចបានកំណត់នៅក្នុងមាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧[89]។ ដូចនេះហើយ ទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់អំពីលំដាប់នៃសន្តតិជន និងធ្វើការបែងចែកចំណែកមត៌កចំពោះសន្តតិជន ដើម្បីឱ្យមានសមភាពរវាងជនដែលមានលក្ខណសម្បត្តិជាសន្តតិជន។

[87] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[88] សេចក្ដីកំណត់ចំពោះមាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[89] សៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ទំព័រទី៣៨

### ១.២.១ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី១

កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា[90]។

ឧទាហរណ៍ៈ មតកជនA មានកូនចំនួនបីនាក់ គឺ B C និង D ព្រមទាំងបានបន្សល់ទុកទ្រព្យចំនួន ១២000$ ។

តាង X ជាចំណែកមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួលបាន

តាង P ជាចំនួនទ្រព្យសរុបស្មើ ១២000$

តាង Q ជាចំនួនសន្តតិជនស្មើ ៣

នាំឱ្យ X = P ÷ Q

= ១២000$ ÷ ៣

X = ៤000$

ដូចនេះ ចំណែកមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួលបានគឺៈ

A ទទួលបាន ៤000$

B ទទួលបាន ៤000$

C ទទួលបាន ៤000$

### ១.២.២ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី២

ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វញាតិផ្ទាល់នីមួយៗ ត្រូវទទួលចំណែកមត៌កស្មើៗគ្នា[91]។

ឧទាហរណ៍ៈ មតកជន A មានតែឪពុកម្តាយ ព្រមទាំងបានបន្សល់ទុកទ្រព្យចំនួន ៥0000$ ។

តាង X ជាចំណែកមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួលបាន

តាង P ជាចំនួនទ្រព្យសរុបស្មើ ៥0000$

តាង Q ជាចំនួនសន្តតិជនស្មើ ២

នាំឱ្យ X = P ÷ Q

= ៥0000$ ÷ ២

X = ២៥000$

ដូចនេះ ចំណែកមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួលបានគឺៈ ២៥000$

[90] មាត្រា ១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[91] មាត្រា ១១៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.២.៣ ចំណែកមត៌កនៃសន្តតិជនលំដាប់ទី៣

ប្រសិនបើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា។ ប៉ុន្តែចំណែកមត៌ករបស់បងប្អូនដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា[92]។

ឧទាហរណ៍ៈ លោក A ជាមតកជនដែលទទួលមរណភាពដោយគ្មានប្រពន្ធ គ្មានកូន ហើយឪពុកម្តាយរបស់គាត់បានទទួលមរណភាពទៅដូចគ្នា។ A មានបងប្អូនបង្កើត ២ នាក់គឺ B និង C ប៉ុន្តែកាលឪពុក A នៅរស់មានកូនផ្សេងម្នាក់ទៀតឈ្មោះ D ដែលមានម្តាយខុសគ្នា។ ក្រោយទទួលមរណភាព លោក A បានបន្សល់ទុកនៅទ្រព្យចំនួន ៩០០០០$។

តាង P ជាចំនួនទ្រព្យសរុបស្មើ ៩០០០០$

ដោយ P = B + C + D (១)

ហើយចំណែក B = C

នាំឱ្យ P = ២C + D (២)

ដោយដឹងថា ចំណែកមត៌ករបស់ D ស្មើនឹងពាក់កណ្តាលនៃចំណែកមត៌ករបស់ B និង C

នោះ D = ១/២B = ១/២C

នាំឱ្យ P = ២C + ១/២C

P = C (២ + ១/២)

P = ២.៥C

នាំឱ្យ C = P ÷ ២.៥

C = ៩០០០០$ ÷ ២.៥

C = ៣៦០០០$

ដោយចំណែក B = C

នាំឱ្យ B = ៣៦០០០$

ដោយ D = ១/២C

នាំឱ្យ D = ៣៦០០០$ x ១/២

D = ១៨០០០$

ដូចនេះ ចំណែកមត៌កដែលសន្តតិជនម្នាក់ៗត្រូវទទួលបានគឺៈ

[92] មាត្រា ១១៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

D ទទួលបាន ១៨០០០$

B ទទួលបាន ៣៦០០០$

C ទទួលបាន ៣៦០០០$

### ១.២.៤ ចំណែកមត៌កនៃសន្តតិជនជំនួស

ប្រសិនបើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបានបាត់បង់សិទ្ធិសន្តតិកម្ម ដោយមូលហេតុដូចបានបកស្រាយក្នុងចំណុច ៣.១ (អភ័ព្វបុគ្គល) និងចំណុច ៣.២ (បុគ្គលដែលត្រូវបានផ្តាច់មត៌ក) នោះចំណែកមត៌ក ត្រូវធ្លាក់ទៅលើកូនរបស់បុគ្គលនោះ (ចៅរបស់មតកជន) តាមរយៈសន្តតិកម្មជំនួស[93]។

ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់ត្រូវទទួលបាន ហើយប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយនោះចំពោះចំណែកមត៌កដែលបុព្វញាតិផ្ទាល់នៃបច្ឆាញាតិនីមួយៗនោះត្រូវទទួលបាន[94]។

ឧទាហរណ៍ មតកជន A គ្មានកូន គ្មានឪពុកម្តាយ គ្មានសហព័ទ្ធ ប៉ុន្តែមានបងប្អូនបង្កើត ៣ នាក់ ឈ្មោះ B C D ប៉ុន្តែ B បានស្លាប់មុន A ។ B មានកូន ២នាក់ ឈ្មោះ(B១) និង (B២)។ (B១) និង (B២) នឹងទទួលសន្តតិកម្មជំនួសត្រឹមចំណែកដែល B មានសិទ្ធិទទួល ប៉ុន្តែបើ B និង (B១,B២) បានទទួលមរណភាពមុន A នោះកូនរបស់ (B១) និង (B២) មិនអាចទទួលសន្តតិកម្មជំនួសបាននោះទេ។

### ១.២.៥ ចំណែកមត៌កនៃសន្តតិជនជានិច្ច

ដូចបានបកស្រាយក្នុងចំណុច ១.១.៥ (សន្តតិជនជានិច្ច) សហព័ទ្ធជាសន្តតិជនជានិច្ច ហើយត្រូវមានលំដាប់ស្មើនឹងសន្តតិជនផ្សេងទៀត ប៉ុន្តែប្រសិនបើមានតែសហព័ទ្ធតែម្នាក់ឯង នោះចំណែកមត៌កទាំងអស់ត្រូវធ្លាក់ទៅលើសហព័ទ្ធទាំងស្រុង។

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជននឹងត្រូវមានកំណត់ដូចខាងក្រោម :

- បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់របស់មតកជននោះជាសន្តតិជន សហព័ទ្ធនិងកូននីមួយៗរបស់មតកជននោះនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា។

---

[93] មាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[94] សេចក្តីកំណត់ចំពោះមាត្រា ១១៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- បើសហព័ទ្ធ និងឪពុកម្តាយរបស់មតកជនជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ភាគ៣ ឯចំណែកមត៌ករបស់ឪពុកម្តាយត្រូវជា២ភាគ៣។ ប៉ុន្តែ បើឪពុក ឬម្តាយរបស់មតកជនតែម្នាក់នៅរស់ ឪពុក ឬម្តាយនោះនិងសហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា។
- បើសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធត្រូវជា ១ភាគ២ ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុកម្តាយរបស់មតកជនឬបងប្អូនបង្កើតរបស់មតកជន ឬអ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ភាគ២[95]។

  ឧទាហរណ៍ មតកជន **ក** មានសហព័ទ្ធ **ខ** និងមានបងប្អូនបង្កើតឪពុកម្តាយរួមគ្នា A B និង C ហើយមានបងប្អូនបង្កើតរួមតែឪពុកចំនួន ២នាក់ គឺ M និង N និងមានបងប្អូនបង្កើតរួមតែម្តាយចំនួន ២នាក់ គឺ Y និង Z ។ នៅពេលចាប់ផ្តើមសន្តតិកម្ម សហព័ទ្ធ **ខ** ទទួលបាន ១/២ នៃចំណែកមត៌កសរុប។ ចំណែកដែលនៅសល់គឺ ១/២ ត្រូវបែងចែកទៅឱ្យបងប្អូនរបស់មតកជននោះ ដោយធ្វើការបែងចែកដូចខាងក្រោម៖

- ចំណែកមត៌កដែលនៅសល់សរុប ១/២ ត្រូវបែងចែកទៅបងប្អូនបង្កើតដែលមានឪពុកម្តាយរួមស្មើៗគ្នា និងបែងចែកទៅបងប្អូនបង្កើតដែលមានតែឪពុក ឬម្តាយតែម្ខាង ពាក់កណ្តាលនៃចំណែករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយរួមគ្នា។
- តាង X ជាចំណែកសន្តតិជននីមួយៗ៖

  ចំណែកមត៌កនៅសល់សរុប ១/២ = A + B + C + M + N + Y +Z
- ដោយ M N Y និង Z មានឪពុក ឬម្តាយរួមតែម្ខាង នោះចំណែកមត៌កត្រូវទទួលបានពាក់កណ្តាលនៃ A B និង C

  ដោយ M = N = Y = Z = ១/២ (A) =១/២ (B) = ១/២ (C)

  គេបាន ១/២ = X + X + X + ១/២ X + ១/២ X + ១/២ X + ១/២ X

នាំឱ្យ ១/២ = ៥X

X = ១/១០

ដូចនេះ ពួកគេម្នាក់ៗទទួលបានចំណែកមត៌កដូចខាងក្រោម៖

- ចំណែកមត៌ករបស់បងប្អូនបង្កើតឪពុកម្តាយរួម A B និង C ទទួលបាន ១/១០ នៃចំណែកមត៌កសរុប។
- ចំណែកមត៌ករបស់បងប្អូនរួមតែឪពុក M និង N គឺ ១/១០ ចែកនឹង ២ នាំឱ្យម្នាក់ៗទទួលបាន១/២០ ។

[95] មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- ចំណែកមត៌ករបស់បងប្អូនរួមតែម្ដាយ Y និង Z គឺ ១/១០ ចែកនឹង ២ នាំឱ្យម្នាក់ៗទទួលបាន១/២០ ។

គំនូសតាង៖




## ផ្នែកទី២ ៖ ការសម្រួលចំណែកមត៌ក

ការសម្រួលចំណែកមត៌ក ក្នុងករណីមានអ្នកទទួលបានផលប្រយោជន៍ពិសេស នៅក្នុងចំណោមសហសន្តតិជននៅពេលដែលមតកជននៅរស់ ដើម្បីឱ្យមានសមភាពជាក់ស្ដែងរវាងសហសន្តតិជន។ ផលប្រយោជន៍ពិសេស គឺជាផលប្រយោជន៍ដែលបុគ្គលណាបានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន។ ការសម្រួលចំណែកមត៌ក គឺជាវិធីមួយដែលយើងអាចដឹងពីចំណែកមត៌ករបស់សហសន្តតិជនទាំងអស់ ក្នុងករណីដែលក្នុងចំណោមសហសន្តតិជនទាំងនោះ មានសន្តតិជនដែលទទួលបានផលប្រយោជន៍ពិសេស។

ជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើមានជនដែលទទួលផលប្រយោជន៍ពិសេស ហើយយើងយកចំណែកមត៌កជាក់ស្ដែង ជាកម្មវត្ថុនៃចំណែកនោះទៅសន្តតិជនទាំងអស់ ដោយមិនសម្រួលចំណែកមត៌ករបស់ជនដែលមានផលប្រយោជន៍ពិសេស នាំឱ្យមានការបំពាននូវខ្លឹម

សារថា សន្តតិជនទាំងអស់ត្រូវមានចំណែកស្មើៗគ្នា។ ដោយឡែក នៅពេលមានភាគនៃវិភាគទាន ដែលជាស្ថានភាពនៃការចំណាយទ្រព្យសម្បត្តិរបស់សហសន្តតិជនណាម្នាក់ នៅក្នុងចំណោមសហសន្តតិជនទាំងអស់ ដើម្បីបង្កើនទ្រព្យរបស់មតកជន ឬចំណាយសម្រាប់ជីវភាពរបស់មតកជន ឬចំណាយដើម្បីមើលថែទាំមតកជន វិធាននៃការសម្រួលចំណែកមត៌ក ក៏ត្រូវកើតឡើងផងដែរ ដើម្បីឱ្យមានសមភាពជាក់ស្តែង សម្រាប់សន្តតិជនដែលបានចំណាយទ្រព្យផ្ទាល់ខ្លួន[96]។

### ២.១ ករណីមានការទទួលផលប្រយោជន៍ពិសេស

ផលប្រយោជន៍ពិសេស គឺជាផលប្រយោជន៍ដែលបុគ្គលណាបានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន[97]។ ផលប្រយោជន៍ពិសេស គឺជាប្រទានកម្មពិសេស ដែលមតកជនបានផ្តល់នូវទ្រព្យណាមួយទៅឱ្យសន្តតិជន។ មិនមែនឱ្យអ្វីបន្តិចបន្តួច សម្រាប់ចាយវាយប្រចាំថ្ងៃ ជាផលប្រយោជន៍ពិសេសនោះទេ។ បើការឱ្យនោះលើសពីទំហំធម្មតា ជាផលប្រយោជន៍ពិសេស។នេះជាបញ្ហានៃការបកស្រាយ ព្រោះលក្ខណៈវិនិច្ឆ័យ ដែលចែងក្នុងមាត្រា១១៦៣ គឺមានលក្ខណៈអរូបី[98]។ លើសពីនេះទៅទៀត អច្ច័យទានដែលត្រូវបានផ្តល់ទៅឱ្យសន្តតិជនក៏ត្រូវចាត់ទុកជាផលប្រយោជន៍ពិសេសផងដែរ ប៉ុន្តែពុំរាប់បញ្ចូលដើម្បីគណនានោះទេ ព្រោះអច្ច័យទានពុំទាន់ត្រូវបានបែងចែកឱ្យទៅសន្តតិជនឡើយ នៅពេលចាប់ផ្តើមសន្តតិកម្ម ហើយប្រទានកម្មដែលជាផលប្រយោជន៍របស់តតិយជន អាចជាកម្មវត្ថុនៃការគណនាភាគបម្រុងបាន លុះត្រាតែប្រទានកម្មនោះធ្វើឡើងនៅក្នុងអំឡុងពេល ០១ឆ្នាំ មុនពេលចាប់ផ្តើមសន្តតិកម្ម ឬប្រទានកម្មដែលធ្វើឡើងដោយភាគីទាំងសងខាងបានដឹងថានឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ហើយការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកជាប្រទានកម្មផងដែរ[99]។

### ២.២ ករណីមានការធ្វើភាគនៃវិភាគទាន

ដោយឡែកចំពោះ ភាគនៃវិភាគទាន គឺជាវិភាគទានពិសេសដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិក[100] លើទ្រព្យសម្បត្តិ ឬ

---

[96] សៀវភៅមេរៀនសង្ខេប នីតិរដ្ឋប្បវេណី ទំព័រទី៦-៧ ដោយលោកមេធាវី អ៊ីវ ប៉ូលី

[97] សន្ធានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ២០០៧

[98] សៀវភៅក្រមរដ្ឋប្បវេណី ភាគ៦ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ២០១២

[99] មាត្រា ១២៣២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[100] តាវកាលិក សំដៅលើវត្ថុ ឬសកម្មភាពដែលជាទីតាំង ឬជាកម្មវត្ថុនៃកាតព្វកិច្ច (ឧទាហរណ៍ៈ តាវកាលិករបស់អ្នកទិញ គឺបង់ថ្លៃទៅឱ្យអ្នកលក់ ឯតាវកាលិករបស់អ្នកលក់ គឺប្រគល់វត្ថុទៅឱ្យអ្នកទិញ។

ដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត[101]។ នៅពេលមានភាគនៃវិភាគទាន ដែលជាស្ថានភាពនៃការចំណាយទ្រព្យសម្បត្តិរបស់សហសន្តតិជនណាម្នាក់ នៅក្នុងចំណោមសហសន្តតិជនទាំងអស់ ដើម្បីបង្កើនទ្រព្យរបស់មតកជន ឬចំណាយសម្រាប់ជីវភាពរបស់មតកជន ឬចំណាយដើម្បីមើលថែទាំមតកជន វិធាននៃការសម្រួលចំណែកមត៌ក ក៏ត្រូវកើតឡើងផងដែរ ដើម្បីឱ្យមានសមភាពជាក់ស្តែងសម្រាប់សន្តតិជនដែលបានចំណាយទ្រព្យផ្ទាល់ខ្លួន។

### ២.៣ វិធីសម្រួលចំណែកមត៌ក

នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះចេញពីចំណែកមត៌ក គឺជាមត៌ករបស់បុគ្គលនោះ[102]។

មានន័យថា:

| |
|---|
| មត៌កសរុប = មត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម + ប្រទានកម្ម ឬអច្ច័យទាន |

| |
|---|
| ចំណែកអ្នកមានផលប្រយោជន៍ពិសេស = មត៌កសរុប ÷ ចំនួនសន្តតិជន - ប្រទានកម្ម ឬអច្ច័យទាន |

ឧទាហរណ៍ សន្តតិជនមាន ៣ នាក់ គឺ A B C ដោយមតកជនបានបន្សល់ទុកនូវមត៌កចំនួន ៣០០០$ ប៉ុន្តែ C បានទទួលប្រទានកម្មចំនួន ៦០០$ មុនពេលមតកជនស្លាប់។ ដូចនេះ ទ្រព្យដែលចាត់ទុកជាមត៌ក គឺ ៣៦០០$។

ជាគោលការណ៍ សន្តតិជន A B C ត្រូវទទួលបានចំណែកមត៌កស្មើភាគគ្នា គឺ ១/៣ នៃមត៌ក ចំនួន ៣៦០០$ ។ ដូចនេះ ម្នាក់ៗគឺត្រូវទទួលបាន ១២០០$ ប៉ុន្តែ C បានទទួលប្រទានកម្មចំនួន ៦០០$ ហេតុនេះ C អាចទទួលបានមត៌កបន្ថែមចំនួន ៦០០$ ប៉ុណ្ណោះ ចំណែក A និង B គឺទទួលបានចំណែកម្នាក់ចំនួន ១២០០$ ដែលមានគំនូសតាងដូចខាងក្រោម:

តាង X ជាមត៌កនាពេលចាប់ផ្តើមសន្តតិកម្ម = ៣០០០$

តាង Y ជាប្រទានកម្មរបស់ C = ៦០០$

[101] សិក្ខាសាលាស្តីពីសន្តតិកម្ម ដោយមានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយស លោកជំទាវ **ចាំង ស៊ីណាត** ជាចៅក្រមតុលាការកំពូល ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈអនឡាយ Microsoft Team

[102] មាត្រា ១១៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

តាង U ជាមត៌កសរុប

នាំឱ្យមត៌កសរុប = មត៌កនាពេលចាប់ផ្តើមសន្តតិកម្ម + ប្រទានកម្ម

U = X + Y = ៣០០០+៦០០ = ៣៦០០

ចំណែកមត៌ករបស់C = (៣៦០០ ÷ ៣) - ៦០០ = ៦០០

ចំណែកមត៌ករបស់ A = (៣៦០០ ÷ ៣) = ១២០០

ចំណែកមត៌ករបស់ B = (៣៦០០ ÷ ៣) = ១២០០

ដូចនេះ A ទទួលបានមត៌កចំនួន ១២០០$

B ទទួលបានមត៌កចំនួន ១២០០$

C ទទួលបានមត៌កចំនួន ៦០០ + ប្រទានកម្ម ៦០០ = ១២០០$

ប៉ុន្តែ នៅក្នុងករណីបដិគ្គាហក[103] បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬបើទ្រព្យសម្បត្តិនោះ ត្រូវបាត់បង់ ឬវិនាស នៅមុនពេលចាប់ផ្តើមសន្តតិកម្ម តម្លៃនៃប្រទានកម្ម ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬនៅពេលបាត់បង់ ឬវិនាសនោះ។ ប្រសិនបើ តម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្តូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្តូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្តើមសន្តតិកម្ម។ រីឯ ការប្រាក់ និងផលចំណេញដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ[104]។

ឧទាហរណ៍ សន្តតិជនមាន ៣ នាក់ គឺ A B C ដោយមតកជនបានបន្សល់ទុកនូវមត៌កចំនួន ៣០០០$ ដោយ C បានទទួលប្រទានកម្មចំនួន ៦០០$ ប៉ុន្តែប្រទានកម្មរបស់ C ត្រូវបានបាត់បង់ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។

តាង X ជាមត៌កនាពេលចាប់ផ្តើមសន្តតិកម្ម = ៣០០០$

តាង Y ជាប្រទានកម្មរបស់ C = ៦០០$

តាង U ជាមត៌កសរុប

នាំឱ្យមត៌កសរុប = មត៌កមាននាពេលចាប់ផ្តើមសន្តតិកម្ម ព្រោះ Y ត្រូវបានបាត់បង់ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។

មានន័យថា U = X = ៣០០០

ចំណែកមត៌ករបស់C = U ÷ ៣ = ៣០០០ ÷ ៣ = ១០០០

---

103 បដិគ្គាហក ឬបដិគ្គាហកៈ សំដៅលើភាគីម្ខាងនៃកិច្ចសន្យាប្រទានកម្មដែលយល់ព្រមទទួលយកនូវទ្រព្យសម្បត្តិពីទាយក ដោយមិនផ្តល់តម្លៃតបស្នង។

104 មាត្រា ១១៦៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ចំណែកមត៌ករបស់ A = U ÷ ៣ = ៣000 ÷ ៣ = ១000

ចំណែកមត៌ករបស់ B = U ÷ ៣ = ៣000 ÷ ៣ = ១000

ដូចនេះ A ទទួលបានមត៌កចំនួន ១000$

B ទទួលបានមត៌កចំនួន ១000$

C ទទួលបានមត៌កចំនួន ១000$

ក្នុងករណីតម្លៃនៃប្រទានកម្ម ឬ អច្ច័យទានដែលសហសន្តតិជនបានទទួលមានចំនួនលើសពីចំណែកមត៌កក៏ដោយ ក៏សហសន្តតិជននោះ មិនចាំបាច់បង្វិលត្រលប់មកវិញនូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង[105] ហើយចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រ នៃចំណែកមត៌ក របស់សហសន្តតិជននីមួយៗ[106]។ ប៉ុន្តែបើការទទួលផលប្រយោជន៍ពិសេសនោះ លើសពី ២០ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនដែលទទួលផលប្រយោជន៍ពិសេសនោះ អាចបដិសេធនូវការទាមទារកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងបាន[107]។

ឧទាហរណ៍ សន្តតិជនមាន ៣នាក់ គឺ A B C ដោយមតកជនបានបន្សល់ទុកនូវមត៌កចំនួន ៣000$ ដោយ C បានទទួលប្រទានកម្មចំនួន ២២00$ ។

យើងមានគំនូសតាងដូចខាងក្រោម:

តាង X ជាមត៌ករបស់មតកជន ស្មើ ៣000$

តាង Y ជាប្រទានកម្មរបស់C ស្មើ ២២00$

តាង U ជាមត៌កសរុប

ប៉ុន្តែចំនួនប្រទានកម្មរបស់C គឺលើសតម្លៃនៃចំណែកមត៌ក ហេតុនេះ C មិនអាចទទួលបាននូវចំណែកមត៌កបានឡើយ។

ចំណែកមត៌ករបស់ C = 0

ដោយ U = X = ៣000

ចំណែកមត៌ករបស់ A = U ÷ ២ = ៣000 ÷ ២ = ១៥00$

[105] ភាគបម្រុង គឺជាភាគនៃទ្រព្យសម្បត្តិរបស់មតកជនដែលបច្ឆាញាតិ ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជននោះ អាចទាមទារបាន តាមការកំណត់របស់ច្បាប់។

[106] មាត្រា ១១៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២00៧

[107] មាត្រា ១២៣៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២00៧

ចំណែកមត៌ករបស់ B = U ÷ ២ = ៣000 ÷ ២ = ១៥00$

ដូចនេះ A ទទួលបានមត៌កចំនួន ១៥00$

B ទទួលបានមត៌កចំនួន ១៥00$

C ទទួលបានមត៌កចំនួន 0$ ប៉ុន្តែបានតែប្រទានកម្មចំនួន ២២00$

ដោយឡែក ក្នុងករណីសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាមួយបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬដោយការមើលថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះ ដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ។

មួយវិញទៀត បើការពិភាក្សាពុំបានសម្រេច ឬពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំនេះរបស់បុគ្គលដែលបានធ្វើវិភាគទាន ដោយពិចារណាទៅលើពេល វិធី និងកម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និងស្ថានភាពទាំងអស់ផ្សេងទៀត។ ប៉ុន្តែភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និងតម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថា ជាចំណែកនៃមត៌ករបស់សហសន្តតិជន ឬជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ[108]។

ឧទាហរណ៍ សន្តតិជនមាន ៣ នាក់ គឺ A B C ដោយមតកជនបានបន្សល់ទុកនូវមត៌កចំនួន ៣000$ ដោយ C បានជួលអ្នកមើលថែមតកជនអស់សោហ៊ុយចំនួន ៦00$ ។

តាង X ជាមត៌កនាពេលចាប់ផ្តើមសន្តតិកម្ម = ៣000$

តាង Y ជាវិភាគទានពិសេសរបស់ C = ៦00$

តាង U ជាមត៌កសរុប

តាង Q ជាមត៌កសុទ្ធ

នាំឱ្យ Q = U – Y = ៣000$ - ៦00$ = ២៤00$

សមាមាត្រចំណែកមត៌កគឺ

ចំណែកមត៌ករបស់C = Q ÷ ៣ = ២៤00$ ÷ ៣ = ៨00$

ចំណែកមត៌ករបស់ A = Q ÷ ៣ = ២៤00$ ÷ ៣ = ៨00$

---

[108] មាត្រា ១១៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២00៧

ចំណែកមត៌ករបស់ B = Q ÷ ៣ = ២៤០០$ ÷ ៣ = ៨០០$

ប៉ុន្តែចំណែកមត៌កជាក់ស្តែងរបស់ C គឺ ៨០០$ + ៦០០$ = ១៤០០$

ដូចនេះ A ទទួលបានមត៌កចំនួន ៨០០$

B ទទួលបានមត៌កចំនួន ៨០០$

C ទទួលបានមត៌កចំនួន ១៤០០$

# ជំពូកទី៣
# ការប្រតិបត្តិសន្តិកម្ម

# ជំពូកទី៣
# ការប្រតិបត្តិសន្តតិកម្ម

ការប្រតិបត្តិការនៃសន្តតិកម្ម គឺជាសកម្មភាពមួយរបស់អ្នកដែលមានសិទ្ធិ កាតព្វកិច្ច និងករណីកិច្ច ដែលពាក់ព័ន្ធទៅនឹងសន្តតិកម្ម អាចធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនដោយសេរី ក្រោមរូបភាពដូចជា ការយល់ព្រម ឬបោះបង់សន្តតិកម្ម នៅពេលសន្តតិកម្មមានអានុភាពចំពោះខ្លួន។មិនតែប៉ុណ្ណោះ វាក៏ជាការបញ្ចប់នូវទំនាក់ទំនងគតិយុត្តិរវាងសិទ្ធិលើកម្មសិទ្ធិរបស់មតកជនដែលមាន ហើយត្រូវផ្ទេរទៅជនដែលសន្មតថា ជាសន្តតិជនធ្វើការគ្រប់គ្រងមត៌កបន្តទៅទៀត។ ក្នុងនោះផងដែរ សន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្ម នៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ហើយធ្វើការគ្រប់គ្រង និងបែងចែកមត៌ក ទៅតាមសិទ្ធិរបស់សហសន្តតិជននីមួយៗ។ ចំណែកឯសន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្មនៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់តែប៉ុណ្ណោះ ប្រសិនបើសន្តតិជនមិនបានទាមទារនៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ទេ សិទ្ធិនោះនឹងត្រូវរលត់ដើម្បីបញ្ជាក់អំពីសិទ្ធិនិងការទទួលខុសត្រូវរបស់ខ្លួនចំពោះសន្តតិកម្មដែលមានអានុភាពចំពោះខ្លួន។

## ផ្នែកទី១ ៖ ការយល់ព្រមទទួលសន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មទាំងស្រុង ឬ ដោយកម្រិតនៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ហើយអំឡុងពេលនេះអាចត្រូវបានពន្យា ប្រសិនបើមានពាក្យសុំរបស់សន្តតិជនទៅតុលាការ គឺដើម្បីឱ្យសន្តតិជនធ្វើការស្រាវជ្រាវមត៌ករបស់មតកជន នៅមុនពេលធ្វើការវិនិច្ឆ័យក្នុងការសម្រេចចិត្តយល់ព្រម ឬបោះបង់សន្តតិកម្មនោះចោល[109]។ នេះគឺជាវិធានដែលបញ្ញត្តិសម្របសម្រួលមួយ ចំពោះសន្តតិជនដែលគ្រាន់តែធ្វើសន្តតិកម្មហើយក្ស័យធន ដោយសារតែមានកាតព្វកិច្ចរបស់មតកជនច្រើនពេក ដោយអនុញ្ញាតឱ្យសន្តតិជនទាំងនោះបោះបង់សន្តតិកម្មចោលបាន ហើយទោះបីជាមតកជនគ្មានកាតព្វកិច្ចក៏ដោយ ក៏សន្តតិជនអាចបោះបង់សន្តតិកម្មចោលបានដែរ ដោយហេតុថាមិនចង់បាន ឬ មិនចង់ទទួលមត៌កជាមួយសហសន្តតិជនដទៃទៀតដែលខ្លួនមិនពេញចិត្ត ឬ មិនសូវមានទំនាក់ទំនងល្អជាមួយគ្នា។ ឯការកំណត់អំឡុងពេល គឺជាការពិចារណាចំពោះទំនាក់ទំនងនៃការអនុវត្តសិទ្ធិលើបំណុលចំពោះមតកជន និងសន្តតិជនដែលមិនឱ្យភាគីណាមួយបាត់បង់ផលប្រយោជន៍ដោយសារតែអំឡុងពេលនោះឡើយ។ ដោយឡែកក្នុងករណីពិសេសនៃអំឡុងពេល បើសន្តតិជនបានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្ម នៅក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ ការគណនាអំឡុងពេលត្រូវគិតចាប់ពីពេល

[109] មាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដែលសន្តតិជនរបស់ជននោះ បានដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន[110] ។ ម្យ៉ាងវិញទៀត បើសន្តតិជនជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលដែលបានកំណត់ ៣ខែ សម្រាប់បង្ហាញឆន្ទៈការយល់ព្រម ឬបោះបង់ ត្រូវគណនាគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ[111]។ មានន័យថាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ មិនមានសិទ្ធិអំណាចក្នុងការសម្រេចយល់ព្រម ឬ បោះបង់សន្តតិកម្មបានឡើយ មានតែអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលទេ ដែលមានសិទ្ធិក្នុងការយល់ព្រម ឬ បោះបង់សន្តតិកម្ម ហើយធ្វើការសម្រេចចិត្តដើម្បីការពារផលប្រយោជន៍សម្រាប់ជនទាំងនោះ។ មួយវិញទៀត ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងទៀត អំឡុងពេលដែលបានកំណត់ ៣ខែ សម្រាប់ការបង្ហាញឆន្ទៈយល់ព្រម ឬ បោះបង់ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ហើយវាក៏អាចជាគោលការណ៍មួយ សម្រាប់ការពារផលប្រយោជន៍សន្តតិជន ដោយច្បាប់គិតពីស្ថានភាពដែលសន្តតិជនជឿជាក់ថា មតកជនគ្មានមត៌កជាទ្រព្យអកម្មនោះទេ[112]។ លើសពីនេះទៅទៀត ការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះបីជានៅអំឡុងពេលដែលបានកំណត់ ៣ខែ សម្រាប់ការបង្ហាញឆន្ទៈយល់ព្រម ឬ ការបោះបង់ក៏ដោយ ដោយហេតុថា ការយល់ព្រម ឬ ការបោះបង់ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធដូចជា សន្តតិជនដែលមានលំដាប់បន្ទាប់ ឬ ជនមានសិទ្ធិលើបំណុលដែលទទួលដោយសន្តតិកម្មជាអាទិ៍។ផ្ទុយទៅវិញប្រសិនបើមានវិការៈក្នុងការបង្ហាញឆន្ទៈដូចជា ការភាន់ច្រឡំ ឬ ការឆបោក ជាអាទិ៍ ការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម អាចធ្វើទៅបានក្នុងអំឡុងពេល ៦ខែ គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ហើយបើមិនបានអនុវត្តសិទ្ធិលុបចោលក្នុងអំឡុងពេលនោះទេ សិទ្ធិនោះនឹងត្រូវរលត់ទៅវិញ ឬ នៅក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម[113]។មានន័យថា ក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ដែលមានភាពចាំបាច់ត្រូវការពារសន្តតិជនដែលបានបង្ហាញឆន្ទៈ ច្បាប់ក៏បានបញ្ញត្តិអំឡុងពេលសមរម្យទុកឱ្យសន្តតិជនធ្វើការលុបចោលសកម្មភាពពីមុនដែលមានវិការៈនោះ។ ហើយប្រសិនបើទុកឱ្យជននោះ មានសិទ្ធិនេះរហូតទៅ នឹងធ្វើឱ្យមានឥទ្ធិពលខ្លាំងទៅលើផលប្រយោជន៍របស់ជនដែលពាក់ព័ន្ធ

[110] មាត្រា ១២៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[111] មាត្រា ១២៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[112] មាត្រា ១២៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[113] មាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ហេតុនេះហើយ បានជាមានការកម្រិតនូវអំឡុងពេលដែលអាចអនុវត្តសិទ្ធិលុបចោលនេះ។ បុគ្គលដែលមានបំណងចង់លុបចោលការយល់ព្រមដោយកម្រិត ឬ ការបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំទៅតុលាការ លើកលែងតែការលុបចោលនូវសកម្មភាពចាត់ចែង ដែលត្រូវបានចាត់ទុកថាជាការយល់ព្រមទាំងស្រុង ដោយសារមូលហេតុនៃការភាន់ច្រឡំ ឬការឆបោកជាអាទិ៍ ការយល់ព្រមទាំងស្រុងនោះនឹងត្រូវបាត់បង់ទៅវិញ[114]។ លើសពីនេះទៅទៀត សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជននៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ[115]។ មានន័យថា ក្នុងករណីដែលសន្តតិជនមិនទាន់បានយល់ព្រម ឬ បោះបង់សន្តតិកម្មទេ អ្នកទទួលបន្តចុងក្រោយរបស់មតកជននៃសន្តតិកម្ម ក៏មិនទាន់មានភាពច្បាស់លាស់ ហេតុនេះ បើម្ចាស់បំណុលរបស់មតកជនមានបំណងចង់ធ្វើបណ្តឹង ត្រូវទាមទារឱ្យតុលាការធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នសិន បន្ទាប់មកអាចចាប់ផ្តើមសកម្មភាពដោយបណ្តឹងចំពោះអ្នកគ្រប់គ្រងនោះបាន។ ប្រសិនបើម្ចាស់បំណុលបានធ្វើបណ្តឹងនៅពេលមតកជនបានទទួលមរណភាព នីតិវិធីនៃបណ្តឹងនោះត្រូវតែផ្អាក រហូតដល់ពេលសន្តតិជនបានយល់ព្រមសន្តតិកម្ម។

ជាគោលការណ៍សន្តតិជនអាចធ្វើការបង្ហាញឆន្ទៈដោយសេរី ក្នុងការយល់ព្រមទទួលយកនូវមត៌កពីមតកជន ហើយនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានធ្វើការបែងចែកការយល់ព្រមទទួលយកមត៌កជា ២ ប្រភេទគឺ ការយល់ព្រមទាំងស្រុង និង ការយល់ព្រមដោយមានកម្រិត។

### ១.១ ការយល់ព្រមទាំងស្រុង

ក្នុងករណីដែលសន្តតិជនបានបង្ហាញឆន្ទៈយល់ព្រមទទួលយកទាំងស្រុង នូវទ្រព្យសម្បត្តិមានន័យថា សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ដោយមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការឡើយ[116]។ ម៉្យាងវិញទៀត ប្រសិនបើសន្តតិជនបានធ្វើសកម្មភាពណាមួយ ក្នុងចំណោមសកម្មភាពខាងក្រោមនេះ ក៏ត្រូវបានចាត់ទុកថាសន្តតិជនបានធ្វើការយល់ព្រមទាំងស្រុងទៅតាមបញ្ញត្តិច្បាប់ដែរ៖

- សន្តតិជនបានចាត់ចែងមត៌កនោះ ទាំងអស់ ឬ មួយភាគ លើកលែងតែសកម្មភាពនោះ ជាការថែរក្សាមត៌ក ឬ សកម្មភាពត្រឹមតែជាការគ្រប់គ្រងតែប៉ុណ្ណោះ។
- សន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់នៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម លើកលែងក្នុងករណីដែលសន្តតិជនសុំពន្យាពេលទៅតុលាការ។

[114] សេចក្តីកំណត់ចំពោះមាត្រា ១២៥២ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹ៨ និង ៩

[115] មាត្រា ១២៥៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[116] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- សន្តតិជនបានលាក់មត៌កទាំងអស់ឬមួយភាគ ឬបានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ក៏ដោយ លើកលែងតែនៅក្រោយពេលដែលជនដែលក្លាយជាសន្តតិជន ដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម[117]។

មានន័យថា ក្នុងករណីដែលសន្តតិជនលំដាប់បន្ទាប់បានយល់ព្រម សន្តតិកម្មនេះត្រូវឱ្យទៅសន្តតិជនលំដាប់បន្ទាប់នោះ ក្នុងគោលបំណងដើម្បីធានាឱ្យមានស្ថេរភាពតាមផ្លូវច្បាប់។ ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ សន្តតិជនលំដាប់បន្ទាប់អាចធ្វើការទាមទារឱ្យសន្តតិជនលំដាប់មុន ប្រគល់មត៌កមកវិញ ឬ ទាមទារឱ្យសងសំណងនៃការខូចខាត។

លើសពីនេះទៅទៀត ក្រៅពីការយល់ព្រមទាំងស្រុង សន្តតិជនក៏អាចធ្វើការយល់ព្រមដោយកម្រិតចំពោះមត៌កដែលបានទទួលនាពេលចាប់ផ្តើមសន្តតិកម្មផងដែរ។

### ១.២. ការយល់ព្រមដោយកម្រិត

ការយល់ព្រមដោយមានកម្រិតរបស់សន្តតិជន ជាការយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួល តាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។ មានន័យថា ប្រសិនបើសន្តតិជនបានធ្វើសន្តតិកម្មដែលបម្រុងសម្រាប់សងនូវកាតព្វកិច្ចរបស់មតកជនដែលបានទទួលដោយសន្តតិកម្ម សន្តតិជនត្រូវតែទទួលរ៉ាប់រង ដោយសងត្រឹមកម្រិតនៃទ្រព្យសម្បត្តិទទួលបានតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ក្នុងករណី ប្រសិនបើមានសន្តតិជនច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើទៅបាន លុះត្រាតែសហសន្តតិជននោះ បានធ្វើឡើងដោយរួមគ្នាទាំងអស់ ហើយចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជី ដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិជនទាំងអស់ត្រូវមានការឯកភាពគ្នាក្នុងការសងនោះ ពីព្រោះថាប្រសិនបើមានសន្តតិជនមួយចំនួនបានយល់ព្រមទាំងស្រុង ហើយបានអះអាងនូវចំណែកមត៌កនោះ ការជម្រះបញ្ជីនូវមត៌កទាំងអស់នឹងមិនអាចធ្វើបានឡើយ។ ផ្ទុយទៅវិញ បើជនដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង ហេតុនេះ សន្តតិជនដែលនៅសល់អាចយល់ព្រមដោយកម្រិតរួមគ្នាទៅបានហើយ[118]។

ជាងនេះទៅទៀត សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើជាបញ្ជីសារពើភ័ណ្ឌ ដោយបញ្ជាក់អំពីមត៌កសកម្ម និង មត៌កអកម្មដែលសន្តតិជនបានទទួលនៅពេលចាប់ផ្តើមសន្តតិកម្មក្នុងកម្រិតដែលខ្លួនបានដឹង ហើយត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ហើយអំឡុងពេលនេះអាចត្រូវបានពន្យា ប្រសិនបើមានសន្តតិជនណាម្នាក់

[117] មាត្រា ១២៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[118] មាត្រា ១២៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បានដាក់ពាក្យសុំទៅតុលាការនោះ[119]។ ក្នុងករណីដែលមានសហសន្តតិកម្ម សហសន្តតិជនទាំងអស់ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត ដោយយកថ្ងៃដែលសន្តតិជនចុងក្រោយគេ បានដឹងថា សន្តតិកម្មបានចាប់ផ្តើម មកធ្វើជាមូលដ្ឋាននៃការគណនា ដើម្បីការពារសិទ្ធិរបស់សន្តតិជនដែលដឹងអំពីការចាប់ផ្តើមសន្តតិកម្មក្រោយគេ[120]។

រីឯអានុភាពនៃការយល់ព្រមដោយកម្រិតរបស់សន្តតិជនវិញ មានន័យថា ម្ចាស់បំណុលរបស់មតកជនមិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ។ ទោះបីជាមានការយល់ព្រមដោយកម្រិតក៏ដោយ ជាគោលការណ៍មត៌កត្រូវធ្លាក់ទៅឱ្យសន្តតិជន ក៏ប៉ុន្តែជាលក្ខណៈសារធាតុទ្រព្យសម្បត្តិជាមត៌ក ត្រូវធ្វើការជម្រះបញ្ជីផ្សេងៗ ពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន ហេតុនេះ សិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជនមិនរលត់ដោយព្យាកុលភាព[121]ទេ ពោលចាំបាច់ត្រូវជម្រះបញ្ជីដូចគ្នាទៅនឹងនីតិវិធីជម្រះបញ្ជីសិទ្ធិលើបំណុល និងកាតព្វកិច្ចផ្សេងដែរ[122]។

## ផ្នែកទី២ ៖ ការបោះបង់សន្តតិកម្ម

ប្រសិនបើ មានបុគ្គលណាមួយដែលមានបំណងចង់បោះបង់សន្តតិកម្ម បុគ្គលនោះត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះទៅតុលាការដើម្បីបញ្ជាក់ពីឆន្ទៈរបស់ខ្លួននៅក្នុងអំឡុងពេល ៣ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម ហើយអំឡុងពេលនេះអាចត្រូវបានពន្យា ប្រសិនបើមានពាក្យសុំរបស់សន្តតិជនណាម្នាក់ទៅតុលាការនោះ ដើម្បីជៀសវាងបណ្តាលឱ្យមានការភាន់ច្រឡំថា ជននោះបានសុខចិត្តទទួលយកចំណែកមត៌ករបស់ខ្លួន[123]។ ម្យ៉ាងវិញទៀត បុគ្គលដែលបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនចំពោះសន្តតិកម្មនោះតាំងពីដំបូងមកម្ល៉េះ[124]។ មានន័យថា ប្រសិនបើមានបុគ្គលម្នាក់ ឬ ច្រើននាក់ ក្នុងចំណោមសហសន្តតិជនដែលបានបោះបង់សន្តតិកម្ម ជននោះត្រូវបានចាត់ទុកថាមិនមែនជាសន្តតិជនតាំងពីដំបូង រីឯសន្តតិជនផ្សេងទៀត នៅតែមានសិទ្ធិក្នុងការទទួលយកសន្តតិកម្មដដែល។ ជាងនេះទៅទៀត អ្នកដែលជាសន្តតិជនលំដាប់បន្ទាប់ អាចទទួលសន្តតិកម្មបាន ប្រសិនបើមានសហសន្តតិជនលំដាប់មុនទាំងអស់បានបោះបង់សន្តតិកម្មនោះ។

---

119 មាត្រា ១២៥៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

120 សេចក្តីកំណត់ចំពោះមាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី ភាគ៦៖ គន្ថីទី៨ និង ទី៩ ទំព័រ ១១៨

121 ករណីដែលកម្មសិទ្ធិ ឬសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានលើវត្ថុតែមួយធ្លាក់ទៅលើបុគ្គលតែម្នាក់ ឬករណីដែលសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀត ដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់។

122 មាត្រា ១២៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

123 មាត្រា ១២៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

124 មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ផ្នែកទី៣ ៖ ការគ្រប់គ្រងមត៌ក

ការគ្រប់គ្រងមត៌ក វាជារឿងសំខាន់សម្រាប់សន្តតិជន និង ជនដែលពាក់ព័ន្ធទៅនឹងមត៌កក្រោយពេលដែលមតកជនបានទទួលមរណភាព។ហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានបញ្ញត្តិទទួលស្គាល់បុគ្គលដែលអាចគ្រប់គ្រងមត៌កជា ៣ ប្រភេទគឺ ការគ្រប់គ្រងមត៌កដោយសន្តតិជន ការគ្រប់គ្រងមត៌កដោយអ្នកប្រតិបត្តិមតកសាសន៍ និងការជ្រើសតាំងអ្នកគ្រប់គ្រងដោយតុលាការធ្វើការគ្រប់គ្រងមត៌កជាបណ្ដោះអាសន្ន បើមិនដូច្នោះទេ ជននោះត្រូវបានចាត់ទុកថាជាជនដែលកំពុងតែគ្រប់គ្រងមត៌កដោយទុច្ចរិត។

### ៣.១ ការគ្រប់គ្រងមត៌កដោយសន្តតិជន

សន្តតិជនដែលកាន់កាប់មត៌ក នៅពេលដែលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះដោយប្រុងប្រយ័ត្ន ប្រៀបដូចជាទ្រព្យសម្បត្តិរបស់ខ្លួន រហូតដល់ពេលធ្វើការបែងចែកមត៌កបានចាប់ផ្ដើមឡើង។ នេះគឺដោយសារតែ គេបានយកចិត្តទុកដាក់ទៅលើការថែរក្សាមត៌កឱ្យស្ថិតនៅក្នុងស្ថានភាពដដែលរហូតដល់ពេលធ្វើការបែងចែកមត៌ក។ ម្យ៉ាងទៀត ចំពោះមត៌កដែលមិនទាន់បានកាន់កាប់ដោយសន្តតិជនណាមួយនោះ នៅពេលដែលមតកជនបានទទួលមរណភាព សហសន្តតិជន ត្រូវរក្សាទុក និងគ្រប់គ្រងមត៌កនោះរួមគ្នាដោយសុចរិត និង ស្មោះត្រង់។ លើសពីនេះទៅទៀត ទោះបីជាមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះដោយប្រុងប្រយ័ត្ន ដូចគ្នាទៅនឹងទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួនដែរ [125] ។ ក្នុងករណីនេះ ក្រោយពេលដែលសន្តតិជនបានបោះបង់សន្តតិកម្ម សន្តតិជននៅតែមានកាតព្វកិច្ចក្នុងការគ្រប់គ្រងរក្សាទុកនូវមត៌កនោះ រហូតដល់ពេលដែលអ្នកដែលក្លាយជាសន្តតិជន ដោយសារការបោះបង់នេះ អាចចាប់ផ្ដើមគ្រប់គ្រងមត៌កនោះបាន។ ហើយនៅពេលសន្តតិជនថ្មីបានទាមទារឱ្យប្រគល់មត៌កនោះ សន្តតិជនមុនដែលបានគ្រប់គ្រងរក្សាទុកនូវមត៌ក ត្រូវតែប្រគល់មត៌កនោះឱ្យទៅសន្តតិជនថ្មីភ្លាម ដោយគ្មានការយឺតយ៉ាវ[126]។

### ៣.២ ការគ្រប់គ្រងដោយអ្នកប្រតិបត្តិមតកសាសន៍

ក្នុងករណីដែលសន្តតិកម្មធ្វើឡើងតាមរយៈមតកសាសន៍ និង បានកំណត់អ្នកប្រតិបត្តិមតកសាសន៍ បុគ្គលដែលជាអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិ និង ករណីកិច្ច ក្នុងការគ្រប់គ្រងមត៌កនៅពេលចាប់ផ្ដើមកាន់កាប់មុខងាររបស់ខ្លួន ហើយអាចធ្វើនូវរាល់សកម្មភាពដែលចាំបាច់ទាក់ទងទៅនឹងការគ្រប់គ្រងមត៌ក ដើម្បីប្រតិបត្តិមតកសាសន៍នោះ។ ជាងនេះទៅទៀត ប្រសិនបើមតកជនបានកំណត់នូវទ្រព្យសម្បត្តិយ៉ាងជាក់លាក់នៅក្នុងមតកសាស៍ដូចជា ដីមួយហិចតា ឬ ផ្ទះល្វែងមួយល្វែងជាអាទិ៍ អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ

[125] មាត្រា ១២៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[126] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗក្នុងក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹទី៨ និង ៩ ទំព័រ១២៨

គ្រប់គ្រងទៅលើទ្រព្យសម្បត្តិ ដែលបានកំណត់យ៉ាងជាក់លាក់នៅក្នុងមតកសាសន៍នោះតែប៉ុណ្ណោះ ចំពោះចំណែកមត៌កដែលមិនបានចែងនៅក្នុងមតកសាសន៍ទេ ត្រូវធ្វើការគ្រប់គ្រងមត៌កនោះដោយសន្តតិជនវិញ[127]។

### ៣.៣ ការគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

ម៉្យាងវិញទៀត ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ក្នុងការគ្រប់គ្រងមត៌កទាំងមូលនោះទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌កបានមកដល់។ ចំណែកឯសោហ៊ុយដែលទាក់ទងទៅនឹងការគ្រប់គ្រងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ។ ផ្ទុយទៅវិញ ប្រសិនបើរាល់ការចំណាយទាក់ទងទៅនឹងមត៌កកើតចេញពីកំហុសរបស់សន្តតិជន វាជាបន្ទុករបស់សន្តតិជននោះវិញ[128]។

## ផ្នែកទី៤ ៖ ការបែងចែកមត៌ក

ការបែងចែកមត៌ក នៅក្រោយពេលមរណភាពរបស់មតកជន អាចធ្វើឡើងតាមរយៈការពិភាក្សារវាងសហសន្តតិជន ដែលនឹងបកស្រាយនៅក្នុងចំណុច ៤.១ (ការបែងចែកមត៌កដោយសហសន្តតិជន) និងអាចធ្វើឡើងតាមរយៈការបែងចែកដោយតុលាការ ប្រសិនបើការពិភាក្សារវាងសហសន្តតិជនពុំបានសម្រេច ឬពុំអាចពិភាក្សាបាន ដែលនឹងលើកយកមកបកស្រាយនៅក្នុងចំណុច ៤.២ (ការបែងចែកដោយតុលាការ)។

### ៤.១ ការបែងចែកមត៌កដោយសហសន្តតិជន

ជាគោលការណ៍ ការបែងចែកមត៌កត្រូវធ្វើឡើងតាមការពិភាក្សាគ្នារវាងសហសន្តតិជន ដោយសហសន្តតិជនអាចពិភាក្សាគ្នាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ០១ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម។ប៉ុន្តែចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌កមិនអាចធ្វើបានឡើយ បើអំឡុងពេល ០៣ខែ នៃការបង្ហាញឆន្ទៈយល់ព្រម ឬបោះបង់ចោលសន្តតិកម្មទាំងស្រុង ឬដោយកម្រិតមិនទាន់កន្លងហួស លើកលែងតែមានភាពចាំបាច់ ដើម្បីសងកាតព្វកិច្ចមតកជន ឬមតកជនបានបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍អំពីអំឡុងពេលនៃការបែងចែកមត៌កជាអាទិ៍ ដោយមតកជនអាចហាមឃាត់មិនឱ្យធ្វើការបែងចែកមត៌កក្នុងអំឡុងពេលដែលមិនលើសពី ០៥ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម។ មួយវិញទៀត ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ[129]។ ដូចជាក្នុងករណីពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[130]ជាដើម។ជាធម្មតា ការពិភាក្សាបែងចែកមត៌កមិនមែនជាសកម្មភាព

[127] មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[128] មាត្រា ១២៦៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[129] មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[130] ប្រការ ៦ នៃប្រកាសអន្តរក្រសួងស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

ចាំបាច់មានទម្រង់ទេ ហើយក៏មិនចាំបាច់ធ្វើជាលាយល័ក្ខណ៍អក្សរនោះដែរ។ ក៏ប៉ុន្តែនៅក្នុងចំណោមមត៌កទាំងអស់ មាន មត៌កខ្លះ ត្រូវការមានទម្រង់កំណត់មួយ ដើម្បីផ្ទេរសិទ្ធិ ឬដើម្បីឱ្យមានល័ក្ខខ័ណ្ឌតតាំង។ ហេតុនេះហើយ ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុ តាមការបែងចែកមត៌ក ត្រូវធ្វើតាមទម្រង់ចាំបាច់ដើម្បីផ្ទេរសិទ្ធិនីមួយៗនោះ។ ក្នុងករណីដែលចំណែកនៃកម្មសិទ្ធិអវិភាគត្រូវបានផ្ទេរ ឬក្នុងករណីដែលដីធ្លីដែលមានឈ្មោះមតកជន ត្រូវដាក់ជាកម្មសិទ្ធិរបស់សន្តតិជនកំណត់ណាមួយតែម្នាក់ឯង ដើម្បីចុះបញ្ជីបញ្ជាក់អំពីការផ្ទេរទាំងនេះ ត្រូវធ្វើជាលិខិតយថាភូត [131] ។ លិខិតយថាភូត គឺជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនេះ។ តាមន័យចង្អៀតគឺជា លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី[132]។

ទម្រង់នៃពាក្យសុំចុះបញ្ជីអំពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ ត្រូវសរសេរនូវចំណុចដូចខាងក្រោម និងទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ:

- ឈ្មោះប្រទេសជាផ្លូវការ
- បាវចនា
- រដ្ឋបាលសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ដែលអចលនវត្ថុតាំងនៅ
- គោលបំណងនៃពាក្យសុំចុះបញ្ជី
- មូលហេតុនៃពាក្យសុំចុះបញ្ជី និងកាលបរិច្ឆេទ
- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់បុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ នៅពេលសាមីខ្លួនមិនមែនជាបុគ្គលមានសិទ្ធិចុះបញ្ជី និងបុគ្គលមានកាតព្វកិច្ចចុះបញ្ជី
- ឈ្មោះរបស់អភិបាលតំណាងនីតិបុគ្គល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជានីតិបុគ្គល
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ក្នុងករណីការដាក់ពាក្យសុំចុះបញ្ជីត្រូវធ្វើឡើងដោយអ្នកតំណាង
- អត្តសញ្ញាណនៃអចលនវត្ថុ
- កិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុអវិភាគជាអាទិ៍ ប្រសិនបើមាន
- មូលហេតុដែលនាំឱ្យមានឧបាទេសកម្ម និងកាលបរិច្ឆេទនៃមូលហេតុនោះ នៅពេលដែលអ្នកដាក់ពាក្យសុំ គឺជាឧបាទេសិក
- ឈ្មោះ និងអាសយដ្ឋានរបស់ឧបាទេសិក ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក

[131] សេចក្តីកំណត់មាត្រា ១២៦៦ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹទី៨-ទី៩

[132] សន្ទានុក្រមផ្នែករដ្ឋប្បវេណី

- ឈ្មោះរបស់មតកជន ឬរបស់នីតិបុគ្គលដែលត្រូវបានរួមបញ្ចូល នៅពេលបុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី គឺជាបុគ្គលទទួលបន្តជាសកល
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី
- ចំណែករបស់ម្ចាស់សិទ្ធិម្នាក់ៗ ក្នុងករណីដែលមានម្ចាស់សិទ្ធិពីរ ឬច្រើននាក់
- ឯកសារភ្ជាប់[133]។

នៅពេលដែលដាក់ពាក្យសុំចុះបញ្ជី បុគ្គលដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវផ្តល់ឯកសារចាំបាច់មួយចំនួនដូចខាងក្រោម ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនីមួយៗ:

- ឯកសារដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គល ដែលដាក់ពាក្យសុំចុះបញ្ជី
- លិខិតបញ្ជាក់សិទ្ធិតំណាងរបស់អភិបាលតំណាងនីតិបុគ្គល ប្រសិនបើអ្នកដាក់ពាក្យសុំចុះបញ្ជីជានីតិបុគ្គល
- លិខិតប្រគល់សិទ្ធិតំណាង ក្នុងករណីដែលពាក្យសុំចុះបញ្ជីនោះ ជាជនដែលស្ថិតនៅក្រោមអ្នកតំណាងដែលកំណត់ដោយច្បាប់
- លិខិតប្រគល់សិទ្ធិតំណាង ក្នុងករណីដែលពាក្យសុំធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិ
- ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី
- ឯកសារបញ្ជាក់អំពីមូលហេតុនៃឧបាទេសកម្ម ក្នុងករណីដែលអ្នកដាក់ពាក្យសុំជាឧបាទេសិក
- សាលក្រម ឬសាលដីកាស្ថាពរ ជាអាទិ៍ ក្នុងករណីដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវបានធ្វើឡើងដោយផ្អែកលើសាលក្រម ឬសាលដីកាស្ថាពរជាអាទិ៍
- ឯកសារបញ្ជាក់ពីការយល់ព្រមរបស់តតិយជន ក្នុងករណីពាក់ព័ន្ធផលប្រយោជន៍តតិយជននោះ
- ឯកសារបញ្ជាក់អំពីសន្តតិកម្ម ឬការរួមបញ្ចូលគ្នានៃនីតិបុគ្គល ក្នុងករណីពាក្យសុំចុះបញ្ជីដែលមានចែងក្នុងកថាខណ្ឌទី២ ប្រការ ១០ និងប្រការ ១១ នៃប្រកាសអន្តរក្រសួងរវាងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី
- គំនូសបង្ហាញសេវភាព
- គំនូសបង្ហាញទីតាំងអគារ ដែលជាកម្មវត្ថុនៃផលុបភោគ
- ប័ណ្ណ

[133] ប្រការ ២៦ នៃប្រកាសអន្តរក្រសួងរវាងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[134]។

នៅពេលកម្មសិទ្ធិត្រូវបានផ្ទេរទាំងមូល ឬមួយផ្នែក ពាក្យសុំចុះបញ្ជីត្រូវសរសេរនូវចំណុចដូចខាងក្រោមៈ

ក. គោលបំណងណាមួយដូចខាងក្រោមៈ

- ការផ្ទេរកម្មសិទ្ធិទាំងមូល
- ការផ្ទេរកម្មសិទ្ធិមួយផ្នែក

ខ.មូលហេតុ និងកាលបរិច្ឆេទណាមួយដូចខាងក្រោមៈ

- ការលក់ទិញ
- ប្រទានកម្ម
- ការដូរ
- សន្តតិកម្ម
- ការបែងចែកមត៌កតាមការព្រមព្រៀង
- អច្ច័យទាន
- សាលក្រម ឬសាលដីកាស្ថាពរ
- មូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត។

គ. បុគ្គលមានសិទ្ធិចុះបញ្ជី

- ឈ្មោះ
- ថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើត
- អាសយដ្ឋាន
- ឈ្មោះឪពុក និងឈ្មោះម្ដាយ

ឃ. ចំណុចផ្សេងទៀតដែលត្រូវចុះបញ្ជី

- ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគថ្មី

ង. អត្តសញ្ញាណនៃអចលនវត្ថុ

- ទីតាំងដី
- លេខក្បាលដី ឬលេខប័ណ្ណ[135]។

[134] ប្រការ ២៧ នៃប្រកាសអន្តរក្រសួងរវាងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្ដីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

### ៤.១.១ មូលដ្ឋាននៃការបែងចែក

បើពុំអាចកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍បានទេ ការបែងចែកមត៌ក ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិដែលមាននៅក្នុងមត៌ក ឬអាយុ មុខរបរ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និងស្ថានភាពផ្សេងទៀត។ ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀតតាមការពិភាក្សា[136]។

### ៤.១.២ សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធ មានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ[137]។ នៅក្នុងករណីនេះ ច្បាប់បានទទួលស្គាល់នូវសិទ្ធិអាទិភាពក្នុងការធ្វើលទ្ធកម្មរបស់សហព័ទ្ធដែលនៅរស់ ចំពោះទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ និងមតកជនពេលនៅរស់។ ទ្រព្យសម្បត្តិដែលប្តីប្រពន្ធទាំងសងខាង ឬ ម្ខាងបានធ្វើលទ្ធកម្មពេលមានចំណងអាពាហ៍ពិពាហ៍ ជាគោលការណ៍ គឺជាទ្រព្យសម្បត្តិរួម។ ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាងឬតែម្ខាងទទួលបាននៅអំឡុងពេលអាពាហ៍ពិពាហ៍ក្នុងលក្ខណៈជាប្រាក់បៀវត្សរ៍ឬប្រាក់ឈ្នួលឬប្រាក់កម្រៃ ឬប្រយោជន៍នានា[138] លើកលែងតែទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិនោះ ។

ឧទាហរណ៍៖ ប្តីធ្វើការជាមន្ត្រីរាជការ និងទទួលបានប្រាក់បៀវត្សរ៍ ១លានរៀល ក្នុងមួយខែ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។ ហេតុដូច្នេះហើយប្រាក់បៀវត្សរ៍របស់ប្តី ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្តី និងប្រពន្ធ។

ក្នុងករណីប្រាក់ចំណូលដែលប្តីរកបានតែម្ខាង ហើយប្រពន្ធត្រឹមតែជាស្ត្រីមេផ្ទះ ធ្វើតែការងារគេហកិច្ច (ការងារក្នុងផ្ទះ) តើប្រាក់ចំណូលដែលប្តីរកបានតែម្ខាងត្រូវចាត់ទុកថា ជាទ្រព្យរួម ឬ ទ្រព្យដោយឡែក?

---

135 ប្រការ ២៨ នៃប្រកាសអន្តរក្រសួងរវាងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

136 មាត្រា ១២៦៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

137 មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

138 មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ពាក់ព័ន្ធនឹងករណីខាងលើ យោងតាមមាត្រា ៣៦ វាក្យខ័ណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ការងារមេផ្ទះ មានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។ មានន័យថា ប្ដីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរកបានពីការងារក្រៅផ្ទះ ថាមិនមែនជាទ្រព្យរួម ឬបន្ថយសិទ្ធិរបស់ប្រពន្ធលើចំណូលរបស់ខ្លួន ដោយសំអាងថាប្រពន្ធរបស់ខ្លួនធ្វើតែការងារផ្ទះ មើលថែទាំកូន ដាំស្ល បោកគក់ ដោយមិនបានប្រឡូកនឹងការងារខាងក្រៅដែលនឿយហត់ដូចការងាររបស់ខ្លួនឡើយ។

ដូចនេះ ប្រសិនបើប្ដី ឬប្រពន្ធណាម្នាក់ទទួលមរណភាព ពាក់កណ្ដាលនៃទ្រព្យសម្បត្តិនោះ ជារបស់សហព័ទ្ធដែលនៅរស់ ហើយពាក់កណ្ដាលទៀត ជាមត៌ក។ ក៏ប៉ុន្តែ ទ្រព្យសម្បត្តិប្រភេទនេះ ក្នុងករណីជាច្រើនសហព័ទ្ធដែលនៅរស់តែងតែមានបំណងចង់ទទួលតែម្នាក់ឯង ដើម្បីជាអនុស្សាវរីយ៍រវាងសហព័ទ្ធដែលនៅរស់និងមតកជន ហើយប្រសិនបើទទួលបានកម្មសិទ្ធិឯកឯង ទំនាក់ទំនងផ្លូវច្បាប់ ពេលក្រោយ ក៏មិនសូវមានបញ្ហាដែរ។ ដូចនេះហើយ បានជាក្នុងការបែងចែកមត៌ក ច្បាប់ទទួលស្គាល់ឱ្យសហព័ទ្ធ មានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលកម្មសិទ្ធិអវិភាគរបស់មតកជន ចំពោះទ្រព្យសម្បត្តិរួម រហូតដល់បានទទួលគ្រប់ចំនួននូវចំណែកមត៌ករបស់ខ្លួន[139]។

### ៤.១.៣ សំណងនៃភាតព្វកិច្ចរបស់មតកជន

ដូចដែលយើងខ្ញុំបានពន្យល់បកស្រាយនៅក្នុងជំពូកទី១ (សញ្ញាណទូទៅនៃសន្តតិកម្ម) សន្តតិកម្ម គឺជាការផ្ទេរទាំងសិទ្ធិ កាតព្វកិច្ចនិងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជន មានន័យថានៅពេលដែលសន្តតិកម្មចាប់ផ្ដើមកើតឡើង សន្តតិជនមិនត្រឹមតែទទួលបន្តនូវសិទ្ធិ ឬផលប្រយោជន៍ផ្សេងៗពីមតកជនប៉ុណ្ណោះនោះទេ ផ្ទុយទៅវិញ សន្តតិជនក៏អាចត្រូវទទួលបន្តនូវករណីកិច្ច ឬជាបំណុលណាមួយដែលមតកជនមានផងដែរ។ ក្នុងករណីនេះ បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះនិងមិនអាចប្ដូរភាគបន្ទុកនៃកាតព្វកិច្ចនោះដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ[140]។ មានន័យថា កាតព្វកិច្ចដែលទទួលដោយសន្តតិកម្ម ត្រូវបានបែងចែកដោយស្វ័យប្រវត្តិ ទៅតាមសមាមាត្រនៃចំណែកម្នាក់ៗ នៅពេលចាប់ផ្ដើមសន្តតិកម្ម ហើយមិនអាចប្ដូរនូវសមាមាត្រនៃបន្ទុកនោះបានទេ ទោះបីជាមានការព្រមព្រៀងពីសហសន្តតិជនក៏ដោយ។ដូចនេះ ក្នុងករណីដែលមតកជនបានធ្វើអាជីវកម្មអ្វីមួយ ហើយមានទ្រព្យសកម្មផង និងទ្រព្យអកម្មផង ដើម្បីធ្វើការព្រមព្រៀងឱ្យសហសន្តតិជនណាម្នាក់ ឬច្រើននាក់ទទួលកាតព្វកិច្ចពាក់ព័ន្ធនឹងអាជីវកម្មនោះ ជំនួសឱ្យការទទួលបន្តអាជីវកម្ម ទាល់តែមានការយល់ព្រមពីម្ចាស់បំណុល[141]។

---

139 សេចក្ដីកំណត់មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

140 មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

141 សេចក្ដីកំណត់មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

## ៤.២ ការបែងចែកដោយតុលាការ

បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ដូចបានបកស្រាយនៅក្នុងចំណុច ៤.១ (ការបែងចែកមត៌កដោយសហសន្តតិជន) ពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌កនោះបាន[142]។ ជាគោលការណ៍ តុលាការអាចធ្វើការបែងចែកមត៌កជំនួសឱ្យសហសន្តតិជន នៅក្នុងករណីដែលការពិភាក្សារបស់សហសន្តតិជន នៅក្នុងការបែងចែកមត៌កពុំបានសម្រេច ឬសហសន្តតិជនពុំអាចពិភាក្សាបាន តាមរយៈការដាក់ពាក្យសុំទៅតុលាការឱ្យធ្វើការបែងចែកមត៌ក ដោយតុលាការធ្វើការបែងចែកដោយពិចារណាទៅលើលក្ខខណ្ឌមួយចំនួនដូចជា មូលដ្ឋាននៃការបែងចែក ដូចបានបកស្រាយនៅក្នុងចំណុច ៤.១.១ (មូលដ្ឋាននៃការបែងចែក) សំណងនៃកាតព្វកិច្ចរបស់មតកជន ដូចបានបកស្រាយនៅក្នុងចំណុច ៤.១.៣ (សំណងនៃកាតព្វកិច្ចរបស់មតកជន) ទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន។ ចំពោះការបែងចែកមត៌កដែលជាកម្មសិទ្ធិអវិភាគ តុលាការអាចបង្គាប់ឱ្យបែងចែកវត្ថុ តាមរូបភាពដើមរបស់វា ឬប្រសិនបើមានការបារម្ភថា ការបែងចែកតាមរូបដើមនឹងធ្វើឱ្យខូចខាតតម្លៃហួសហេតុ ឬប្រសិនបើមានមូលហេតុសមរម្យ តុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃ ហើយចែកប្រាក់លក់នោះ តាមចំណែក ឬអាចបង្គាប់ឱ្យផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគ ឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយឱ្យបង់ប្រាក់សំណងនៃចំណែកនោះបាន [143] ។ ជាក់ស្តែង វិធីនៃការបែងចែកវត្ថុកម្មសិទ្ធិអវិភាគមានបីប្រភេទ ទីមួយគឺ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគផ្ទាល់តែម្តង។ ឧទាហរណ៍ ការបែងចែកដីកម្មសិទ្ធិអវិភាគរបស់ "ក" "ខ" និង "គ" ជាបីឡូត៍ដាច់ៗពីគ្នា ហើយឱ្យអ្នកទាំងបីនោះ មានកម្មសិទ្ធិលើដីនីមួយៗនោះ។ ទីពីរគឺ ការលក់វត្ថុកម្មសិទ្ធិអវិភាគទៅឱ្យតតិយជន ហើយបែងចែកថ្លៃលក់បាននោះ ឱ្យម្ចាស់កម្មសិទ្ធិអវិភាគ។ ទីបីគឺ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ ក្នុងចំណោមម្ចាស់កម្មសិទ្ធិទាំងអស់ ធ្វើលទ្ធកម្មវត្ថុនោះទាំងមូល ហើយបង់ប្រាក់ទៅឱ្យម្ចាស់កម្មសិទ្ធិដទៃទៀត[144]។

### ៤.២.១ ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬអំពីបុគ្គលដែលត្រូវទទួលរវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន[145]។ ត្រង់ចំណុចនេះ ក្រៅពីវិធីនៃការបែងចែកមត៌កទៅតាមរូបភាពដើមរបស់វា ឬផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគ ឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយបង់ប្រាក់សំណងនៃចំណែកនោះ ឬប្រសិនបើមានការបារម្ភថា ការបែងចែក

[142] មាត្រា ១២៧០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[143] មាត្រា ២១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[144] សេចក្តីកំណត់មាត្រា ២១២ នៃក្រមរដ្ឋប្បវេណី ភាគ១ គន្លឹះទី១-ទី៣

[145] មាត្រា ១២៧១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

តាមរូបដើមនឹងធ្វើឱ្យខូចខាតតម្លៃហួសហេតុ ឬប្រសិនបើមានមូលហេតុសមរម្យ តុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃ ហើយចែកប្រាក់លក់នោះ តាមចំណែកនោះបាន។

### ៤.២.២ អានុភាពនៃការបែងចែក

ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម។ ប៉ុន្តែការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខណ្ឌតតាំងបានឡើយ។ សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម[146]។ ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬបានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ[147]។ ផ្ទុយទៅវិញ បើមតកជនបានទទួលស្គាល់ជាកូនពេលនៅរស់ ក៏ប៉ុន្តែដោយសារតែសន្តតិជនផ្សេងទៀតមិនបានដឹង ហើយបានដកជនដែលត្រូវបានទទួលស្គាល់នោះចេញពីការពិភាក្សាបែងចែកមត៌ក ឬ ក្នុងករណីដែលការទទួលស្គាល់ ក្រោយមរណភាពរបស់មតកជនត្រូវបានធ្វើឡើងមុនការបែងចែកមត៌ក ក៏ប៉ុន្តែសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ ដោយមិនឱ្យជននោះចូលរួមក្នុងការបែងចែក ការបែងចែកនោះមិនបានធ្វើឡើងដោយមានវត្តមានរបស់សន្តតិជនទាំងអស់ នាំឱ្យការបែងចែកចាត់ទុកជាមោឃៈ[148]។

### ៤.៣ ការសម្រួលរវាងម្ចាស់បំណុល

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិជ្រើសរើសយកគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ដែលតម្រូវឱ្យសន្តតិជនទទួលយកទាំងសិទ្ធិ និងករណីកិច្ចរបស់មតកជនដែលមាននាពេលចាប់ផ្តើមសន្តតិកម្ម។ ការសម្រួលរវាងម្ចាស់បំណុល ជាការហាមឃាត់សិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន ក្រោយពេលចាប់ផ្តើមសន្តតិកម្ម។ ក្នុងករណីដែលមតកជនមានកាតព្វកិច្ច ហើយសន្តតិជនមានកាតព្វកិច្ច ប្រសិនបើគ្មានបញ្ញត្តិសម្រួលទេ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទ្រព្យសម្បត្តិរបស់សន្តតិជន ហើយម្ចាស់បំណុលរបស់សន្តតិជនក៏អាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះចំណែកមត៌ករបស់សន្តតិជននោះផងដែរ។ មានន័យថា ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់អំឡុងពេល ៣ខែ នៃការយល់ព្រម ឬការបោះបង់ចោលសន្តតិកម្ម គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម បានកន្លងហួស[149]។ ម្ចាស់បំណុលរបស់

---

146 មាត្រា ១២៧៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

147 មាត្រា ១២៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

148 សេចក្តីកំណត់មាត្រា ១២៧៦ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

149 មាត្រា ១២៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

មតកជន មានសិទ្ធិអនុវត្តទៅលើមត៌កដែលទុកបម្រុងតែប៉ុណ្ណោះ តាមរយៈការហាមឃាត់មិនឱ្យធ្វើការផ្ទេរកម្មសិទ្ធិពីមតកជនទៅសន្តតិជន ហើយនៅក្នុងអំឡុងពេលនេះ ម្ចាស់បំណុលរបស់មតកជន អាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមត៌កបណ្តោះអាសន្ន ប្រសិនបើគ្មានអ្នកប្រតិបត្តិមតកសាសន៍ ហើយម្ចាស់បំណុលអាចធ្វើការទាមទារឱ្យរក្សាការពារទ្រព្យសម្បត្តិទាំងនោះ។ ម្យ៉ាងវិញទៀត ម្ចាស់បំណុលរបស់សន្តតិជនមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេល ៣ខែ នៃការយល់ព្រម ឬការបោះបង់ចោលសន្តតិកម្ម គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម បានកន្លងហួស[150]។ មានន័យថា ក្នុងអំឡុងពេលនេះ ម្ចាស់បំណុលរបស់សន្តតិជនដែលមានបំណងចង់អនុវត្តសិទ្ធិរបស់ខ្លួនទៅលើមត៌ករបស់មតកជន ក៏សិទ្ធិនោះមិនអាចអនុវត្តបានទេ ទោះបីជាកូនបំណុលរបស់ខ្លួនជាសន្តតិជនក៏ដោយ ពីព្រោះថា កូនបំណុលដែលជាសន្តតិជនមិនទាន់បានបង្ហាញឆន្ទៈក្នុងការយល់ព្រម ឬបោះបង់សន្តតិកម្ម ដែលជាហេតុនាំឱ្យសន្តតិជនមិនទាន់មានសិទ្ធិក្លាយជាកម្មសិទ្ធិករទៅលើមត៌ករបស់មតកជន។

ចំពោះការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ សន្តតិជន និងអ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬអច្ច័យលាភីបានឡើយ រហូតដល់ពេលដែលអំឡុងពេល ៣ខែ នៃការយល់ព្រម ឬការបោះបង់ចោលសន្តតិកម្ម គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើមបានកន្លងហួស។ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក្នុងករណីចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន សន្តតិជន និងអ្នកគ្រប់គ្រងមត៌ក អាចធ្វើការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កបាន ដោយធ្វើនីតិវិធីប្តូរជាប្រាក់ភ្លាមសម្រាប់ករណីដែលបានប្តូរមត៌កជាប្រាក់ ដើម្បីសងបំណុលរបស់មតកជន[151] ។

### ៤.៤ ការជម្រះបញ្ជីក្នុងករណីមានការយល់ព្រមដោយកម្រិត

សន្តតិជនដែលយល់ព្រមដោយកម្រិត ត្រូវបន្តគ្រប់គ្រងមត៌កដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត[152]។ ការយល់ព្រមដោយកម្រិត គឺជានីតិវិធីជម្រះដែលមានលក្ខណៈ ដូចជាក្ស័យធននៃមត៌កដែរ។ ក្នុងករណីសន្តតិកម្មមានសន្តតិជនតែម្នាក់ សន្តតិជនដែលបានយល់ព្រមដោយកម្រិត ជាអ្នកមានករណីកិច្ចគ្រប់គ្រង រីឯក្នុងករណីដែលសន្តតិកម្មមានសន្តតិជនច្រើននាក់ សន្តតិជនដែលត្រូវបានជ្រើសតាំងជាអ្នកគ្រប់គ្រងមត៌ក ដែលតុលាការបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ។ សន្តតិជនដែលបានយល់ព្រមដោយកម្រិត អាចទទួលសន្តតិកម្មនូវមត៌កសកម្មដែលនៅសល់ពីការជម្រះបាន ហើយបានយល់ព្រមទទួលដោយកម្រិត[153]។

[150] មាត្រា ១២៧៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[151] សេចក្តីកំណត់មាត្រា ១២៧៧ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-ទី៩

[152] មាត្រា ១២៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[153] សេចក្តីកំណត់មាត្រា ១២៨០ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្ថីទី៨-ទី៩

អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធារណៈ នៅក្នុងអំឡុងពេល ៥ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និងការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលបានកំណត់ ហើយអំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ខែឡើយ។ ក្នុងករណីអ្នកយល់ព្រមដោយកម្រិត បានជូនដំណឹងជាសាធារណៈ ដោយសរសេរបញ្ជាក់ថា ម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ។

ការជូនដំណឹងនេះ គឺជាការដាស់តឿនឱ្យម្ចាស់បំណុលស្នើសុំ នៅមុនពេលចូលដល់ដំណាក់កាលនៃនីតិវិធីជម្រះមត៌ក ប៉ុន្តែចំពោះម្ចាស់បំណុលដែលភ្ជាប់នូវសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ហ៊ីប៉ូតែក សិទ្ធិនោះមិនអាចរលត់ដោយសារហេតុនេះបានឡើយ។

ផ្ទុយទៅវិញ អ្នកយល់ព្រមដោយកម្រិត មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញពីការជម្រះបានឡើយ ទោះបីជាមានការជូនដំណឹងនេះក៏ដោយ ប៉ុន្តែអ្នកយល់ព្រមដោយកម្រិត អាចធ្វើការដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងដើម្បីឱ្យគេធ្វើការស្នើសុំបាន[154]។

ម្យ៉ាងវិញទៀត នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីបាន[155]។ ប៉ុន្តែ នៅក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈបានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និងម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ[156]។

ជាគោលការណ៍នៃការសងតាមការចែកចំណែក ក្រោយអំឡុងពេលកំណត់សម្រាប់ជូនដំណឹងដែលមានលំដាប់សងដូចខាងក្រោមៈ

- ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព ( ហ៊ីប៉ូតែក)
- ម្ចាស់បំណុលដែលបានស្នើសុំ ក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ និងម្ចាស់បំណុលដែលបានដឹងដោយអ្នកយល់ព្រមដោយកម្រិត លើកលែងតែអច្ច័យលាភីនីមួយៗ

[154] មាត្រា ១២៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[155] មាត្រា ១២៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[156] មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

- អច្ច័យលាភីដែលបានស្នើសុំ ក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ និងអច្ច័យលាភីដែលបានដឹងដោយអ្នកយល់ព្រមដោយកម្រិត
- ម្ចាស់បំណុល និងអច្ច័យលាភីដែលមិនបានស្នើសុំក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈ ហើយអ្នកយល់ព្រមដោយកម្រិតមិនបានដឹង

បន្ទាប់មក ប្រសិនបើមិនអាចសងបំណុលចំពោះម្ចាស់បំណុលទាំងអស់នៃលំដាប់ទី២ទេ ត្រូវសងទៅតាមសមាមាត្រនៃទឹកប្រាក់នៃសិទ្ធិលើបំណុលទាំងនោះ រីឯចំពោះម្ចាស់បំណុលលំដាប់ ទី៣ ទៅ មិនចាំបាច់សងទេ[157]។

នៅពេលដែលសន្តតិជនបង្ហាញឆន្ទៈយល់ព្រមដោយកម្រិតចំពោះសន្តតិកម្ម ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលត្រូវសងក៏ដោយ ក៏ត្រូវសងទៅម្ចាស់បំណុលនៅក្នុងនីតិវិធីជម្រះមត៌កផងដែរ។ ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬសិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ[158]។

ម្យ៉ាងវិញទៀត អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលដែលមានអាទិភាព[159]។ ដូចនេះ ការសងចំពោះអច្ច័យលាភី ត្រូវមានលំដាប់ក្រោយការសងចំពោះម្ចាស់បំណុលរបស់មតកជន។ មូលហេតុដែលច្បាប់បានកំណត់បែបនេះ ដោយសារមូលហេតុ ទីមួយគឺ សិទ្ធិរបស់ម្ចាស់បំណុលនៃមតកជន ត្រូវបានកំណត់ជាស្ថាពរមុនពេលចាប់ផ្តើមសន្តតិកម្ម ដោយមើលទៅតាមស្ថានភាពទ្រព្យសម្បត្តិរបស់មតកជន ផ្ទុយទៅវិញ សិទ្ធិរបស់អច្ច័យលាភី ត្រូវបានធ្វើលទ្ធកម្មដោយចិត្តសប្បុរសធម៌របស់មកតជនដោយឯកតោភាគី ហេតុនេះហើយ ត្រូវឱ្យអាទិភាពទៅលើសិទ្ធិរបស់ម្ចាស់បំណុលនៃមតកជនវិញ។ ទីពីរ ប្រសិនបើឱ្យសមភាពរវាងម្ចាស់បំណុល និងអច្ច័យលាភី អាចមានករណីដែលធ្វើអច្ច័យទានដោយមានគោលបំណងបំពានសិទ្ធិរបស់ម្ចាស់បំណុល[160]។

ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ដោយបង្ខំ ឬលក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសរើសដោយតុលាការ។ ក្នុងករណីនេះ អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬអច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬដោយការលក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវ

157 សេចក្តីកំណត់មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹទី៨-ទី៩
158 មាត្រា ១២៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
159 មាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧
160 សេចក្តីកំណត់មាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹទី៨-ទី៩

បានជ្រើសរើសដោយតុលាការ[161]។ ផ្ទុយទៅវិញ ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬការដាស់តឿន ឬបើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬអច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬអច្ច័យលាភីផ្សេង នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈនោះ អ្នកយល់ព្រមដោយកម្រិត ត្រូវសងសំណងការខូតខាតដែលកើតមានឡើងដោយសារហេតុនោះ។ម្ចាស់បំណុល ឬអច្ច័យលាភីដែលទទួលការខូចខាត ដោយសារលទ្ធផលនៃការសងមិនត្រឹមត្រូវ អាចទាមទារសំណងនៃការខូចខាតពីម្ចាស់បំណុល ឬអច្ច័យលាភី ដែលបានទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ[162]។

ក្នុងករណីដែលម្ចាស់បំណុល និងអច្ច័យលាភីដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ហើយដែលអ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបានអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ លើកលែងតែជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬសិទ្ធិដែលបានកំណត់ដាក់លាក់ក្នុងចំណោមមត៌ក។ មានន័យថា ជនដែលមានសិទ្ធិទៅលើវត្ថុ ឬសិទ្ធិជាក់លាក់ណាមួយដែលត្រូវជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ក្នុងករណីដែលមានការប្តូរជាប្រាក់ក្នុងនីតិវិធីជម្រះ ជនដែលមានសិទ្ធិប្រាតិភោគ អាចទទួលសំណងជាអាទិភាពពីប្រាក់ដែលបានមកពីការលក់តាមវិធីឧបាទេសកម្មលើវត្ថុ ហើយក្នុងករណីដែលបានធ្វេសប្រហែស សិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគនោះ នឹងក្លាយទៅជាសិទ្ធិដែលមិនត្រូវបានធានា[163]។

ដោយឡែក នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសរើសអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រង និងសងកាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និងជំនួសសហសន្តតិជនដទៃទៀត[164]។

## ផ្នែកទី៥ ៖ នត្ថិភាពនៃសន្តតិជន

នៅពេលដែលមនុស្សម្នាក់ទទួលមរណភាព ទ្រព្យសម្បត្តិរបស់គាត់នឹងត្រូវបានទទួលបន្តដោយសន្តតិជន។ ប្រសិនបើមានសន្តតិជន ប៉ុន្តែពួកគេបានបាត់ខ្លួន នោះបញ្ញត្តិស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិសម្រាប់បុគ្គលដែលអវត្តមាន និងការប្រកាសការបាត់ខ្លួន ត្រូវយកមកប្រើប្រាស់។មួយវិញទៀត ក៏អាចមានករណីដែលមិនមានភាពច្បាស់លាស់ថាមានសន្តតិជនឬក៏អត់ផងដែរ។ ក្នុងករណីនេះ ចាំបាច់ត្រូវមាននីតិវិធីក្នុងការស្វែង

[161] មាត្រា ១២៨៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[162] មាត្រា ១២៨៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[163] មាត្រា ១២៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[164] មាត្រា ១២៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

រកសន្តតិជន។ ប្រសិនបើរកមិនឃើញសន្តតិជនទេនោះ ទ្រព្យសម្បត្តិដែលនៅសល់ ត្រូវប្រគល់ជូនឱ្យអ្នកមាននិស្ស័យពិសេសជាមួយនឹងមតកជន ឬធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ[165]។

## ៥.១ នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល[166]។ ភាពមិនច្បាស់លាស់ថាមានសន្តតិជននេះរួមមាន ករណីមិនមានសន្តតិជនសោះ ឬមានសន្តតិជនដែរ ប៉ុន្តែពួកគេទាំងអស់បានបោះបង់ចោលសន្តតិកម្មដូចបានបកស្រាយនៅក្នុងផ្នែកទី២ (ការបោះបង់សន្តតិកម្ម)នៃជំពូកនេះ ឬករណីមានសន្តតិជនដែរ ប៉ុន្តែពួកគេគឺជាអភ័ព្វបុគ្គល ឬជាជនដែលត្រូវបានផ្តាច់មត៌កដូចបានបកស្រាយនៅក្នុងផ្នែកទី៣ (បុគ្គលដែលគ្មានលក្ខណសម្បត្តិជាសន្តតិជន)នៃជំពូកទី១។

ក្នុងករណីដែលគ្មានសន្តតិជនទេ ប្រធាននៃកម្មសិទ្ធិមត៌កក៏គ្មានដែរ ដូចនេះប្រសិនបើគ្មានបញ្ញត្តិអំពីនីតិបុគ្គលមត៌កនេះទេ ចំពោះអចលនវត្ថុត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ រីឯចលនវត្ថុវិញ អ្នកដែលបានកាន់កាប់មុននឹងក្លាយទៅជាកម្មសិទ្ធិករនៃចលនវត្ថុនោះ ជាហេតុធ្វើឱ្យម្ចាស់បំណុលរបស់មតកជននឹងមានការពិបាកក្នុងការទទួលការសង ឬក៏ការប្រជែងយកចលនវត្ថុនឹងអាចកើតឡើង ហើយធ្វើឱ្យមានការជ្រួលច្របល់ដល់សង្គម។ ហេតុនេះហើយ បានជាត្រូវចាត់ទុកមត៌កនោះជានីតិបុគ្គល ហើយឱ្យនីតិបុគ្គលនោះ ធ្វើជាប្រធាននៃសិទ្ធិលើមត៌កនោះ បន្ទាប់មកត្រូវធ្វើការជម្រះទៅតាមនីតិវិធី[167]។

ផ្ទុយទៅវិញ ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង[168]។

### ៥.១.១ ការជ្រើសតាំងអ្នកគ្រប់គ្រង

ក្នុងករណីដែលមត៌កនោះក្លាយទៅជានីតិបុគ្គលមត៌ក តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ[169]។

អ្នកគ្រប់គ្រងមត៌ក ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ហើយត្រូវថែរក្សា និងគ្រប់គ្រងមត៌កនោះ។ បើមានការចាំបាច់ដើម្បីថែរក្សា និងគ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬអាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ។

165 សៀវភៅសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១-៣

166 មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

167 សេចក្តីកំណត់មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

168 មាត្រា ១២៩៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

169 មាត្រា ១២៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ម្យ៉ាងទៀត ប្រសិនបើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬអច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពផ្សេងៗដូចជា ពត៌មានស្តីពីតម្លៃ ឬខ្លឹមសារនៃមត៌កទៅឱ្យជននោះ[170]។

### ៥.១.២ ការជូនដំណឹងជាសាធារណៈ

បន្ទាប់ពីជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ[171]។ ការជូនដំណឹងជាសាធារណៈ ត្រូវធ្វើឡើងដោយបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តបត្ររបស់ក្រសួងយុត្តិធម៌[172]។ ម្យ៉ាងទៀត បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ខែ បន្ទាប់ពីបានជូនដំណឹងជាសាធារណៈដោយតុលាការរួចមក អ្នកគ្រប់គ្រងមត៌កត្រូវជូនដំណឹងជាសាធារណៈចំពោះម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីទាំងអស់ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលកំណត់។

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់ នៅក្នុងការជូនដំណឹងជាសាធារណៈ អ្នកគ្រប់គ្រងមត៌ក អាចបដិសេធក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីបាន។ ប៉ុន្តែ នៅក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈបានកន្លងហួស អ្នកគ្រប់គ្រងមត៌ក អាចយកមត៌កនោះ មកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និងម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹងទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ។

ចំពោះអ្នកគ្រប់គ្រងមត៌កវិញ ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬការលក់តាមរយៈការប្តូរមត៌កជាប្រាក់បានឡើយ[173]។ ក្រោយពីអំឡុងពេល ២ខែ នៃការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុលដោយអ្នកគ្រប់គ្រងមត៌ក បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថា មានសន្តតិជននៅឡើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជនម្តងទៀត តាមពាក្យសុំរបស់អ្នកគ្រប់គ្រងមត៌ក ឬតំណាងអយ្យការ ហើយប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលបានកំណត់ ដោយអំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ខែ ឡើយ។ គោលបំណងនៃការជូនដំណឹងនេះ គឺដើម្បីផ្តល់ឱ្យនូវទ្រព្យសម្បត្តិដែលនៅសល់ទៅឱ្យសន្តតិជន តែបើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មត៌កទេ មិនទាមទារឱ្យអ្នកគ្រប់គ្រងមត៌ក និងតំណាងអយ្យការធ្វើពាក្យសុំឡើយ[174]។

ម្យ៉ាងវិញទៀត នៅក្នុងអំឡុងពេលជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជនដោយតុលាការ បើគ្មានការស្នើសុំថាខ្លួនជាសន្តតិជននោះទេ សន្តតិជននោះ មិនអាចអនុវត្តសិទ្ធិទទួលបានមត៌កតាមរយៈសន្តតិកម្ម

170 មាត្រា ១២៩២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

171 មាត្រា ១២៩១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

172 មាត្រា ១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១

173 មាត្រា ១២៩៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

174 មាត្រា ១២៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

បានឡើយ។ ដូចនេះ ក្នុងករណីដែលគ្មានសន្តតិជនចេញបង្ហាញខ្លួនតាមការប្រកាសជាសាធារណៈដើម្បីស្វែងរកសន្តតិជន ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា បានដកហូតសិទ្ធិពីសន្តតិជននោះ ដើម្បីធ្វើការបែងចែកមត៌កទៅឱ្យអ្នកមាននិស្ស័យពិសេស។ ចំពោះម្ចាស់បំណុល ឬអច្ច័យលាភីដែលអ្នកគ្រប់គ្រងមិនបានដឹង ដោយសារតែមិនបានស្នើសុំអំពីការទាមទារសិទ្ធិក្នុងអំឡុងពេលនៃការប្រកាសជាសាធារណៈស្វែងរកសន្តតិជន ដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ នៃក្រមរដ្ឋប្បវេណីនោះទេ ជននោះត្រូវបានដកហូតសិទ្ធិក្នុងការទទួលបានទ្រព្យសម្បត្តិរបស់មតកជន[175]។

### ៥.២ ចំណែកនៃជនដែលមានឧបនិស្ស័យពិសេស

នៅក្នុងករណីខ្លះ ក៏អាចមានមត៌កដែលនៅសល់ក្រោយពីការរលត់សិទ្ធិ ដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ នៃក្រមរដ្ឋប្បវេណីផងដែរ។ ប្រសិនបើតុលាការពិចារណាឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និងជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ប៉ុន្តែចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្តាលនៃមត៌កដែលនៅសេសសល់នោះទេ។

ពាក្យសុំរបស់ជននោះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ខែ ក្រោយពីអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ ស្វែងរកសន្តតិជនបានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះ ឱ្យបានច្បាស់លាស់[176]។

### ៥.៣ មត៌កដែលក្លាយជារបស់រដ្ឋ

ជាទូទៅ ទ្រព្យសម្បត្តិរដ្ឋ មានប្រភពមកពីទ្រព្យសម្បត្តិទាំងឡាយដែលកើតឡើងតាមធម្មជាតិ ឬបង្កើតឡើងដោយមនុស្សជាតិ ក្រោមទម្រង់ជាចលនវត្ថុ ឬអចលនវត្ថុរូបី ឬអរូបី ដែលមិនមែនជាកម្មសិទ្ធិឯកជន[177]។ ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ[178]។ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរដ្ឋផងដែរ ចំពោះទ្រព្យសម្បត្តិដែលទទួលបានតាមរយៈលទ្ធកម្មនៃកម្មសិទ្ធិមកជាទ្រព្យសម្បត្តិរដ្ឋ ដោយប្រើប្រាស់ ឬមិនប្រើប្រាស់ថវិការដ្ឋ មានជាអាទិ៍ ការទិញ ការដូរ អស្សាមិករណ៍ ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាឃាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ការរឹបអូសដោយសេចក្តីសម្រេចរបស់តុលាការ ព្រមទាំងទ្រព្យសម្បត្តិដែលរដ្ឋទទួលបានដោយមធ្យោបាយស្របច្បាប់ផ្សេង

[175] មាត្រា ១២៩៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងសេចក្តីកំណត់មាត្រា ១២៩៨ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

[176] មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[177] មាត្រា ៤ នៃច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០

[178] មាត្រា ៥៨ វាក្យខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ទៀត[179]។ ដូចគ្នានេះដែរ ក្រមរដ្ឋប្បវេណី ក៏បានបញ្ញត្តិចំពោះទ្រព្យដែលអាចក្លាយទៅជាទ្រព្យសម្បត្តិរបស់រដ្ឋផងដែរ នៅក្នុងករណីមានសន្តតិកម្មកើតឡើង ប៉ុន្តែមត៌កនោះគ្មានសន្តតិជន ហើយមិនត្រូវបានចែកទៅឱ្យជនដែលមាននិស្ស័យពិសេស ក៏ត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋផងដែរ[180]។ ពាក់ព័ន្ធនឹងចំណុចនេះ យើងក៏សង្កេតឃើញមានកំណត់នៅក្នុង ច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់ជនបរទេសផងដែរ។ នៅពេលដែលមានសន្តតិកម្មកើតឡើង ក្នុងករណីដែលមត៌កជាអគារសហកម្មសិទ្ធិនៅទំនេរដោយគ្មានសន្តតិជនទទួលបន្ត ឬសន្តតិជនបោះបង់ចោល ឬមត៌កមិនត្រូវបានចាត់ចែងឱ្យទៅជនណាមួយតាមបញ្ញត្តិច្បាប់ មត៌កនៅទំនេរនោះ ត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ[181]។

## ផ្នែកទី៦ ៖ ការទាមទារបដិទានសន្តតិកម្ម

ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម មានភាពខុសគ្នាទៅនឹងករណីដែលសន្តតិជន ធ្វើការទាមទារយកមត៌កមកវិញ នៅពេលដែលមានតតិយជន បានកាន់កាប់មត៌កដោយគ្មានសិទ្ធិ ដែលជាមូលហេតុគតិយុត្តសមស្របក្នុងការកាន់កាប់នោះ។ ម៉្យាងទៀត មានតែសន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្មទេ ដែលមានសិទ្ធិក្នុងការទាមទារឱ្យធ្វើបដិទាន[182]សន្តតិកម្មនោះ ក្រៅពីសន្តតិជនមិនមានបុគ្គលណាមួយ មានសិទ្ធិក្នុងការទាមទារឱ្យធ្វើបដិទានសន្តតិកម្មបាននោះទេ ហើយសន្តតិជនមានសិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ជាក់លាក់តែប៉ុណ្ណោះ ប្រសិនបើសន្តតិជនមិនបានទាមទារក្នុងអំឡុងពេលដែលច្បាប់បានកំណត់ទេ សិទ្ធិនោះនឹងត្រូវរលត់។

### ៦.១ បុគ្គលដែលមានសិទ្ធិទាមទារ

សន្តតិជន ដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្មដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគបាន ប្រសិនបើសហសន្តតិជនផ្សេងទៀតបានធ្វើការពិភាក្សាគ្នាក្នុងការបែងចែកមត៌កគ្នារួចហើយ។ ម៉្យាងវិញទៀត ការទាមទារឱ្យធ្វើបដិទាននេះ ជាស្ថានភាពមួយដែលអ្នកមានសិទ្ធិជាសន្តតិជន អាចទាមទារចំពោះជនដែលបានទទួលមត៌កតាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់ត្រឡប់មកវិញនូវទ្រព្យដែលបានទទួលនោះ។ មានន័យថា ជនដែលគេយល់ថាជាសន្តតិជនតាមសភាពខាងក្រៅ កំពុងកាន់កាប់មត៌កដោយមូលហេតុទទួលសន្តតិកម្ម ជនដែលជាសន្តតិជនពិតប្រាកដ អាចធ្វើការ

---

[179] មាត្រា ៦ ចំណុច ខ នៃច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០

[180] មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[181] មាត្រា ១០ នៃច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសឆ្នាំ២០១០

[182] ការស្តារឡើងវិញនូវស្ថានភាពដើម ឬការសងប្រគល់ត្រឡប់វិញ (ឧទាហរណ៍ ការបង្វិលសងវត្ថុដែលកូនបំណុលបានប្រគល់ ឬសងប្រាក់ ដែលកូនបំណុលបានបង់ ឬបង្វិលសងវត្ថុដែលម្ចាស់បំណុលកំពុងប្រើប្រាស់ ឬថែរក្សាគ្រប់គ្រង ទៅកូនបំណុលវិញ ឬការបង្វិលសងវិញនូវទ្រព្យមត៌កដែលអ្នកគ្មានសិទ្ធិខាងសន្តតិកម្មបានទទួលជាដើម)។

ទាមទារឱ្យជននោះប្រគល់មត៌កនោះមកខ្លួនវិញបាន។ មិនតែប៉ុណ្ណោះ សន្តតិជនក៏អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ចំពោះសន្តតិជនដែលបានទទួលសន្តតិកម្មលើសចំណែកមត៌កបាន ដោយហេតុថានៅពេលធ្វើការបែងចែកមត៌កសហព័ទ្ធ និង កូនរបស់មតកជន បានជឿថាសន្តតិជនគឺមានតែពួកគេតែប៉ុណ្ណោះ ហើយបានធ្វើលទ្ធកម្មនូវមត៌ករៀងៗខ្លួនបាន។ ក្នុងករណីនេះដែរ ជនដែលត្រូវបានទទួលស្គាល់ជាកូន ហើយត្រូវបានគេបំពាននូវចំណែកមត៌ករបស់ខ្លួន ដូច្នេះជននោះអាចទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មចំពោះសន្តតិជនផ្សេងទៀតបានដែរ។ លើសពីនេះ ក្នុងករណីដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទាន បានលក់មត៌កតាមកិច្ចសន្យានោះ សន្តតិជនមិនអាចធ្វើការទាមទារឱ្យធ្វើបដិទានសន្តតិកម្មចំពោះអ្នកទិញបានទេ ប្រសិនបើអ្នកទិញមិនបានដឹងថា សន្តតិជនដែលជាអ្នកលក់នោះមិនមានសិទ្ធិទៅលើមត៌កដែលជាកម្មវត្ថុនៃកិច្ចសន្យា តែអាចធ្វើការទាមទារនូវថ្លៃលក់ដែលជាវត្ថុជំនួសមត៌កបាន។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទិញបានដឹងច្បាស់ថាសន្តតិជនដែលជាអ្នកលក់នោះមិនមានសិទ្ធិទៅលើមត៌កនោះទេ ហើយនៅតែធ្វើកិច្ចសន្យាលក់ទិញទៀតនោះ សន្តតិជនពិតប្រាកដអាចទាមទារមត៌កដែលជាកម្មវត្ថុនៃកិច្ចសន្យាមកវិញបាន ដោយអះអាងថាកម្មសិទ្ធិនៃវត្ថុនោះមិនត្រូវបានផ្ទេរទៅឱ្យអ្នកទិញវិញ ពីព្រោះអ្នកទិញជាជនទុច្ចរិត និងមានកំហុស[183]។

### ៦.២ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌កមានអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព[184]។ ការកំណត់ត្រឹម ៥ឆ្នាំ សម្រាប់ការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មនេះ គឺព្រោះថាប្រសិនបើមើលពីតតិយជន ជនដែលបានបន្លំឋានៈរបស់ខ្លួនជាសន្តតិជនក៏មិនខុសពីសន្តតិជនធម្មតាផ្សេងទៀតដែរ ដូច្នេះចាំបាច់ត្រូវធ្វើឱ្យមានស្ថិរភាពនៃទំនាក់ទំនងសិទ្ធិ ហើយម្យ៉ាងទៀត ទាំងអំឡុងពេលនេះ ក៏ត្រូវសម្របទៅនឹងអំឡុងពេលនៃការរំលត់សិទ្ធិលើបំណុល (កាតព្វកិច្ច) ដែរ។ ចំពោះករណីដែលបានទទួលសន្តតិកម្មតែឯង សន្តតិកម្មត្រូវបានផ្ទេរនៅថ្ងៃដែលមតកជនបានទទួលមរណភាពបានសេចក្តីថា នៅពេលចាប់ផ្តើមសន្តតិកម្ម។ ដូចនេះ ត្រូវធ្វើការគណនាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ចាប់ពីថ្ងៃនោះទៅ។ រីឯក្នុងករណីនៃសហសន្តតិកម្ម ត្រូវធ្វើការគណនាពីថ្ងៃដែលមត៌កត្រូវបានផ្ទេរទៅតាមមតកសាសន៍ ឬការបែងចែកមត៌កនោះ[185]។

---

[183] មាត្រា១៣០២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[184] មាត្រា១៣០៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[185] សេចក្តីកំណត់មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណី ភាគ៦ គន្លឹះទី៨-ទី៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយប្រធានបទស្តីពី "**សន្តតិកម្មតាមច្បាប់**" រួចមក យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា របបសន្តតិកម្ម ជារបបគតិយុត្តមួយដែលត្រូវបានកំណត់ដោយក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ពោលគឺបញ្ញត្តិឡើងដើម្បីការពារ និងគោរពសិទ្ធិរបស់ញាតិភាពនៃមតកជន មានន័យថាការពារសិទ្ធិដល់សន្តតិជននិងមតកជនកាលដែលគាត់នៅរស់រានមានជីវិត មានសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជាសាច់សារលោហិត ពោរពេញទៅដោយមនោសញ្ចេតនាក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅ និងខ្វាយខ្វល់ ទៅកាន់អ្នកដែលត្រូវទទួលមត៌កទាំងអស់ ដើម្បីបន្តវង្សត្រកូលទៅជំនាន់ក្រោយៗ។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិអំពី ជនដែលមានសិទ្ធិក្នុងការទទួលបន្តនូវចំណែកមត៌កដែលបន្សល់ទុកដោយមតកជន គឺជាជនដែលត្រូវបានកំណត់ដោយច្បាប់ ទៅតាមលំដាប់នៃសន្តតិជននីមួយៗជាបន្តបន្ទាប់ ដោយកំណត់យកតាមញាតិលោហិតខ្សែផ្ទាល់របស់មតកជនប៉ុណ្ណោះ។ ក្រៅពីនេះច្បាប់ក៏បានបញ្ញត្តិក្នុងករណីពិសេស គឺច្បាប់បានកំណត់យកសហព័ទ្ធជាសន្តតិជនជានិច្ច មានន័យថាទោះក្នុងកាលៈទេសៈណាក៏ដោយ ប្រសិនបើសហព័ទ្ធរបស់មតកជនរស់រានមានជីវិត សហព័ទ្ធនោះមានសិទ្ធិទទួលបានចំណែកមត៌កដូចសន្តតិជនលំដាប់ដទៃៗទៀតដែរ លើកលែងតែប្រព្រឹត្តផ្ទុយនឹងច្បាប់។ លើសពីនេះសន្តតិជនទាំងអស់សុទ្ធតែមានសិទ្ធិក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនក្នុងការយល់ព្រម ឬ បោះបង់នូវចំណែកសន្តតិកម្មណាមួយបានប្រសិនបើមានករណីកាតព្វកិច្ចធ្ងន់ធ្ងរពេក។

បើក្រឡេកមកមើលទិដ្ឋភាពពិតជាក់ស្តែងនៅក្នុងសង្គមយើងវិញ សបញ្ជាក់ឱ្យឃើញថាសន្តតិកម្មតាមច្បាប់ពុំទាន់បានអនុវត្តបានទូលំទូលាយនៅឡើយទេ ដោយហេតុថាមនុស្សភាគច្រើនមិនទាន់បានយល់ដឹងស៊ីជម្រៅពីអត្ថន័យនៃសន្តតិកម្មតាមច្បាប់នេះ ដែលសកម្មភាពជាទូទៅតែងជួបប្រទះតែក្នុងរូបភាពជាការប្រគល់ឱ្យនូវទ្រព្យណាមួយពីមតកជនទៅឱ្យទាយាទរបស់ខ្លួនតែប៉ុណ្ណោះ។ ជាទូទៅយើងខ្ញុំសង្កេតឃើញមានការអនុវត្តដោយមើលឃើញតាមរយៈកូន ឬទាយាទរបស់មតកជនដែលសន្តតិជន មានករណីកិច្ចមើលថែរក្សា ទំនុកបម្រុងមតកជនពេលចាស់ជរា ហើយនៅពេលមតកជនទទួលមរណភាពទៅ ទ្រព្យនោះក៏ក្លាយជារបស់ពួកគាត់តែម្តង។ ក្រៅពីនេះយើងសង្កេតឃើញថាមានចំណែកមត៌កដែលទទួលបានតាមរយៈជាប្រទានកម្ម ឬផលប្រយោជន៍ពិសេសណា ដែលជាហេតុធ្វើឱ្យបុគ្គលខ្លះមិនទទួលបានអ្វីនោះទេ ពេលចាប់ផ្តើមនូវសន្តតិកម្ម។ ទោះបីជាយ៉ាងណាក៏ដោយបញ្ហាទំនាស់នៃការបែងចែកទ្រព្យសម្បត្តិគ្នា នៅតែកើតមានឡើងដោយសារសេចក្តីត្រូវការរបស់បុគ្គលរៀងៗខ្លួនរហូតដល់តុលាការជាអ្នកដោះស្រាយ។ យ៉ាងណាមិញ ប្រសិនបើនត្ថិភាពនៃសន្តតិជននោះ ក្រោយពីស្វែងរកអស់លទ្ធភាពហើយមត៌កនោះនឹងត្រូវក្លាយទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។

ជារួមមកការសិក្សាអំពី "**សន្តិកម្មតាមច្បាប់**" មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដោយហេតុថាវាជាការចាំបាច់បំផុតសម្រាប់ការអនុវត្តក្នុងសង្គមជាក់ស្តែង។ មានន័យថាប្រសិនបើប្រជាជនមានចំណេះដឹង ទាក់ទងនឹងសន្តិកម្ម នោះបញ្ហាផ្សេងៗដែលបង្កឱ្យមានជម្លោះ ឬ ផលប៉ះពាល់នូវសិទ្ធិនិងផលប្រយោជន៍ផ្សេងៗនឹងត្រូវបានកាត់បន្ថយថែមមួយកម្រិតផងដែរ។ មិនតែប៉ុណ្ណោះវាក៏មានសារៈសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាអ្នកអនុវត្តច្បាប់ផងដែរ វាជាកត្តាមួយរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកសាង និងលើកកម្ពស់ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និរន្តរភាព និងយុត្តិធម៌ នៅលើប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាដែលយើងរាល់គ្នាគួរចងចាំ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងចងក្រងនូវអត្ថបទសារណា ព្រមទាំងទទួលបានការពន្យល់ណែនាំបន្ថែមពីលោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** រួចមកធ្វើឱ្យយើងខ្ញុំទាំងពីរបានយល់ដឹងបន្ថែមអំពីប្រព័ន្ធសន្តតិកម្មតាមច្បាប់នៅប្រទេសកម្ពុជា ហើយដែលតែងតែកើតមានឡើងនៅក្នុងជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប។

សន្តតិកម្ម នៅតែជាបញ្ហាចោទដ៏ធំមួយដែលប្រជាពលរដ្ឋគ្រប់រូបត្រូវគប្បីយកចិត្តទុកដាក់ និងស្វែងយល់ ព្រោះថាប្រសិនបើប្រជាពលរដ្ឋមិនបានយល់ដឹងពីមូលដ្ឋានច្បាប់ពាក់ព័ន្ធនឹងសន្តតិកម្មតាមច្បាប់នេះ ដែលជាហេតុនាំឱ្យជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់មតកជន មិនអាចអនុវត្តន៍សិទ្ធិរបស់ខ្លួនឱ្យបានពេញលេញ ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍ចំពោះខ្លួនផង និងអាចនាំឱ្យមានបញ្ហាជម្លោះនៅថ្ងៃក្រោយទៀតផង។

ម្យ៉ាងទៀត យើងខ្ញុំសង្កេតឃើញថា ប្រជាពលរដ្ឋខ្មែរយើងមួយចំនួន នៅតែមានកង្វះខាតក្នុងការយល់ដឹងពាក់ព័ន្ធនឹងក្រមរដ្ឋប្បវេណី ពិសេសគឺទាក់ទងសន្តតិកម្មតាមច្បាប់នេះតែម្តង ពីព្រោះថា ប្រជាពលរដ្ឋខ្មែរយើង នៅតែបន្តអនុវត្តតាមទំនៀមទម្លាប់ប្រពៃណីចាស់ដដែល ពោលនៅពេលដែលមានបុគ្គលណាម្នាក់បានស្លាប់ ទ្រព្យសម្បត្តិដែលបន្សល់ទុកនោះ ភាគច្រើនត្រូវធ្លាក់តែទៅលើប្តី ឬប្រពន្ធរបស់ជននោះតែប៉ុណ្ណោះ។ ច្បាប់មិនបានកំណត់ត្រឹមនេះឡើយ ជាក់ស្តែងប្រសិនបើជនដែលបានស្លាប់ទៅនោះ មានប្រពន្ធ តែគ្មានកូន ហើយមានឪពុកម្តាយ នោះទ្រព្យដែលបន្សល់ទុកដោយជននោះ ប្រពន្ធរបស់ជននោះ ក៏មានចំណែកទទួលបានទ្រព្យនោះ ហើយឪពុកម្តាយរបស់ជននោះ ក៏មានចំណែកទទួលបានទ្រព្យនោះផងដែរ។ មិនតែប៉ុណ្ណោះ បើជនដែលបានស្លាប់ទៅនោះ មានប្រពន្ធ គ្មានកូន គ្មានឪពុកម្តាយ ហើយគ្មានជីដូនជីតា ប៉ុន្តែមានបងប្អូនបង្កើតនោះទ្រព្យដែលបន្សល់ទុកដោយជននោះ បងប្អូនបង្កើតរបស់ជននោះ ក៏មានចំណែកទទួលបានទ្រព្យនោះបានដែរ។ នេះគឺជាឧទាហរណ៍ត្រួសៗ ដែលបុគ្គលមានផលប្រយោជន៍ទាក់ទងនឹងទ្រព្យសម្បត្តិរបស់ជនដែលបានស្លាប់ទៅ មិនបានដឹង ហើយមិនបានអនុវត្តសិទ្ធិរបស់ខ្លួននៅពេលចាប់ផ្តើមសន្តតិកម្ម។ បន្ថែមទៅលើចំណុចនេះ យើងខ្ញុំក៏សង្កេតឃើញថា ប្រព័ន្ធនៃការផ្សព្វផ្សាយច្បាប់នៅក្នុងប្រទេសកម្ពុជាយើង នៅមានកម្រិតនៅឡើយ រួមផ្សំនឹងកត្តាជីវភាព និងទីតាំងភូមិសាស្ត្ររបស់ប្រជាជន ដែលជាបញ្ហាចម្បងធ្វើឱ្យប្រជាពលរដ្ឋខ្មែរមួយចំនួនខ្វះការយល់ដឹងអំពីច្បាប់ផងដែរ។

យើងខ្ញុំសង្ឃឹមថា ស្ថាប័នគ្រប់ជាន់ថ្នាក់ដែលមានសមត្ថកិច្ច ពិសេស ក្រសួងយុត្តិធម៌ ដែលជាស្ថាប័នច្បាប់មួយដ៏សំខាន់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ នឹងចូលរួមយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលប្រជាពលរដ្ឋឱ្យមានការយល់ដឹងអំពីច្បាប់កាន់តែទូលំទូលាយ មិនត្រឹមតែ

ចំពោះនិស្សិតច្បាប់ ឬមន្ត្រីអនុវត្តច្បាប់នោះទេ ដើម្បីឱ្យការផ្សព្វផ្សាយច្បាប់ និងការចូលរួមអនុវត្តច្បាប់ទទួលបានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយនិរន្តភាព។

ជាចុងក្រោយ យើងខ្ញុំជឿជាក់ថា នៅពេលដែលប្រជាពលរដ្ឋខ្មែរយើងមានចំណេះដឹងទូលំទូលាយពាក់ព័ន្ធនឹងវិស័យច្បាប់ ពិសេសគឺសន្តតិកម្មនេះ នឹងជួយឱ្យពួកគាត់អាចអនុវត្តន៍សិទ្ធិក្នុងការទទួលបាននូវផលប្រយោជន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលបន្សល់ទុកដោយបុគ្គលដែលបានស្លាប់ទៅហើយ ព្រមទាំងបង្ការមិនឱ្យមានជម្លោះកើតឡើងរវាងបុគ្គលដែលមានផលប្រយោជន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលបន្សល់ទុកនោះ។

# ឯកសារយោង

# ឯកសារយោង

**១.រដ្ឋធម្មនុញ្ញ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

**២.ក្រម**

១.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

២.ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

**៤.ច្បាប់**

១.ច្បាប់ភូមិបាលប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១

២.ច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេសប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០

៣.ច្បាប់ស្តីពីសញ្ជាតិ ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨

៤.ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

៥.ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០

៦.ច្បាប់ស្តីពីឯកពន្ធភាព ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦

៧.ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០

**៥.បទបញ្ញា**

១.អនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

២.អនុក្រឹត្យលេខ ១១២ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

## ៦.ប្រកាស

១.ប្រកាសអន្តរក្រសួងលេខ ៣០ កយដនស.ប្រក/១៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ រវាងទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការចុះបញ្ជី អំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

## ៧.សៀវភៅពាក់ព័ន្ធ

១.សៀវភៅក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១ ខែធ្នូ ឆ្នាំ២០១៥

២.សៀវភៅសេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ១-៣ រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០១៧

៣.សៀវភៅនីតិរដ្ឋប្បវេណី គម្រោងបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា ឧបត្ថម្ភដោយអង្គការ JICA សមិទ្ធផលរបស់ក្រុមការងារសសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៤.សៀវភៅមេរៀនសង្ខេប នីតិរដ្ឋប្បវេណី ដោយលោកមេធាវី អ៊ុំ ប៉ូលី

៥.សៀវភៅក្រមរដ្ឋប្បវេណី ភាគ៦ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ២០១២

## ៨.សន្ទានុក្រម

សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ២០០៧

## ៩.ឯកសារស្រាវជ្រាវតាមរយៈអ៊ីនធឺណែត

១.កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអគ្រានុកូលដ្ឋាន (http://cdslawcambodia.com/wp-content/uploads /2018/12/២០០៥ -អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន.pdf

២. www.ciclg.com, ហ្វេសបុកផេក ៖ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ / Cambodia International Cooperation Law Group

៣.សិក្ខាសាលាស្តីពីសន្តតិកម្ម ដោយមានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយស លោកជំទាវ ចាំង ស៊ីណាត ជាចៅក្រមតុលាការកំពូល ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ តាមរយៈអនឡាយ Microsoft Team

៤.កម្មវិធីយល់ដឹងអំពីច្បាប់ និងជំនួញ ប្រធានបទ ច្បាប់ប្រគល់មត៌ក របស់វិទ្យុបារាំង RFI បកស្រាយដោយលោក សេង ឌីណា

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

- ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

## ឧបសម្ព័ន្ធទី២

- គម្រូពាក្យស្នើសុំឱ្យបែងចែកមត៌ក

## ឧបសម្ព័ន្ធទី៣

- ដីកាសម្រេចបែងចែកមត៌ក

# ឧបសម្ព័ន្ធទី១
# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៧០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ក្រមរដ្ឋប្បវេណី

# គន្ថីទី ៨

# សន្តតិកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១

### ការចាប់ផ្តើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.-** មូលហេតុនៃការចាប់ផ្តើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ។

**មាត្រា ១១៤៦.-** ទីកន្លែងចាប់ផ្តើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២

### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.-** ការទទួលបន្តនូវមតិក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.–** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.–** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្ដើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្ដាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.–** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.–** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្ដាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្ដាច់មត៌ក នេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្ដាច់មត៌កនេះ នៅក្នុងការ សម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.–** ការផ្ដាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្ដាច់ មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការ ឱ្យផ្ដាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះ បានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្ដាច់មត៌កពីសន្តតិជននោះ មានអានុភាព ប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.–** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យ សម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្ដាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការ ផ្ដាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្ដាច់មត៌កពីសន្តតិជន ដោយមតក- សាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម ។

**មាត្រា ១១៥៤.–** ការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការ ផ្ដាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្ដាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាង

លើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្ដាច់មត៌កពីសន្តតិ-ជន ។

**មាត្រា ១១៥៥.–** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ញាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ញាតិជាខ្មែរទេ មត៌កត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ញាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ញាតិជាខ្មែរ ។ ក្នុងករណីនេះនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

# ជំពូកទី ២
# សន្តតិកម្មតាមច្បាប់

## ផ្នែកទី ១
## សន្តតិជន

**មាត្រា ១១៥៦.–** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.–** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.–** ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួន

នោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.-** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.-** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

# ផ្នែកទី ២
# សន្តតិកម្មរបស់សហព័ទ្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.-** ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្តាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្តាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្តាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្តាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

## ផ្នែកទី ៣
## ការសម្រួលចំណែកមត៌ក

**មាត្រា ១១៦៣.-** ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

**មាត្រា ១១៦៤.-** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្ដូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្ដូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្ដើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥.-** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

**មាត្រា ១១៦៦.-** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះ ដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.-** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

**មាត្រា ១២៤៧.–** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង របស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមាន ឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

# ជំពូកទី ៥
# ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.–** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយ កម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះ ខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមតិកបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការ យល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជន របស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.-** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.-** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផង ដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.–** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.–** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមតិកនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មត៌កទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មត៌កនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាយកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.–** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមតិក តាមចំណែកមតិកនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.–** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.–** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្ដឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមតិក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្ដឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្ដោះអាសន្ន ។

**មាត្រា ១២៦៥.–** សោហ៊ុយដែលទាក់ទងទៅនឹងមតិក

សោហ៊ុយដែលទាក់ទងទៅនឹងមតិក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមតិក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមតិក

១-សហសន្តតិជនអាចចាប់ផ្ដើមពិភាក្សាបែងចែកមតិក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិលើមតិក ដោយសារលទ្ធផលនៃការបែងចែកមតិក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្ដូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមតិកតាមមតកសាសន៍ ការបែងចែកមតិកពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមតិក ការបែងចែកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.-** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.-** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.-** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្តូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.-** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

**មាត្រា ១២៧១.-** ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

**មាត្រា ១២៧២.-** ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

**មាត្រា ១២៧៣.-** អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

**មាត្រា ១២៧៤.-** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

**មាត្រា ១២៧៥.-** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះបាន ។

**មាត្រា ១២៧៦.-** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

## ផ្នែកទី ៣

## ការសម្រួលរវាងម្ចាស់បំណុល

**មាត្រា ១២៧៧.-** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ច របស់មតកជន ។

**មាត្រា ១២៧៨.–** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

**មាត្រា ១២៧៩.–** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

## ផ្នែកទី ៤
## ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.–** ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១២៨១.–** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

**មាត្រា ១២៨២.–** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

**មាត្រា ១២៨៣.–** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

**មាត្រា ១២៨៤.–** ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែក

ចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

**មាត្រា ១២៨៥.–** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

**មាត្រា ១២៨៦.–** ការប្តូរមតិកជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មតិកដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មតិកនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១២៨៧.–** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង

នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសង សំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាត របស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

**មាត្រា ១២៨៨.–** ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបាន កំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃ មាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែល អ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះ ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោម មត៌ក ។

**មាត្រា ១២៨៩.–** ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និង សង កាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូច គ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នក

គ្រប់គ្រង ។

## ជំពូកទី ៧
## នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ។

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមត៌ក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមត៌ក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬ អាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមត៌កទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា

១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

**មាត្រា ១២៩៣.–** កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្តល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមតិក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមតិក និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២៩៤.–** ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមតិកត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

**មាត្រា ១២៩៥.–** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩៦.–** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យ-

លាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមតិកជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

**មាត្រា ១២៩៧.–** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មតិកទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

**មាត្រា ១២៩៨.–** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិន

អាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

**មាត្រា ១២៩៩.–** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្ដាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

**មាត្រា ១៣០០.–** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

## ជំពូកទី ៨
## ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

**មាត្រា ១៣០១.-** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

**មាត្រា ១៣០២.-** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

**មាត្រា ១៣០៣.-** ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

**មាត្រា ១៣០៤.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។

# ឧបសម្ព័ន្ធទី២
# ពាក្យសុំឱ្យបែងចែកមត៌ក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

<u>គម្រូពាក្យសុំសម្រាប់ករណីសិក្សាទី១</u>

## <u>ពាក្យស្នើសុំឲ្យបែងចែកមត៌ក</u>

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ **A** អាយុ ៤០ ឆ្នាំ មុខរបររពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "អ្នកដាក់ពាក្យសុំ[1]" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី.................. ដែលមានអាសយដ្ឋានស្ថិតនៅ...............មហាវិថី............... សង្កាត់.............. ខណ្ឌ......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ............។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី.................[2]

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ **B** អាយុ ៤២ ឆ្នាំ មុខរបររពាណិជ្ជករ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៣៥ ផ្លូវលេខ៦៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## <u>សូមគោរពចូលមក</u>

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]

**ក**-ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ

១.អ្នកដាក់ពាក្យសុំធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមតិកដែលបានភ្ជាប់ជាមួយនេះ។

---

[1] មានករណីមួយចំនួនដែលការពិភាក្សាលក្ខណ:សារធាតុរវាងសហសន្តតិជនបានធ្វើឡើងរួចរាល់ ប៉ុន្តែ ចំណុចនេះបង្ហាញតែអំពីឧទាហរណ៍ដែលមេធាវីបានដាក់ពាក្យសុំក្នុងនាមជាអ្នកតំណាងដោយអាណត្តិឲ្យសន្តតិជនតែម្នាក់គត់ក្នុងចំណោមសហសន្តតិជន។ ប្រសិនបើមេធាវីបានដាក់ពាក្យសុំក្នុងនាមតំណាងឲ្យសន្តតិជនច្រើននាក់ក្នុងចំណោមសហសន្តតិជន (រួមបញ្ចូលទាំងករណីដែលធ្វើការតំណាងឲ្យសន្តតិជនទាំងអស់ផងដែរ) នឹងធ្វើឲ្យមានការព្រួយបារម្ភណ៍អំពីភាពផ្ទុយគ្នានៃផលប្រយោជន៍ ហេតុនេះមេធាវីចាំបាច់ត្រូវតែពន្យល់ឲ្យបានច្បាស់លាស់អំពីចំនុចនេះទៅកាន់អតិថិជន និងត្រូវទទួលការយល់ព្រមពីអតិថិជនផងដែរ។ យ៉ាងណាមិញ គេគិតថា វិធីដែលសន្តតិជនណាម្នាក់ក្នុងចំណោមសហសន្តតិជនតំណាងឲ្យសហសន្តតិជនផ្សេងទៀត ហើយបានដាក់ពាក្យសុំ នឹងធ្វើឲ្យមានការព្រួយបារម្ភថាខ្វះការធានាចំពោះនីតិវិធីសម្រាប់សហសន្តតិជនផ្សេងទៀត ហើយពួកគេនឹងមិនពេញចិត្ត។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្តឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[3] តុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីកន្លែងចាប់ផ្តើមសន្តតិកម្ម (តារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។ ហើយទីកន្លែងចាប់ផ្តើមសន្តតិកម្ម គឺជាអាសយដ្ឋាននៅពេលមរណភាពរបស់មតកជន (ក្រមរដ្ឋប្បវេណីមាត្រា១១៤៦)។

២.ភាគីម្ខាងទៀត......ធ្វើលទ្ធកម្មនូវប្រាក់បញ្ញើដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ២ ស្តីពីមត៌ក និងសាច់ប្រាក់ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ៣ស្តីពីមត៌ក ដែលបានភ្ជាប់ជាមួយនេះ ។

**ខ.អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១.មតកជន...... បានទទួលមរណភាពនៅថ្ងៃទី......ខែ......ឆ្នាំ...... ហើយមត៌កដែលដឹងច្បាស់នាពេលបច្ចុប្បន្ន មានដូចទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភ័ណ្ឌស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ (តទៅនេះហៅថា "មត៌កនៃរឿងក្តីនេះ")។

២.នៅពេលទទួលមរណភាព មតកជន.............មានប្រពន្ធ..............ហើយរវាងមតកជន និងប្រពន្ធ.......នោះ មានកូន..........១នាក់។ មតកជនមិនមានកូនផ្សេងទៀតទេ។ មតកជន......មិនបានបន្សល់ទុកមតកសាសន៍ឡើយ[4]។

៣.សន្តតិជនរបស់មតកជនដែលជាអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានពិភាក្សាគ្នាអំពីការបែងចែកមត៌កនៃរឿងក្តីនេះ។ ជាលទ្ធផលនៃការពិភាក្សា ភាគីម្ខាងទៀតមានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរួចទៅហើយ ប៉ុន្តែ ដោយសារតែគាត់មានអាយុច្រើន និង មិនមានប្រាក់ចំណូល ដូច្នេះ គាត់ត្រូវការចាំបាច់នូវសាច់ប្រាក់និង ប្រាក់បញ្ញើក្នុងធនាគារ សម្រាប់ជីវភាពរបស់គាត់ក្នុងពេលខាងមុខ។ ចំណែកឯអ្នកដាក់ពាក្យសុំវិញ គឺជាបុគ្គលិកក្រុមហ៊ុនដែលមានប្រាក់ចំណូល ប៉ុន្តែ គាត់មិនទាន់មានផ្ទះដែលជាកម្មសិទ្ធិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះហើយ អ្នកដាក់ពាក្យសុំ ត្រូវធ្វើលទ្ធកម្មនូវអចលនវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ ហើយភាគីម្ខាងទៀតត្រូវធ្វើលទ្ធកម្មនូវសាច់ប្រាក់ និងប្រាក់បញ្ញើក្នុងធនាគារដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ បន្ថែមពីនេះទៀត តម្លៃទីផ្សារនៃអចលនវត្ថុ ដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ១ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ គឺប្រហែល......ដុល្លារ ហើយ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃនៃការបូកសរុបប្រាក់បញ្ញើនៅក្នុងធនាគារ និងសាច់ប្រាក់សុទ្ធដែលបានសរសេរក្នុងបញ្ជីសារពើភ័ណ្ឌ ២ និង ៣ ស្តីពីមត៌កដែលបានភ្ជាប់ជាមួយនេះ។ ដូចនេះ នៅថ្ងៃទី......ខែ.......ឆ្នាំ២០១៧ ភាគីទាំង២ បានបង្កើត[5]នូវការព្រមព្រៀងដូចមាននៅក្នុងការសរសេរនៃចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ។

៤.អាស្រ័យហេតុនេះ អ្នកដាក់ពាក្យសុំសូមឲ្យតុលាការចេញដីកាសម្រេចតាមការសរសេរនៅក្នុងចំណុចទី១ ខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ ចំពោះពាក្យសុំនៃរឿងក្តីនេះ។

---

[4] បើសិនជាមានមតកសាសន៍ ករណីនេះនឹងក្លាយជាសន្តតិកម្មអនុវត្តតាមមតកសាសន៍ (សន្តតិកម្មតាមមតកសាសន៍)(ក្រមរដ្ឋប្បវេណី មាត្រា ១១៥៥ និង ចាប់ពីមាត្រា ១១៦៨)។

[5] ដើម្បីឲ្យតុលាការចេញដីកាសម្រេចទៅតាមខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ តើរវាងសហសន្តតិជនបានបង្កើតនូវការព្រមព្រៀងពិតប្រាកដដែរឬទេ? (តើសហសន្តតិជនទាំងអស់បានយល់ព្រមតាមការបែងចែកដូចនៅក្នុងខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញដែរឬទេ?)គឺជាចំណុចសំខាន់។ ដូច្នេះហើយ ត្រង់ចំណុចនេះ គួរតែមានការពន្យល់អំពីមូលហេតុលម្អិត ថាតើហេតុអ្វីបានជាបែងចែកតាមវិធីបែបនេះ?

បញ្ជីសារពើភ័ណ្ឌស្ដីពីមត៌ក[7]

១.អចលនវត្ថុ[8]

ទីតាំងស្ថិតនៅ ៖ ភូមិ...... សង្កាត់ ផ្សារកណ្ដាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ៖

លេខក្បាលដី ៖

កម្មសិទ្ធិករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

២.ប្រាក់បញ្ញើក្នុងធនាគារ[9]

ធនាគារ ៖ ប្រទេសកម្ពុជា ធនាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ (អ្នកថែរក្សាគ្រប់គ្រង)[10]

ប្រាក់......រៀល

[7] បញ្ជីសារពើភ័ណ្ឌនៃមត៌ក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្ដង។

[8] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

[9] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី១២៧៥ កថាខណ្ឌទី១)។

[10] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។

**គ.ភស្តុតាងជាឯកសារ**[6]

១.សំបុត្រមរណភាពរបស់មតកជន

២.សំបុត្រកំណើតរបស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

៣.ច្បាប់ចម្លងនៃសៀវភៅគ្រួសារ

៤.ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុ

៥.លិខិតបញ្ជាក់ប្រាក់ដែលនៅសល់ក្នុងគណនីប្រាក់បញ្ញើ

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៨

**អ្នកតំណាងដោយអាណត្តិ**

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

**P**

[6] ចំពោះឯកសារបញ្ជាក់ដំបូង ចាំបាច់ត្រូវតែដាក់ឯកសារដែលចាំបាច់ និងគ្រប់គ្រាន់ទៅតុលាការ ដើម្បីឲ្យតុលាការទទួលស្គាល់នូវខ្លឹមសារនៃដីកាសម្រេចដែលទាមទារឲ្យតុលាការចេញ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ប៉ុន្តែដំណើរការនៃការព្រមព្រៀងទាក់ទងនឹងវិធីបែងចែកមត៌កជាដើម អំពីចំណុចដែលមិនមានឯកសារត្រឹមត្រូវ នឹងក្លាយជាការពន្យល់នៅក្នុងការសួរជំនួសនៅតុលាការ (ច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមាត្រា ២៨ កថាខណ្ឌទី២) ។

## បញ្ជីសារពើភ័ណ្ឌស្តីពីមតិក[7]

១.អចលនវត្ថុ[8]

ទីតាំងស្ថិតនៅ ៖ ភូមិ...... សង្កាត់ ផ្សារកណ្តាល ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ៖

លេខក្បាលដី ៖

កម្មសិទ្ធិករ ៖ ឈ្មោះ និង អាសយដ្ឋាន

អាគារដែលជាសមាសភាពនៃដីខាងលើ

២.ប្រាក់បញ្ញើក្នុងធនាគារ[9]

ធនាគារ ៖ ប្រទេសកម្ពុជា ធនាគារពាណិជ្ជទី១

សាខា ៖ សាខាតាមដងមហាវិថីព្រះមុន្នីវង្ស

លេខគណនីធនាគារ ៖

ឈ្មោះម្ចាស់គណនី ៖

៣.សាច់ប្រាក់ ៖ (អ្នកថែរក្សាគ្រប់គ្រង)[10]

ប្រាក់......រៀល

[7] បញ្ជីសារពើភ័ណ្ឌនៃមតិក ត្រូវសរសេរខ្លឹមសារដែលអាចឲ្យតុលាការយកមកប្រើប្រាស់ក្នុងដីកាសម្រេចបានតែម្តង។

[8] អចលនវត្ថុ ចាំបាច់ត្រូវធ្វើនូវបញ្ជីសារពើភ័ណ្ឌដែលមានទម្រង់ ឬ ខ្លឹមសារដែលអាចយកទៅធ្វើការចុះបញ្ជីបាន។

[9] ប្រាក់បញ្ញើក្នុងធនាគារ ចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃប្រាក់បញ្ញើ ដើម្បីអាចតតាំងដោយភាពត្រឹមត្រូវជាមួយនឹងធនាគារ (ក្រមរដ្ឋប្បវេណី១២៧៥ កថាខណ្ឌទី១)។

[10] សាច់ប្រាក់ភាគច្រើនត្រូវកំណត់ដោយដាក់ឈ្មោះរបស់អ្នកថែរក្សាគ្រប់គ្រង ដោយសារតែវាមានភាពពិបាកក្នុងការកំណត់។

# ឧបសម្ព័ន្ធទី៣
# ដីកាសម្រេចបែងចែកមត៌ក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**<u>ដីកាសម្រេចរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង</u>**

យើង ......................ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

**លេខ ..... "ណ" ភ.ព.មិ**

**ចុះថ្ងៃទី ..-..-២០១៥**

-បានឃើញមាត្រា **៣** , **២២** និងមាត្រា **៣៥** នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

-បានឃើញមាត្រា **១១៦១** , **១១៦២** , **១២៤៨** និងមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ។

-បានឃើញប្រការ **៤០** នៃប្រកាសអន្តរក្រសួង ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណីលេខ **៥៩ ប្រ ក.ជនស / ១១** ចុះថ្ងៃទី ..................................រវាងក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

-បានឃើញសំណុំរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ......... ចុះថ្ងៃទី ........................ របស់សាលាដំបូងរាជធានីភ្នំពេញ ។

រវាងអ្នកដាក់ពាក្យសុំឈ្មោះ ....................... ភេទ.......... អាយុ ......ឆ្នាំ ជាតិខ្មែរ របរ...... អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ....... ផ្លូវ...... ក្រុមទី..... ភូមិ...... សង្កាត់............. ខណ្ឌ................ រាជធានីភ្នំពេញ ។

លោកស្រី ...............ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. ការិយាល័យមេធាវី ............ ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវលេខ....... សង្កាត់........ ខណ្ឌ........ រាជធានីភ្នំពេញ ។

លោក .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. ការិយាល័យមេធាវី ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ........... សង្កាត់........... ខណ្ឌ.......... រាជធានីភ្នំពេញ ។

និង ភាគីម្ខាងទៀតឈ្មោះ ............... ភេទ........ អាយុ ........ ជាតិខ្មែរ និងឈ្មោះ ............ ភេទ..... អាយុ ........ ជាតិខ្មែរ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវ......... ក្រុមទី.... ភូមិ....... សង្កាត់.... ខណ្ឌ....... រាជធានីភ្នំពេញ ។

លោក/កញ្ញា .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ ........... ការិយាល័យ........... ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ....... ផ្លូវលេខ......... សង្កាត់....... ខណ្ឌ....... រាជធានីភ្នំពេញ ។

លោក/កញ្ញា ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ .......... ការិយាល័យច្បាប់កម្ពុជា ស្នាក់ការបច្ចុប្បន្ន ផ្ទះលេខ.......ផ្លូវលេខ............ សង្កាត់.......... ខណ្ឌ....... រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុ</u>** ៖ សុំឲ្យតុលាការចេញដីកាសម្រេចបែងចែកចំណែកមត៌ក ផ្ទះលេខ......... ផ្លូវ...... ក្រុមទី........ ភូមិ....... សង្កាត់........ ខណ្ឌ........ រាជធានីភ្នំពេញ ពីមតកជនឈ្មោះ ............។

-បានឃើញពាក្យសុំ ចុះថ្ងៃទី ............ របស់ឈ្មោះ ................ ។

-បានឃើញសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី .................... របស់លោក/លោកស្រី ........... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................... ។

-បានឃើញកំណត់ហេតុសាកសួរភាគី ចុះថ្ងៃទី ................ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញកំណត់ហេតុសាកសួរភាគី ចុះថ្ងៃទី ................. របស់សាលាដំបូងរាជធានីភ្នំពេញ ។

-ក្រោយពីបានពិនិត្យភស្តុតាងរបស់គូភាគី ។

-ក្រោយពីបានពិនិត្យសំណុំរឿង និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាដំបូងរាជធានីភ្នំពេញ

## សំអាងហេតុ

-តាមការអះអាងរបស់លោក/លោកស្រី......... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ ............. ថា ខ្លួនសុំកែតម្រូវកម្មវត្ថុក្នុងពាក្យសុំចេញដីកាសម្រេច ចុះថ្ងៃទី ................ របស់កូនក្តីខ្លួន ដោយស្នើសុំឲ្យតុលាការបែងចែកចំណែកមត៌កពីសពមតកជនឈ្មោះ ...................... ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........... ផ្លូវ ........... ក្រុមទី........ ភូមិ............. សង្កាត់.............. ខណ្ឌ.......... រាជធានីភ្នំពេញ និង សុំបដិសេធសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ចុះថ្ងៃទី .................. ដោយហេតុថា កូនក្តីខ្លួនឈ្មោះ ............ បានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវជាមួយឈ្មោះ ........... នៅថ្ងៃទី ............. ហើយក្នុងការរួមរស់ជាមួយគ្នា កូនក្តីខ្លួនមានកូនប្រុសម្នាក់ឈ្មោះ ................ លុះដល់ថ្ងៃទី ................ ប្តីរបស់កូនក្តីខ្លួនក៏បានទទួលមរណភាព ។ ខ្លួនសូមឲ្យតុលាការពិនិត្យភស្តុតាងដូចដែលខ្លួនបានដាក់ជូនក្នុងសេចក្តីថ្លែងការណ៍ ចុះថ្ងៃទី .................. និងសូមបដិសេធចោលនូវការទាមទាររបស់ភាគីម្ខាងទៀត ក្នុងការស្នើសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្តាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ........... ឲ្យឈ្មោះ ................ ដោយហេតុថា ឈ្មោះ ................ បានទទួលមរណភាពតាំងពីឆ្នាំ........... រហូតដល់ឆ្នាំ................ទើបបានលក់ ដី- ផ្ទះលេខ.............. ផ្លូវលេខ...........សង្កាត់............ ខណ្ឌ......... រាជធានីភ្នំពេញ ទៅទិញ ដី - ផ្ទះលេខ.............. ផ្លូវ......... ក្រុមទី.....ភូមិ........... សង្កាត់...... ខណ្ឌ............ រាជធានីភ្នំពេញ គឺមានរយៈពេល .....ឆ្នាំ កន្លងមកហើយ ។ ដូច្នេះ ផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិឲ្យធ្វើបដិទានសន្តតិកម្ម ក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅឲ្យភាគីម្ខាងទៀត មានអំឡុងពេល **៥ឆ្នាំ** គិតចាប់ពីពេលនោះ ឬ ក្នុងករណីជនណាម្នាក់ដែលទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល **៥ឆ្នាំ** គិតចាប់ពីថ្ងៃមតកជននោះបានទទួលមរណភាព តាមមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ។ ម៉្យាងទៀត ឈ្មោះ ............ ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ជាមួយឈ្មោះ ................ ឡើយ ។ ហេតុនេះ ខ្លួនសុំឲ្យតុលាការបែងចែកមត៌កជា ........ចំណែក ស្មើគ្នា តាមផ្លូវច្បាប់ ហើយក្នុងអំឡុងពេលឈ្មោះ ............. រស់នៅជាមួយកូនក្តីខ្លួន នៅផ្ទះលេខ...... ផ្លូវ.......... ក្រុមទី..... ភូមិ....... សង្កាត់............. ខណ្ឌ........ រាជធានីភ្នំពេញ ភាគីម្ខាងទៀតឈ្មោះ ......... មិនបានរស់នៅជាមួយកូនក្តីខ្លួន និង មតកជនឈ្មោះ ............ ទេ ពីព្រោះថា ភាគីទាំងពីរបានរៀបការ និង ចាកចេញពីលំនៅឋាន ដោយទទួលបានចំណែកមត៌ករួចរាល់អស់ហើយ ។

-តាមការអះអាងតបរបស់កញ្ញា ................ និងលោក ............ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ .................. និងឈ្មោះ ........... ថា កូនក្តីខ្លួនទទួលស្គាល់ការទាមទារសុំបែងចែកមត៌កតាមច្បាប់ដោយក្នុងអំឡុងឆ្នាំ.................. ម្តាយរបស់កូនក្តីខ្លួនឈ្មោះ ......... បានទទួលមរណភាព ដោយបន្សល់ទុកអចលនវត្ថុ ដី - ផ្ទះ ចំនួន ...... កន្លែង ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ.............. ផ្លូវលេខ........... សង្កាត់........... ខណ្ឌ......... រាជធានីភ្នំពេញ ជាទ្រព្យសម្បត្តិរួមរបស់ឪពុកម្តាយកូនក្តីខ្លួន ។ នៅឆ្នាំ....... ឪពុករបស់កូនក្តីខ្លួន និង កូនក្តីខ្លួនបានព្រម

ព្រៀងគ្នាលក់ ដី - ផ្ទះ នោះ ដើម្បីផ្លាស់ប្តូរទីលំនៅ ដោយយកប្រាក់ពីការលក់ ដី - ផ្ទះ ទៅទិញ ដី - ផ្ទះ ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ....... ក្រុមទី..... ភូមិ...... សង្កាត់...... ខណ្ឌ...... រាជធានីភ្នំពេញ និង រស់នៅទីនោះរហូតដល់សព្វថ្ងៃនេះ ។ លុះនៅឆ្នាំ....... ទើបឪពុករបស់កូនក្តីខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ .......... និង មានកូនប្រុសម្នាក់ឈ្មោះ ............... ។ ការជាពិតណាស់ដែលចំណែកមត៌កចំនួនពាក់កណ្តាលរបស់ឪពុកឈ្មោះ .......... ត្រូវយកមកធ្វើការបែកចែកឲ្យសហសន្តតិជនទាំង ......នាក់ ប៉ុន្តែ ត្រូវធ្វើការបែងចែកចំណែកមត៌កចំនួនពាក់កណ្តាលរបស់ម្តាយឈ្មោះ ........ ជាមុនសិន តាមមាត្រា **១១៤៧** នៃក្រមរដ្ឋប្បវេណី ដែលមត៌កត្រូវតែជាចំណែកទ្រព្យសម្បត្តិផ្ទាល់របស់មតកជន ហើយសហសន្តតិជននឹងក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគនៅលើចំណែកមត៌ក តាមមាត្រា **១១៤៨** នៃក្រមរដ្ឋប្បវេណី ដែលបញ្ជាក់ថា កូនក្តីខ្លួនជាម្ចាស់កម្មសិទ្ធិករអវិភាគទៅលើចំណែកពាក់កណ្តាលនៃមត៌ករបស់ម្តាយ ។ ចំពោះការលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម គឺមិនត្រឹមត្រូវទៅតាមស្ថានភាពនៃការទាមទាររបស់កូនក្តីខ្លួនឡើយ ពីព្រោះជាសន្តតិកម្មតាមច្បាប់ ដែលមិនបានកំណត់អំពីអាជ្ញាយុកាលនៃការទាមទារ ហើយសន្តតិកម្មតាមច្បាប់ ចាប់ផ្តើមអនុវត្តនៅពេលណាដែលមានការទាមទារឲ្យបែងចែកចំណែកមត៌កនោះកើតឡើងតែប៉ុណ្ណោះ ។ កូនក្តីខ្លួន ក៏ដូចជាឪពុក ពុំដែលធ្វើការទាមទារបែងចែកមត៌ករបស់ម្តាយ និង ប្រពន្ធនោះឡើយ គឺបន្តរក្សាស្ថានភាពនៃមត៌កនោះដដែល ក្នុងនាមជាកម្មសិទ្ធិករអវិភាគ រហូតដល់មានការលក់ទិញ ដី - ផ្ទះ ថ្មី ។ ហេតុនេះ ដាច់ខាតទាល់តែមានការយល់ព្រមពីកូនក្តីខ្លួន ទើបអាជ្ញាធរអនុញ្ញាត និង យល់ព្រមឲ្យមានការផ្ទេរកម្មសិទ្ធិ ។ ចំពោះការធ្វើបដិទានសន្តតិកម្ម គឺធ្វើឡើងតែក្នុងករណីដែលសន្តតិជនត្រូវបានដកហូតសិទ្ធិសន្តតិកម្មក្នុងការទទួលមត៌កតែប៉ុណ្ណោះ តាមមាត្រា **១៣០១** នៃក្រមរដ្ឋប្បវេណី ។ ចំពោះអាជ្ញាយុកាល **៥**ឆ្នាំនេះ មិនអាចអនុវត្តលើសន្តតិកម្មតាមច្បាប់ ដែលពុំទាន់មានការទាមទារឲ្យបែងចែកឡើយ ឯការលើកឡើងថា បានធ្វើការបែងចែកចំណែកមត៌ករួចរាល់អស់ហើយនោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះទ្រព្យសម្បត្តិដែលបានមកពីការលក់ ដី - ផ្ទះ ចាស់ បានយកទៅទិញ ដី - ផ្ទះ ថ្មី ព្រមទាំងធ្វើការជួសជុល និងបង្កើតនូវមុខរបរថ្មីអស់ទៅហើយ គ្មានសេសសល់ចំណែកណាមួយ ដើម្បីយកមកធ្វើការបែងចែកនោះទេ ។ ខ្លួនសូមដាក់ជូនតុលាការនូវភស្តុតាង ដើម្បីបញ្ជាក់អំពីសិទ្ធិក្នុងការទាមទាររបស់កូនក្តីខ្លួន ដែលមានដូចជា សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ......... ចុះថ្ងៃទី ............. របស់ឈ្មោះ .........., សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ........... ចុះថ្ងៃទី ...........របស់ឈ្មោះ ................, លិខិតលក់ផ្ទះ ចុះថ្ងៃទី .................., លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី .............., លិខិតស្នើសុំទិញ ចុះថ្ងៃទី ..........................., លិខិតធានាអះអាង ចុះថ្ងៃទី ......................... និងសំណូមពរសុំឲ្យតុលាការចេញដីកាសម្រេចដូចខាងក្រោម ៖

**១**. បែងចែកចំណែកមត៌កចំនួនពាក់កណ្តាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ................ មកឲ្យឈ្មោះ .......... និងឈ្មោះ ................. តាមច្បាប់ ។

**២**. បែងចែកចំណែកមត៌កចំនួនពាក់កណ្តាលទៀត នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ................ មកឲ្យឈ្មោះ .............. , ............. , ............ និងឈ្មោះ ................ តាមច្បាប់ ។

**៣**. អនុញ្ញាតឲ្យអង្គភាពសុរិយោដី និង អង្គភាពពាក់ព័ន្ធ ចុះបញ្ជីផ្ទេរសិទ្ធិកម្មសិទ្ធិករពីឈ្មោះ ............... មកឲ្យសហសន្តតិជន ដូចខាងលើ ។

-តាមសេចក្តីចម្លងសំបុត្រមរណភាពលេខ ................ សៀវភៅមរណភាពលេខ ............... ចុះថ្ងៃទី .................. របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់................. ខណ្ឌ............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ .............. ភេទ........... ថ្ងៃខែឆ្នាំកំណើត .................... បានទទួលមរណភាព កាលពីថ្ងៃទី ................. ដោយស្ថានភាពសព គឺមានប្រពន្ធ ។

-តាមសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍លេខ ......... សៀវភៅអាពាហ៍ពិពាហ៍លេខ ............... ចុះថ្ងៃទី ................ របស់មន្ត្រីអត្រានុកូលដ្ឋាន ឃុំ...... ស្រុក....... ខេត្ត....... បានបញ្ជាក់ថា ឈ្មោះ ................ និងឈ្មោះ .................. គឺជាសហព័ទ្ធនឹងគ្នា ពិតប្រាកដមែន ។

-តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ............ ចុះថ្ងៃទី .............. សៀវភៅបញ្ជាក់កំណើតលេខ ............. ចុះថ្ងៃទី ................ របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ខណ្ឌ............ រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ............ ភេទប្រុស កើតថ្ងៃទី ................ មានឪពុកឈ្មោះ ................ និង ម្តាយឈ្មោះ ................ ។

-តាមសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ............. ចុះថ្ងៃទី .......... សៀវភៅបញ្ជាក់កំណើតលេខ .................... ចុះថ្ងៃទី .................. របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ខណ្ឌ.............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ................ ភេទ............ កើតថ្ងៃទី ............... មានឪពុកឈ្មោះ ................ និង ម្តាយឈ្មោះ ................ ។

-តាមសេចក្តីចម្លងសំបុត្រកំណើតលេខ ............... ចុះថ្ងៃទី ................ សៀវភៅកំណើតលេខ ................ចុះថ្ងៃទី ........................ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់................ ខណ្ឌ.............. រាជធានីភ្នំពេញ បានបញ្ជាក់ថា ឈ្មោះ ................ ភេទ........... កើតថ្ងៃទី .................. មានឪពុកឈ្មោះ ............... និង ម្តាយឈ្មោះ .............. ។

-តាមបង្កាន់ដៃទទួលប័ណ្ណកម្មសិទ្ធិ និង ទទួលប្រាក់ ចុះថ្ងៃទី .............. បានបញ្ជាក់ថា លិខិតផ្ទេរសិទ្ធិ លេខ ......................... លើអចលនវត្ថុ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ.............. ផ្លូវ............ ក្រុមទី................. ភូមិ............ សង្កាត់................ ខណ្ឌ............... រាជធានីភ្នំពេញ គឺជាកម្មសិទ្ធិរបស់ឈ្មោះ ..........។

-តាមការអះអាងរបស់លោកស្រី ............. ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ ............ , ការអះអាងតបរបស់កញ្ញា .............. និងលោក .............. ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀត ឈ្មោះ ...................... និង ការពិនិត្យភស្តុតាងរបស់គូភាគីក្នុងនីតិវិធីសាកសួរភាគីរួចមកឃើញថា ឈ្មោះ .............. និង អ្នកដាក់ពាក្យសុំឈ្មោះ ................. គឺជាសហព័ទ្ធនឹងគ្នា ហើយនៅក្នុងចំណងអាពាហ៍ពិពាហ៍នេះ សហព័ទ្ធមានកូនប្រុសម្នាក់ឈ្មោះ ............. ។ នៅថ្ងៃទី .......... ឈ្មោះ ......... ក៏បានទទួលមរណភាពទៅ ដោយបន្សល់ទុកនូវមត៌កជាអចលនវត្ថុ ចំនួន ....កន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ.......ផ្លូវ.........ក្រុមទី.....ភូមិ.......សង្កាត់.....ខណ្ឌ....... រាជធានីភ្នំពេញ ហើយមតកជនឈ្មោះ .......មានកូនប្រុស ....នាក់ ទៀត ...... និងឈ្មោះ ........... ។ ហេតុនេះ តុលាការគប្បីទទួលស្គាល់ការទាមទាររបស់លោកស្រី ......... ក្នុងការស្នើសុំឲ្យតុលាការចេញដីកាសម្រេចបែងចែកមត៌កតាមច្បាប់ ពីព្រោះអ្នកដាក់ពាក្យសុំឈ្មោះ ........... ដែលជាសហព័ទ្ធរបស់មតកជនឈ្មោះ ........... ត្រូវក្លាយជាសន្តតិជនជានិច្ច តាមមាត្រា **១១៦១** នៃក្រមរដ្ឋប្បវេណី ហើយឈ្មោះ ........ និងឈ្មោះ ....... ដែលត្រូវជាបច្ឆាញាតិផ្ទាល់របស់មតក

ជនឈ្មោះ ......... ត្រូវក្លាយជាសន្តតិជន ដែលមានលំដាប់ស្មើគ្នានឹងឈ្មោះ ......... តាមមាត្រា **១១៦២** កថាខណ្ឌ "**ក**" នៃក្រមរដ្ឋប្បវេណី និង ច្រានចោលការទាមទាររបស់កញ្ញា ......... និងលោក ........ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ ............ ក្នុងការស្នើសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្តាល នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ......... មកឲ្យឈ្មោះ ....... និងឈ្មោះ ......... និងសុំបែងចែកមត៌កដែលជាចំណែកពាក់កណ្តាលទៀត នៃទ្រព្យសម្បត្តិរួមរបស់មតកជនឈ្មោះ ....... មកឲ្យឈ្មោះ ........ និងឈ្មោះ ........ ដោយហេតុថា ឈ្មោះ ......... ដែលត្រូវជាម្តាយរបស់ភាគីម្ខាងទៀតឈ្មោះ ............ និងមតកជនឈ្មោះ.......... ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាទេ ហើយក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថា ដី-ផ្ទះចាស់លេខ........ ផ្លូវលេខ....... ភូមិ....... សង្កាត់....... ខណ្ឌ....... រាជធានីភ្នំពេញ គឺជាទ្រព្យសម្បត្តិរួមរបស់ឈ្មោះ ........ និង មតកជនឈ្មោះ ........... នោះទេ ។ ម៉្យាងវិញទៀត ក្រោយពេលដែលឈ្មោះ .......... បានទទួលមរណភាពទៅក្នុងអំឡុងឆ្នាំ........មត៌កបានធ្លាក់នៅក្រោមការកាន់កាប់របស់ឈ្មោះ ....... រហូតឈ្មោះ ............បានលក់ដី-ផ្ទះចាស់លេខ.......... ផ្លូវលេខ........ ភូមិ....... សង្កាត់....... ខណ្ឌ........ រាជធានីភ្នំពេញ ទៅទិញដី-ផ្ទះថ្មី............ ផ្លូវ......... ក្រុមទី...... ភូមិ......... សង្កាត់........ខណ្ឌ........ រាជធានីភ្នំពេញ ក៏ភាគីម្ខាងទៀតឈ្មោះ .......... និងឈ្មោះ ......... ដែលត្រូវជាកូនរបស់ឈ្មោះ ........... ពុំបានដាក់ពាក្យសុំមកតុលាការ ដើម្បីបែងចែកមត៌កពីឈ្មោះ .......... នោះទេ ដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀត នៃការទាមទារឲ្យធ្វើបដិសន្តតិកម្ម តាមការបែងចែកមត៌ក មានអំឡុងពេល **៥** ( **ប្រាំ** ) **ឆ្នាំ** គិតចាប់ពីពេលនោះ តាមមាត្រា **១៣០៤** នៃក្រមរដ្ឋប្បវេណី ហើយសន្តតិជនត្រូវធ្វើការយល់ព្រម ឬ បោះបង់សន្តតិកម្មទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល **៣** ( **បី** ) **ខែ** គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម តាមមាត្រា **១២៤៨** នៃក្រមរដ្ឋប្បវេណី និង បន្តរហូតមកដល់ពេលមតកជនឈ្មោះ ............. បានទទួលមរណភាព នៅថ្ងៃទី ..........ទៀត ក៏ភាគីម្ខាងទៀតឈ្មោះ ......... និងឈ្មោះ .......... ពុំបានដាក់ពាក្យសុំបែងចែកមត៌ក ឬ ពាក្យសុំពន្យារពេលបែងចែកមត៌កពីមតកជនឈ្មោះ ........ មកកាន់តុលាការដែរ ។

-ចំពោះការទាមទាររបស់កញ្ញា ....... និងលោក ............ ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីម្ខាងទៀតឈ្មោះ .......... និងឈ្មោះ ........ ត្រង់ចំណុចទី**៣** ក្នុងការសុំអនុញ្ញាតឲ្យអង្គភាពសុរិយោដី និង អង្គភាពពាក់ព័ន្ធ ចុះបញ្ជីផ្ទេរសិទ្ធិកម្មសិទ្ធិករពីឈ្មោះ ........... មកឲ្យសហសន្តតិជន តុលាការគប្បីទទួលស្គាល់ តាមប្រការ **៤០** នៃប្រកាសអន្តរក្រសួងលេខ **៥៩ ប្រក.ដនស** / **១១** ចុះថ្ងៃទី **៣០-០៥-២០១១** រវាងក្រសួងយុត្តិធម៌ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ តាមមាត្រា **២២** នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

## សាលាដំបូងរាជធានីភ្នំពេញ

## សម្រេចសេចក្តីបញ្ចប់

**១**/. ទទួលស្គាល់ការទាមទាររបស់លោកស្រី ......... ជាមេធាវីតំណាងដោយអាណត្តិឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .......... ក្នុងការស្នើសុំឲ្យតុលាការបែងចែកមត៌ក ។

២/. បែងចែកមត៌ករបស់មតកជនឈ្មោះ ......... ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ....... ក្រុមទី.... ភូមិ....... សង្កាត់....... ខណ្ឌ...... រាជធានីភ្នំពេញ ជា ........ ចំណែក ស្មើគ្នា រវាងសន្តតិជនឈ្មោះ .........។

៣/. អនុញ្ញាតឲ្យអង្គភាពសុរិយោដី ចុះបញ្ជីផ្លាស់ប្តូរសិទ្ធិកម្មសិទ្ធិករលើអចលនវត្ថុ ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ........ ផ្លូវ...... ក្រុមទី...... ភូមិ.......... សង្កាត់........ ខណ្ឌ...... រាជធានីភ្នំពេញ ពីឈ្មោះ ......... ឲ្យមកឈ្មោះ .... ។

៤/. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំឈ្មោះ ............ ។

- ទុកសិទ្ធិឲ្យគូភាគីប្តឹងជំទាស់ក្នុងអំឡុងពេល ......**សប្តាហ៍** គិតចាប់ពីថ្ងៃ ដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចនេះ ៕

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា :** ............

---

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

រាជធានីភ្នំពេញ, ថ្ងៃទី .......ខែ ...... ឆ្នាំ .......

បានឃើញ **ក្រឡាបញ្ជី**

**ចៅក្រម**